**សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# ប្រៀបធៀបប្រាតិភោគដោយអនុប្បទាន
# កម្ពុជា-ជប៉ុន

ស្រាវជ្រាវចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ក. លី សិរីរ័ត្ន**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ប៊ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ អនុញ្ញាតឲ្យនាងខ្ញុំ សូមធ្វើការសម្ដែងនូវកតញ្ញូ កតវេទី ចំពោះលោកអ្នកដែលមាននាមដូចខាងក្រោម៖

លោកឪពុក **លី ម៉ុនថន** និង អ្នកម្ដាយ **ចក់ ឧបុល** ជាទីគោរព និងជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ លោកជាម្លប់ដ៏ត្រជាក់ ផ្ដល់កំណើត ចិញ្ចឹមបីបាច់ ផ្ដល់ការអប់រំ បញ្ជូនទៅសាលាឲ្យទទួលការអប់រំ លើកទឹកចិត្តកូនស្រីមិនដែលលោះពេលឲ្យខិតខំសំភីរៀនសូត្រ តាំងពីកូននៅតូចមិនទាន់ដឹងក្ដី រហូតដល់ពេលនេះកូនអាចមានភាពឯករាជ្យ អាចបោះជំហានដោយខ្លួនឯងបាន និងជាពិសេសចំពោះការជ្រោមជ្រែងពីសំណាក់អ្នកមានគុណទាំងទ្វេ ជួយឲ្យកូនអាចសម្រេចកម្រិតឧត្ដមសិក្សា ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះបាន។

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ជាគ្រឹះស្ថានសិក្សាអប់រំ ដែលមិនត្រឹមតែផ្ដល់នូវសាស្ត្រាចារ្យល្អៗ មានជំនាញក្នុងការផ្ទេរចំណេះដឹងពិតប្រាកដដល់រូបនាងខ្ញុំប៉ុណ្ណោះទេ ថែមទាំងជាឋានជួយហាត់ពត់ លត់ដំចរិយាមារយាទ អប់រំស្មារតីឲ្យបណ្ដុះខ្លួនក្លាយទៅជាពលរដ្ឋល្អ ជាទំពាំងស្នងឫស្សីដែលប្រទេសជាតិមិនអាចខ្វះបាន។

**មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវច្បាប់ជប៉ុន** (CJL) ជាកន្លែងបណ្ដុះបណ្ដាលធនធាននិស្សិតពិតប្រាកដឲ្យយល់ពីជម្រៅនៃការសិក្សារៀនសូត្រ ដែលបានផ្ដល់ជាអាហារូបករណ៍ពេញរយៈពេល៥ឆ្នាំ ជួយឲ្យនាងខ្ញុំមានការវិភាគបានស៊ីជម្រៅបន្ថែមមួយកម្រិតទៀតទៅលើសារណា ព្រមទាំងផ្ដល់ជាឯកសារនានា ញ៉ាំងឲ្យនាងខ្ញុំមានឱកាសក្នុងការប្រៀបធៀបរវាងប្រព័ន្ធច្បាប់ប្រទេសកម្ពុជា និងជប៉ុនដូចមានសេចក្ដីរៀបរាប់នៅក្នុងកិច្ចការសារណានេះ។

**លោក លោកស្រីសាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាអ្នកអប់រំប្រៀនប្រដៅទាំងផ្នែកទ្រឹស្ដី ទាំងបង្ហឹកផ្នែកការអនុវត្ត លើកទឹកចិត្ត ស្មារតីឲ្យរូបនាងខ្ញុំកាន់តែមានឆន្ទៈមោះមុតមិនរាថយ រហូតទទួលបាននូវចំណេះដឹងជាសារវន្តក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ អាចឲ្យនាងខ្ញុំក្រេបយកទៅបំពេញវិជ្ជាជីវៈផ្នែកច្បាប់ទាំងពេលបច្ចុប្បន្ន និងកាន់តែពង្រីកការយល់ដឹងឲ្យកាន់តែទូលំទូលាយបន្ថែមទៀតនាពេលអនាគត។

ជាពិសេស នាងខ្ញុំក៏សូមសម្ដែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកស្រីសាស្ត្រាចារ្យ **ម៉ួយ ធីតា** ជាគ្រូដឹកនាំសារណាដែលបានជួយគាំទ្រនាងខ្ញុំយ៉ាងពេញទំហឹង ជាប្រទីបបំភ្លឺ តម្រង់ទិស ជួយឲ្យនាងខ្ញុំមានវិធីសាស្ត្រកាន់តែច្បាស់លាស់ ធ្វើឲ្យកិច្ចការសារណានេះ លេចចេញជារូបរាងឡើង។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធពរជ័យ បវរសួស្ដីដល់លោកអ្នកមានគុណទាំងអស់ ឲ្យជួបតែនឹងសេចក្ដីសុខ សុភមង្គលជានិរន្តរ៍ ព្រមទាំងទទួលបានជោគជ័យលើគ្រប់ភារកិច្ច។

# អារម្ភកថា

កន្លងមក មានលោក លោកស្រីសាស្ត្រាចារ្យ និស្សិត ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវមួយចំនួន បានយកចិត្តទុកដាក់យ៉ាងសស្រាក់សស្រាំក្នុងការសិក្សាពីបញ្ញត្តិនីមួយៗនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានបង្កើតឡើងនាឆ្នាំ២០០៧ ពាក់ព័ន្ធនឹងរឿងរ៉ាវបុគ្គលឯកជនរួមមានទ្រព្យសម្បត្តិ និងញាតិ។ មានគោលការណ៍មួយចំនួនថែងបានគ្រប់គ្រាន់ជាក់លាក់ដែលបង្កលក្ខណៈងាយស្រួលក្នុងការយកគោលការណ៍ទាំងនោះយកមកអនុវត្ត ចំណែកគោល-ការណ៍មួយចំនួនទៀត នៅមានសភាពចន្លោះប្រហោងនៅឡើយ ដែលអាចឲ្យមតិសាធារណជនមានការភ័ន្តច្រឡំ ឬឈានទៅដល់ការមានបំណកស្រាយផ្សេងគ្នាផងក៏មាន។

បរិយាយត្រឹមតែបញ្ញត្តិស្តីពី ប្រាតិភោគដោយអនុប្បទានពីក្រមរដ្ឋប្បវេណីកម្ពុជា ចាប់ពីមាត្រា៨៨៨ ដល់មាត្រា៨៩៩ នាងខ្ញុំមានការចាប់អារម្មណ៍ពីប្រព័ន្ធនៃការយកបញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាននេះយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជា ដោយសង្កេតឃើញថា កន្លែងផ្តល់សេវាប្រាតិភោគដោយអនុប្បទាននានា មានការកើនឡើងជាបន្តបន្ទាប់។ ទន្ទឹមនឹងការសិក្សាច្បាប់ជប៉ុនជាភាសាជប៉ុន នាងខ្ញុំក៏បានយល់ដឹងពីអត្ថន័យ ខ្លឹមសារនៃទ្រឹស្តី ព្រមទាំងការអនុវត្តប្រាតិភោគដោយអនុប្បទានរបស់ប្រទេសជប៉ុន ហើយបានមើលឃើញពីភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងបញ្ញត្តិនៃប្រទេសទាំងពីរនេះ បើទោះបីជាកម្ពុជាបានទទួលឥទ្ធិពលច្បាប់ខាងរដ្ឋប្បវេណីពីជប៉ុនក្តីក៏មិនប្រាកដថានឹងមានលក្ខណៈដូចគ្នាទាំងអស់សុទ្ធសាធនោះទេ។ ក្នុងនាមជានិស្សិតច្បាប់មួយរូប នាងខ្ញុំចង់ពាំនាំយកនូវបញ្ញត្តិបរទេសយកមកឲ្យអ្នកសិក្សាទាំងឡាយជួយពិនិត្យ ស្រាវជ្រាវទាំងអស់គ្នា ជួយពិចារណារួមគ្នា ថានឹងមានចំណុចណា ត្រូវយកជាគំរូមកសម្រួលច្បាប់ជាតិយើង ដើម្បីអភិវឌ្ឍវិស័យច្បាប់ឲ្យសមនឹងស្ថានភាពទូទៅរបស់ស្រុកទេសយើង។

ហេតុដូចដែលបានពោលខាងលើនេះហើយ ដែលជាកត្តាលីករជម្រុញទឹកចិត្តនាងខ្ញុំឲ្យជ្រើសយកប្រធានបទស្តីពី **«ប្រៀបធៀបប្រាតិភោគដោយអនុប្បទានកម្ពុជា-ជប៉ុន»** យកមកធ្វើការវែកញែកជាបន្តបន្ទាប់ទៅនេះ។

នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះ នឹងក្លាយទៅជាចំណេះដឹងថ្មីរបស់អ្នកអានទាំងឡាយ ដោយហេតុថា ជាទូទៅយើងតែងយល់ពីច្បាប់កម្ពុជា ប៉ុន្តែមិនធានាថាយល់ដឹងអស់ពីច្បាប់បរទេសនោះទេ (ក្នុងករណីនេះ គឺប្រទេសជប៉ុន)។ នាងខ្ញុំនឹងព្យាយាមរំលេចឲ្យឃើញពីលក្ខណៈពិសេសប្លែក ដែលប្រព័ន្ធកម្ពុជាពុំទាន់មានបញ្ញត្តិយកមកអនុវត្ត ប៉ុន្តែមាននៅប្រទេសជប៉ុនរួចមកហើយ។ ទន្ទឹមនឹងនេះ សារណានេះនឹងជាប្រយោជន៍ដល់អ្នកសិក្សាឲ្យ ស្វែងយល់កាន់តែទូលំទូលាយអំពីប្រាតិភោគដោយអនុប្បទានបន្ថែមទៀត។

## មាតិកា

ទំព័រ

**សេចក្តីថ្លែងអំណរគុណ** ...... i

**អារម្ភកថា** ...... ii

**មាតិកា** ...... iii

**សេចក្តីផ្តើម** ...... ១


## ជំពូកទី១

**លក្ខណៈដូចគ្នានៃបទប្បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទានកម្ពុជា-ជប៉ុន** ...... ៤

**ផ្នែកទី១ សុពលភាព និងលក្ខខណ្ឌតតាំងនៃប្រាតិភោគដោយអនុប្បទាន** ...... ៥

កថាខណ្ឌទី១ ការបង្កើត ...... ៨

ក- រចនាសម្ព័ន្ធនៃការបង្កើត ...... ៨

ខ- អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ...... ៩

ខ-១- ការផ្ទេរការកាន់កាប់ ...... ១០

ខ-២- ការកម្រិតអានុភាពតតាំង ...... ១៣

កថាខណ្ឌទី២ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ...... ១៤

ក- វិសាលភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ...... ១៤

ខ- ការកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ...... ១៦

**ផ្នែកទី២ លក្ខខណ្ឌតតាំង និងការអនុវត្តប្រឈមជាបញ្ហានៃសិទ្ធិប្រាតិភោគដោយអនុប្បទាន** ...... ១៧

កថាខណ្ឌទី១ គោលការណ៍ទូទៅនៃលក្ខខណ្ឌតតាំង ...... ១៨

កថាខណ្ឌទី២ លក្ខខណ្ឌតតាំងក្នុងករណីប្រាតិភោគដោយអនុប្បទាន ...... ១៩

កថាខណ្ឌទី៣ ហានិភ័យដែលអាចនឹងកើតឡើងចំពោះម្ចាស់បំណុល ...... ២០

ក. បញ្ហានៃករណីតតិយជនក្លាយជាអ្នកទិញ ...... ២២

ខ. បញ្ហានៃករណីតតិយជនក្លាយជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានលំដាប់ទី២ ...... ២៥

គ. បញ្ហានៃករណីចលនវត្ថុផ្គុំគ្នាដែលត្រូវបានលក់មួយផ្នែក ...... ២៨

កថាខណ្ឌទី៤ ការអនុវត្តប្រាតិភោគដោយអនុប្បទាន ...... ២៩

**ជំពូកទី២**

**លក្ខណៈខុសគ្នានៃបទប្បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទានកម្ពុជា-ជប៉ុន** ............. ៣១
**ផ្នែកទី១ លក្ខខណ្ឌនៃការទទួលស្គាល់ប្រាតិភោគដោយអនុប្បទានតាមរយៈ ការផ្ទេរការកាន់កាប់នៅកម្ពុជា** ...................................................... ៣១
កថាខណ្ឌទី១ ការការពារម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន ................ ៣២
កថាខណ្ឌទី២ ការការពារតតិយជនសុចរិត ....................................................៣៣
កថាខណ្ឌទី៣ តុល្យភាពនៃការការពាររវាងសិទ្ធិរបស់ម្ចាស់បំណុលប្រាតិភោគ ដោយ អនុប្បទាន និងតតិយជន ............................................... ៣៤
កថាខណ្ឌទី៤ ស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងផ្នែកប្រាតិភោគដោយអនុប្បទាន .. ៣៩
**ផ្នែកទី២ លក្ខខណ្ឌនៃការទទួលស្គាល់ប្រាតិភោគដោយអនុប្បទានតាម រយៈការចុះបញ្ជីនៅជប៉ុន** ............................................................. ៤០
កថាខណ្ឌទី១ លក្ខខណ្ឌគ្រឹះ និងផលប្រយោជន៍នៃការចុះបញ្ជីចលនវត្ថុ ........... ៤០
កថាខណ្ឌទី២ ការចុះបញ្ជីចលនវត្ថុ ............................................................. ៤៣
ក- ប្រភេទនៃការចុះបញ្ជី ................................................................... ៤៣
ខ- នីតិវិធីនៃការចុះបញ្ជី .................................................................... ៤៣
គ- ទីកន្លែងចុះបញ្ជី និងស្ថាប័នមានសមត្ថកិច្ច..................................... ៤៥
កថាខណ្ឌទី៣ អាទិភាពតតាំងសិទ្ធិចំពោះកូនបំណុល តតិយជន ឬម្ចាស់-បំណុល .......................................................................................... ៤៥
**សេចក្តីសន្និដ្ឋាន**...........................................................................................៤៧
**អនុសាសន៍**.................................................................................................. ៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

មកដល់ពេលបច្ចុប្បន្ននេះ មានប្រជាជនជាច្រើននៅលើសកលលោក រួមទាំងប្រជាជននៃប្រទេសកម្ពុជាផងនោះ កំពុងរស់នៅក្នុងជីវភាពមានកម្រិតក្រីក្រនៅឡើយ។ ជាក់ស្តែងយោងតាមអត្ថបទមួយដែលចុះផ្សាយនៅលើគេហទំព័ររបស់ធនាគារពិភពលោក (World Bank) នាខែមេសា ឆ្នាំ២០១៦ ប្រទេសកម្ពុជានៅមានប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រប្រមាណ១៧,៧% ដែលទិន្នន័យនេះ ជាទិន្នន័យចុងក្រោយបំផុតក្នុងឆ្នាំ២០១២[1]។ ប្រជាជនប្រហែល៣លាននាក់ មានជីវភាពក្រីក្រ ខណៈពេលដែល៨,១លាននាក់ទៀតមានស្ថានភាពសេដ្ឋកិច្ចគ្រួសារមធ្យម ឬឈានទៅដល់ក្បែរបន្ទាត់នៃភាពក្រីក្រ។ ទិន្នន័យទាំងនេះអាចសបញ្ជាក់ឲ្យឃើញអំពីកង្វះខាតហិរញ្ញវត្ថុក្នុងគ្រួសារនីមួយៗ។ អាស្រ័យដោយកង្វះខាតផ្នែកហិរញ្ញវត្ថុនេះហើយ ញ៉ាំងឲ្យប្រជាជនមួយចំនួនជ្រើសរើសវិធីកម្ចីប្រាក់ពីបុគ្គលដទៃ ឬពីគ្រឹះស្ថានផ្តល់សេវាប្រាក់កម្ចីនានា ដើម្បីយកមកដោះទ័លការចំណាយជីវភាពប្រចាំថ្ងៃ និងមួយចំនួនទៀតដើម្បីជាទុនសម្រាប់ប្រកបរបររកស៊ី។ ទន្ទឹមនឹងនេះក្នុងការធានាឲ្យបានថាកម្ចីទាំងនោះនឹងត្រូវបានសងត្រឡប់ទៅម្ចាស់ដើមវិញ ម្ចាស់បំណុលភាគច្រើនទាមទារឲ្យកូនបំណុលដាក់ធានាបំណុលដោយវត្ថុ ឬការធានាដោយបុគ្គល។ តួយ៉ាងនៅប្រទេសកម្ពុជា បច្ចុប្បន្ន មានការកើនឡើងនូវការប្រើប្រាស់តាមវិធីប្រាតិភោគដោយអនុប្បទាន[2]គួរឲ្យកត់សម្គាល់។

ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា បានបញ្ញត្តិស្តីពី«ប្រាតិភោគដោយអនុប្បទាន»នេះ យ៉ាងជាក់លាក់ នៅត្រង់គន្លឹ៦ ជំពូកទី៦។ បើពិនិត្យទៅលើក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន ដែលជាប្រភពនៃក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាឆ្នាំ២០០៧ មិនមានចែងអំពីបញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាននេះទេ។ ដូច្នេះហើយ វាល់វិវាទដែលពាក់ព័ន្ធនឹងផ្នែកប្រាតិភោគដោយអនុប្បទាន គឺត្រូវបានដោះស្រាយដោយយោងតាមយុត្តិសាស្ត្ររបស់តុលាការនៃប្រទេសជប៉ុន។ អត្ថិភាពនៃវិធីសាស្ត្រដោះស្រាយបែបនេះ គួបផ្សំជាមួយនឹងភាពងាយស្រួលក្នុងការអនុវត្តវិធីសាស្ត្រប្រាតិភោគដោយអនុប្បទានផង ទើបធ្វើឲ្យការអនុវត្តប្រាតិភោគដោយអនុប្បទានកាន់តែមានភាពពេញនិយមនៅប្រទេសជប៉ុន។

មានមតិមួយចំនួនបានយល់ឃើញថា ការកើនឡើងនៃការប្រើប្រាស់ប្រាតិភោគដោយអនុ-ប្បទាននៅកម្ពុជា គឺបណ្តាលមកពីការរីកចម្រើនផ្នែកសេដ្ឋកិច្ច ក៏ដូចជាការអភិវឌ្ឍជាសកលលើ

[1]គេហទំព័ររបស់ធនាគារពិភពលោក http://www.worldbank.org/en/country/cambodia/overview (ចូលមើលថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦)

[2] ប្រាតិភោគដោយអនុប្បទាន ជាវិធីដាក់ចលនវត្ថុដើម្បីធានាសងបំណុល

វិស័យច្បាប់។ ទន្ទឹមនឹងកំណើនការអនុវត្តគួរឲ្យកត់សម្គាល់នេះ គេមិនអាចអះអាងបានទេថាក្នុងការអនុវត្តពិតជាអាចប្រព្រឹត្តទៅបានរលូនដោយមិនមានឧបសគ្គអ្វីនោះឡើយ។ ដោយហេតុថានៅក្នុងបញ្ហាសិទ្ធិលើបំណុល តែងតែមានភាពស្មុគស្មាញត្រង់ការការពារសិទ្ធិរបស់ម្ចាស់បំណុល កូនបំណុល និងតតិយជន ដូចនេះទើបមានចម្ងល់មួយថា តាមរយៈប្រាតិភោគដោយអនុប្បទាន តើគ្រប់ភាគីពាក់ព័ន្ធក្នុងបញ្ហាបំណុល អាចទទួលបានលទ្ធភាពនៃការការពារសិទ្ធិ និងផលប្រយោជន៍បានគ្រប់ជ្រុងជ្រោយហើយឬយ៉ាងណា? ចម្ងល់នេះនៅមិនទាន់មានការបកស្រាយណាមួយឲ្យបានច្បាស់លាស់នៅឡើយដែលទាមទារឲ្យមានការសិក្សាមួយយ៉ាងជាក់លាក់។

បើម្ចាស់បំណុល (ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន) កាន់កាប់ដោយផ្ទាល់លើចលនវត្ថុនោះគឺអាចបញ្ជាក់ច្បាស់ថា វាជាលក្ខខណ្ឌជាក់លាក់ដើម្បីតតាំងជាមួយនឹងតតិយជននៅពេលមានវិវាទសិទ្ធិលើបំណុលកើតឡើង។ ប៉ុន្តែដោយប្រាតិភោគដោយអនុប្បទានទទួលស្គាល់ "ការប្តូរលក្ខណៈនៃការកាន់កាប់" មានន័យថាការកាន់កាប់ចលនវត្ថុដោយប្រយោលជាលក្ខខណ្ឌតតាំងមួយផងដែរ។ ដូច្នេះហើយទើបបង្កឲ្យម្ចាស់សិទ្ធិមានភាពលំបាកក្នុងការតតាំងជាមួយតតិយជន។ ទន្ទឹមនឹងនេះ ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា មាត្រា២២៩ ក៏ទទួលស្គាល់ការផ្ទេរ ការកាន់កាប់ដោយប្រយោល ដែលនេះជាកត្តាគួបផ្សំញ៉ាំងឲ្យលទ្ធភាពនៃហានិភ័យចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមានកម្រិតកាន់តែខ្ពស់។

សារណានេះ នឹងលើកយកករណីប្រឈមនានាយកមកពិចារណា ដូចដែលមានរៀបរាប់ដូចតទៅនេះ៖

- ករណីទី១ តតិយជនជឿជាក់ថា ចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន មិនមានជាប់សិទ្ធិលើបំណុលប្រាតិភោគ ហើយធ្វើការលក់ទិញលើចលនវត្ថុនោះ។
- ករណីទី២ តតិយជនជឿជាក់ថា ចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន មិនមានជាប់សិទ្ធិលើបំណុលប្រាតិភោគ ហើយយកចលនវត្ថុដែលទៅដាក់ធានានឹងម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានថ្មី។
- ករណីទី៣ ជាគោលការណ៍បានចង្អុលបង្ហាញថា កូនបំណុលមានសិទ្ធិលក់ចលនវត្ថុផ្តុំគ្នា ឬមួយផ្នែកដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។ ករណីនេះច្បាប់មិនបានបញ្ជាក់ថាអាចលក់បានត្រឹមផ្នែកណា ឬកម្រិតណានោះទេ។ កង្វះខាតនៃច្បាប់បែបនេះអាចនឹងបង្កហានិភ័យដល់ម្ចាស់បំណុល ប្រសិនបើកូនបំណុលលក់លើសហួសដល់តម្លៃធានាបំណុលប្រាតិភោគដោយអនុប្បទាន ធ្វើឲ្យម្ចាស់បំណុលលែងមានវត្ថុសំអាងក្នុងការធានាសំណងកាតព្វកិច្ចមកខ្លួនវិញ។

ដោយផ្អែកលើចំណោទបញ្ហាដូចដែលបានរៀបរាប់ខាងលើ សារណាមួយនេះនឹងលើកឡើងពីតុល្យភាពនៃការធានាទៅលើសិទ្ធិរវាងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ជាមួយនឹងតតិយជន (អ្នកទិញចលនវត្ថុជាប់ប្រាតិភោគដោយអនុប្បទាន ឬម្ចាស់សិទ្ធិប្រាតិភោគដោយអនុ-ប្បទានលំដាប់ទី២) ពោលគឺដោយយោងលើហេតុផលថាលក្ខខណ្ឌនៃការតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទានទទួលស្គាល់ការផ្ទេរការកាន់កាប់ដោយប្រយោលទើបមិនអាចធានាសុវត្ថិភាពជំនួញបានទេ។

គោលបំណងនៃកិច្ចការស្រាវជ្រាវមួយនេះ មាន៣ចំណុច (ទី១) ចង់ពាំនាំនូវចំណេះដឹងថ្មីស្ដីពីប្រាតិភោគដោយអនុប្បទាន ដល់អ្នកសិក្សាទាំងឡាយដែលតែងមានការភ័ន្តច្រឡំរវាងបទប្បញ្ញត្តិនេះទៅនឹងការបញ្ចាំចលនវត្ថុ (ទី២) យល់ដឹងពីភាពខ្លាំង និងភាពខ្សោយនៃការការពារសិទ្ធិរបស់ម្ចាស់បំណុលតាមរយៈប្រាតិភោគដោយអនុប្បទាន ជាពិសេសនៅប្រទេសកម្ពុជា និង(ទី៣) គឺចង់លើកយកនូវច្បាប់របស់ប្រទេសជប៉ុនអំពីបញ្ញត្តិការពារម្ចាស់បំណុលមកបង្ហាញ។

គួរបញ្ជាក់ផងដែរថា វិសាលភាពនៃខ្លឹមសារសារណានេះ នឹងបង្ហាញត្រឹមតែចំណុចពាក់ព័ន្ធមួយចំនួនទៅនឹងការការពារសិទ្ធិរបស់ម្ចាស់បំណុល កូនបំណុល និងតតិយជនតាមរយៈប្រាតិភោគដោយអនុប្បទាន ដោយយោងតាមច្បាប់នៃប្រទេសទាំងពីរ ព្រមទាំងសៀវភៅឯកសារនានារួមមានជាភាសាខ្មែរផង ជាភាសាជប៉ុនផង។ ការអានច្បាប់ សៀវភៅឯកសារទាំងនេះ បានក្លាយជាវិធីសាស្ត្រក្នុងការរៀបចំចងក្រងសារណានេះឲ្យលេចចេញជារូបរាងឡើង។ មិនត្រឹមតែប៉ុណ្ណោះ ការស្វែងរកឯកសារតាមគេហទំព័រនានា ក៏បានផ្ដល់នូវទិន្នន័យជាក់ច្បាស់ ជាប្រយោជន៍ឲ្យអត្ថន័យរបស់សារណាកាន់តែមានភាពស៊ីចង្វាក់បន្ថែមទៀត។

ដើម្បីឲ្យមានភាពងាយស្រួល ក្នុងការសិក្សាស្វែងយល់ទៅលើប្រធានបទសារណានេះឲ្យកាន់តែមានភាពស៊ីជម្រៅ សារណានេះនឹងបង្ហាញពី **លក្ខណៈដូចគ្នានៃបញ្ញត្តិស្ដីពីប្រាតិភោគដោយអនុប្បទានកម្ពុជា-ជប៉ុន** (ជំពូកទី១) រួមមាន **សុពលភាព និងលក្ខខណ្ឌតតាំងនៃប្រាតិភោគដោយអនុប្បទាន** (ផ្នែកទី១) និង**ប្រាតិភោគដោយអនុប្បទានតាមរយៈការផ្ទេរការកាន់កាប់**។ បន្ទាប់មកទៀតនឹងមានការបកស្រាយពី**លក្ខណៈខុសគ្នានៃបញ្ញត្តិស្ដីពី ប្រាតិភោគដោយអនុប្បទានកម្ពុជា-ជប៉ុន** (ជំពូកទី២) ដែលនឹងរំលេចឲ្យឃើញពី **លក្ខខណ្ឌនៃការទទួលស្គាល់ប្រាតិភោគដោយអនុប្បទានតាមរយៈការផ្ទេរការកាន់កាប់នៅកម្ពុជា** (ផ្នែកទី១) និង**លក្ខខណ្ឌនៃការទទួលស្គាល់ប្រាតិភោគដោយអនុប្បទានតាមរយៈការចុះបញ្ជីនៅជប៉ុន** (ផ្នែកទី២)។

# ជំពូកទី១
# លក្ខណៈដូចគ្នានៃបទប្បញ្ញត្តិ
# ស្តីពីប្រាតិភោគដោយ
# អនុប្បទានកម្ពុជា-ជប៉ុន

# ជំពូកទី១
# លក្ខណៈដូចគ្នានៃបទប្បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទានកម្ពុជា-ជប៉ុន

ជាការពិតណាស់ កម្ពុជាពិតជាបានទទួលជំនួយចងក្រងក្រមរដ្ឋប្បវេណីពីសំណាក់អ្នកជំនាញការនៃប្រទេសជប៉ុន ដែលជាហេតុធ្វើឲ្យមានការជះឥទ្ធិពលនៃគោលគំនិតផ្នែករដ្ឋប្បវេណីមួយផ្នែកធំមកលើក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ មានផ្នែកខ្លះរបស់ក្រមរដ្ឋប្បវេណីកម្ពុជារហូតដល់ទៅបញ្ញត្តិដូចគ្នាសុទ្ធសាធនឹងក្រមរដ្ឋប្បវេណីជប៉ុនទៀតផង។ មិនត្រឹមតែក្រមរដ្ឋ-ប្បវេណីជប៉ុនប៉ុណ្ណោះទេ ដែលបានសាយភាយឥទ្ធិពលមកលើការបង្កើតក្រមរដ្ឋប្បវេណីកម្ពុជាជាក់ស្តែងសូម្បីតែច្បាប់ផ្សេងទៀត ដែលស្ថិតនៅក្នុងវិស័យនីតិឯកជនរបស់ជប៉ុន ក៏បានរួមចំណែកក្នុងការផ្តល់ជាទស្សនាទានដល់នីតិឯកជននៅកម្ពុជាយើងផងដែរ។ យ៉ាងណាមិញ ទោះបីវិសាលភាពនៃច្បាប់ជប៉ុនបានគ្របដណ្តប់ច្រើនមកលើច្បាប់កម្ពុជាក៏ពិតមែន ក៏មិនមានន័យថារាល់ចំណុចទាំងអស់សុទ្ធតែដូចគ្នានោះទេ ពីព្រោះអ្នកច្បាប់នៃប្រទេសទាំងពីរបានពិចារណាទៅលើស្ថានភាពជាក់ស្តែងនៃសណ្ឋានប្រជាសាស្រ្តរបស់ប្រទេសខ្លួន ហើយចងក្រងច្បាប់ឡើងឲ្យត្រូវនឹងសង្គមរបស់ប្រជាជនរៀងៗខ្លួន។

តួយ៉ាង ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ បានទទួលយកនូវគោលគំនិតនៃបទប្បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទានដែលមិនមែនបានមកពីក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនទេ ប៉ុន្តែបានពីច្បាប់ដោយឡែកស្តីពីប្រាតិភោគដោយអនុប្បទានរបស់ប្រទេសជប៉ុនត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៤ ព្រោះថាក្រមរដ្ឋប្បវេណីជប៉ុន មិនបានចែងអំពីប្រាតិភោគដោយអនុប្បទានឡើយ។ ជាគោលការណ៍ទូទៅប្រាតិភោគដោយអនុប្បទាននៅកម្ពុជា មានលក្ខណៈដូចគ្នាច្រើនទៅនឹងប្រាតិភោគដោយអនុប្បទាននៅជប៉ុនកាលពីមុនជប៉ុនបង្កើតច្បាប់ដោយឡែកស្តីពីប្រាតិភោគដោយអនុប្បទាននៅឆ្នាំ២០០៤ ដែលគួរបញ្ជាក់ផងដែរថា មុនឆ្នាំបង្កើតច្បាប់នេះជប៉ុនបានអនុវត្តន៍ ព្រមទាំងដោះស្រាយវិវាទពាក់ព័ន្ធទៅនឹងបញ្ហាប្រាតិភោគដោយអនុប្បទាន ដោយយោងតាមយុត្តិសាស្រ្តរបស់តុលាការ។ នេះសបញ្ជាក់ឲ្យឃើញថាមានចំណុចមួយចំនួន ដែលកម្ពុជាមិនអាចចងក្រងបញ្ញត្តិឲ្យដូចទៅនឹងច្បាប់ជប៉ុន អាស្រ័យដោយស្ថានភាពជាក់ស្តែងរបស់ប្រទេសយើង។ ចំណុចបន្តទៅនេះ នឹងលើកឡើងតែពីភាពដូចគ្នារវាង ប្រាតិភោគដោយអនុប្បទានរវាងប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន និងប្រាតិភោគដោយអនុប្បទានរបស់ប្រទេសជប៉ុនកាលពីមុនពេលបង្កើតច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទានឆ្នាំ២០០៤។

## ផ្នែកទី១ សុពលភាព និងលក្ខខណ្ឌតតាំងនៃប្រាតិភោគដោយអនុប្បទាន

អនុលោមតាមមាត្រា៨៨៨ ត្រង់កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជា បានឲ្យនិយមន័យនៃប្រាតិភោគដោយអនុប្បទានថា "ជាការណ៍ដែលកូនបំណុល ឬតតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅឲ្យម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ច។ ក្នុងករណីនេះ បើកាតព្វកិច្ចត្រូវបានសងរួចហើយកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុត្រូវផ្ទេរទៅអ្នកបង្កើត"[3]។ ផ្ទុយទៅវិញ បើកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ដោយផ្ទាល់ខ្លួន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរបាន ដោយជូនដំណឹងទៅកូនបំណុល[4]។ ទន្ទឹមនឹងនេះ ប្រាតិភោគដោយអនុប្បទាន ក៏អាចបង្កើតលើចលនវត្ថុផ្តុំគ្នាបានដែរ។ នេះមានន័យថា ជាការយកចលនវត្ថុច្រើនរួមគ្នារបស់កូនបំណុលដើម្បីធ្វើការធានាលើបំណុលតែមួយជាមួយម្ចាស់បំណុល។

ចំពោះការទទួលយកចលនវត្ថុផ្តុំគ្នា ដើម្បីបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននេះមានការចង្អុលបង្ហាញយ៉ាងច្បាស់ថា ចលនវត្ថុនេះគឺអាចនឹងត្រូវបានកំណត់ទំហំតាមមាត្រដ្ឋានដូចជាប្រភេទ ឬទីកន្លែងស្ថិតនៅរបស់ចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន។ ទោះចលនវត្ថុផ្តុំគ្នានេះ អាចនឹងមានការប្រែប្រួល ក៏នៅតែអាចយកមកធ្វើអនុប្បទានទៅឲ្យម្ចាស់បំណុលបានដែរ។ ត្រង់ចំណុចនេះ អាចនឹងត្រូវបានពិចារណានៅត្រង់ចំណុចជាបន្តបន្ទាប់ទៀត ដោយហេតុថាការបញ្ញត្តិបែបនេះអាចនឹងបណ្តាលឲ្យចោទជាបញ្ហាឡើង។

ខ្លឹមសារនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន មានទម្រង់ជាការផ្ទេរកម្មសិទ្ធិលើចលនវត្ថុដោយបណ្តោះអាសន្នទៅឲ្យម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន។ កម្មសិទ្ធិនៃវត្ថុដែលជាកម្មវត្ថុនឹងត្រូវធ្វើអនុប្បទានត្រឡប់មកវិញ នៅពេលដែលអ្នកបង្កើត (កូនបំណុល) បានអនុវត្តកាតព្វកិច្ចរួចហើយ។ ផ្ទុយទៅវិញ ការទទួលបាននូវកម្មសិទ្ធិជាបណ្តោះអាសន្នរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានក្នុងអំឡុងពេលអត្ថិភាពនោះនឹងក្លាយទៅជាស្ថាពរ ឬត្រូវបានចាត់ចែងប្តូរជាប្រាក់ប្រសិនបើកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនពេលដល់កំណត់នៃការសង។

ប្រសិនបើមិនទាន់បានសិក្សាឲ្យបានច្បាស់លាស់ទេ អ្នកសិក្សាមួយចំនួនអាចនឹងមានការភ័ន្តច្រឡំរវាង**«ការបញ្ចាំចលនវត្ថុ»** និង**«ប្រាតិភោគដោយអនុប្បទាន»** ដោយហេតុថាបញ្ញត្តិទាំង២នេះមានលក្ខណៈស្រដៀងគ្នា អនុវត្តន៍ចំពោះចលនវត្ថុដូចគ្នាក្នុងការធានាលើបំណុល។ ចំណុចដូច

[3] អ្នកបង្កើត សំដៅលើកូនបំណុល ឬតតិយជន

[4] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៨៩៨ កថាខណ្ឌទី១

នោះស្ថិតនៅត្រង់ថា សិទ្ធិទាំងពីរប្រភេទសុទ្ធតែជាប្រភេទសិទ្ធិប្រាតិភោគប្រត្យក្ស ដែលនៅពេលបង្កើតសិទ្ធិលើបំណុល ទាមទារឲ្យមានការដាក់ចលនវត្ថុដើម្បីធានាការសងកាតព្វកិច្ចទៅកាន់ម្ចាស់ដើមវិញ។ យ៉ាងណាមិញ ក៏មានចំណុចសំខាន់ៗមួយចំនួនខុសគ្នាដែរ។ នៅក្នុងករណីនៃការបញ្ចាំចលនវត្ថុ [5] គឺមានការហាមឃាត់ចំពោះកូនបំណុល ក្នុងការកាន់កាប់ចលនវត្ថុបញ្ចាំដោយផ្ទាល់ (មាត្រា៨១៩នៃក្រមរដ្ឋប្បវេណីកម្ពុជា)។ មានន័យថា កូនបំណុលត្រូវប្រគល់វត្ថុបញ្ចាំទៅឲ្យម្ចាស់បំណុល ឬម្ចាស់សិទ្ធិលើការបញ្ចាំដើម្បីរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ។

ផ្ទុយទៅវិញ តាមរយៈប្រាតិភោគដោយអនុប្បទាន ភាពដាច់ខាតនៃការប្រគល់ចលនវត្ថុទៅឲ្យម្ចាស់បំណុលកាន់កាប់ដោយផ្ទាល់មិនមែនជាលក្ខខណ្ឌចាំបាច់នោះទេ។ ហេតុផលនេះមានចែងបញ្ជាក់យ៉ាងច្បាស់នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ត្រង់មាត្រា៨៩០ ស្តីពីលក្ខខណ្ឌនៃការតតាំងថា "ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយយោងតាមបញ្ញត្តិនៃមាត្រា២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះទេ"។ ជាទូទៅវិធីសាស្ត្រនៃការផ្ទេរការកាន់កាប់អាចជាវិធីសាស្ត្រដោយផ្ទាល់ និងអាចជាវិធីសាស្ត្រផ្ទេរការកាន់កាប់ដោយប្រយោល។ ត្រង់ចំណុចនេះប្រាតិភោគដោយអនុប្បទានមិនបានហាមឃាត់មិនឲ្យប្រើប្រាស់វិធីសាស្ត្រផ្ទេរការកាន់កាប់ដោយប្រយោលនោះទេ ពោលគឺកូនបំណុលដែលបានយកចលនវត្ថុទៅដាក់ធានាប្រាតិភោគដោយអនុប្បទាន នៅតែមានលទ្ធភាពក្នុងការកាន់កាប់ដោយផ្ទាល់លើចលនវត្ថុដែលជាកម្មវត្ថុនៃបំណុលដដែលឲ្យតែមានការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និងកូនបំណុល។

ការបែងចែករវាង**សិទ្ធិប្រាតិភោគដោយអនុប្បទាន** និង**សិទ្ធិលើការបញ្ចាំ**នេះមានលក្ខណៈដូចគ្នារវាងបទប្បញ្ញត្តិកម្ពុជា និងជប៉ុន។ ឆ្លងតាមការអនុវត្តកន្លងមក គេសង្កេតឃើញថាតាមរយៈការបញ្ចាំចលនវត្ថុមិនបានផ្តល់នូវភាពងាយស្រួលសម្រាប់កូនបំណុលនោះទេ ព្រោះកូនបំណុលមិនអាចបន្តប្រើប្រាស់ចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់ខ្លួនបានក្នុងអំឡុងពេលជាប់ធានាបំណុល។ ប្រសិនបើករណីដែលកូនបំណុលអាចរកចំណូល បានតាមរយៈការប្រើប្រាស់នូវចលនវត្ថុនោះ ហេតុនេះការអនុវត្តទៅតាមបញ្ញត្តិនេះ មិនធ្វើឲ្យមានការប៉ះពាល់ដល់ការរកចំណូលរបស់កូនបំណុលទេឬយ៉ាងណា? ប្រាតិភោគដោយគ្មានការផ្ទេរការកាន់កាប់ដោយផ្ទាល់គឺមានសារៈប្រយោ-

[5] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៨២៩ ដល់មាត្រា៨៣៣

ជន៍ចំពោះកូនបំណុល នៅក្នុងករណីដែលកូនបំណុលទទួលផលប្រយោជន៍ពីវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ[6]។

ជាឧទាហរណ៍ដើម្បីឲ្យមានភាពងាយស្រួលក្នុងការយល់ទៅលើបរិបទនេះ ក្នុងករណីដែលកូនបំណុលជាជាងថតរូប ហើយគាត់បានយកម៉ាស៊ីនថតរូប(ចលនវត្ថុ) ទៅដាក់ប្រាតិភោគដោយអនុប្បទានដើម្បីធានាបំណុលរបស់គាត់។ ប្រសិនបើកូនបំណុលអាចបន្តប្រើប្រាស់ម៉ាស៊ីនថតនោះបាន កូនបំណុលអាចនឹងមានលទ្ធភាពក្នុងការរកចំណូលបាន តាមរយៈការប្រើប្រាស់ម៉ាស៊ីនថតរូបនោះ ព្រមទាំងមានលទ្ធភាពប្រសើរជាងក្នុងការសងបំណុលត្រឡប់ទៅម្ចាស់បំណុលវិញជាជាងការយកចលនវត្ថុរបស់ខ្លួនទៅទុកបញ្ចាំចោលមិនអាចប្រើប្រាស់បានជាមួយនឹងម្ចាស់បំណុល។

ដោយផ្អែកលើហេតុផលដូចដែលបានរៀបរាប់ខាងលើនេះ នៅប្រទេសជប៉ុនមានការអនុវត្តប្រាតិភោគដោយអនុប្បទានជាច្រើន តាំងពីមុនប្រទេសជប៉ុនបង្កើត**«ច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទាន»**[7] មកម្ល៉េះ ដែលការអនុវត្តមានការទទួលស្គាល់ដោយតុលាការនៃប្រទេសជប៉ុនទៀតផង។ ជាការគួរឲ្យកត់សម្គាល់ បើទោះបីជាមានការប្រើប្រាស់វិធីសាស្ត្រនេះក៏ដោយក្រមរដ្ឋប្បវេណីជប៉ុនមិនបានបញ្ញត្តិអំពីសិទ្ធិប្រាតិភោគដោយអនុប្បទាននេះទេ។ ផ្ទុយទៅវិញ ក្រមរដ្ឋប្បវេណីកម្ពុជា ដែលទទួលបានជំនួយបច្ចេកទេសពីអ្នកជំនាញការជប៉ុន បែរជាមានបទប្បញ្ញត្តិប្រាតិភោគដោយអនុប្បទាននេះទៅវិញ។ ហេតុផលនៃការមិនបានបញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាននៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន ព្រោះថាតាំងពីបង្កើតក្រមរដ្ឋប្បវេណីឆ្នាំ១៨៩៦ (民法、Minpō ) ដែលជប៉ុនបានទទួលឥទ្ធិពលគោលគំនិតច្បាប់ពីក្រមរដ្ឋប្បវេណីប្រទេសអាឡឺម៉ង់ និងបារាំងមកអ្នកច្បាប់ជប៉ុនក៏មិនបានគិតដល់ប្រាតិភោគដោយអនុប្បទាននេះទេ។ វិវាទប្រាតិភោគដោយអនុប្បទានចេះតែកើតឡើងជាបន្តបន្ទាប់ រហូតដល់តុលាការជប៉ុនមានដំណោះស្រាយចេញជាយុត្តិសាស្ត្រអនុវត្តន៍ជាបន្តបន្ទាប់មក ទើបជប៉ុនសម្រេចចងក្រងជាបញ្ញត្តិប្រាតិភោគដោយអនុប្បទាននេះឡើង។ យ៉ាងណាមិញ ក្រមរដ្ឋប្បវេណីកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៧ ខណៈពេលដែលច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទានជប៉ុនបង្កើតឡើងនៅឆ្នាំ២០០៤។ ពិចារណាលើករណីនេះ យើងអាចយល់បានថា អ្នកជំនាញការជប៉ុនដែលបានជួយផ្តល់គំនិតនៅពេលបង្កើតក្រម

[6] សមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម, *ក្រមរដ្ឋប្បវេណីភាគ៥*, បោះពុម្ពខែមីនា ឆ្នាំ២០១២

[7] ច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងឆ្នាំ២០០៤ ដោយនាំយកនូវប្រព័ន្ធចុះបញ្ជីចលនវត្ថុមកអនុវត្ត

រដ្ឋប្បវេណីកម្ពុជាគួរតែបានបញ្ចូលមតិយោបល់ជម្រុញឲ្យមានការរួមបញ្ចូលបទបញ្ញត្តិនេះទៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាតែម្តង។

### កថាខណ្ឌទី១ ការបង្កើត

ប្រាតិភោគដោយអនុប្បទាន គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្សទាំង៥ [8] ។ ពាក្យថា «ប្រាតិភោគ» បានសេចក្តីថាការធានាដល់ម្ចាស់បំណុលក្នុងប្រមូលឥណទេយ្យរបស់ខ្លួនមកវិញ ឬជាមធ្យោបាយមួយធានាដល់ការសងកាតព្វកិច្ច[9]។ ជាសម្រាយត្រួសៗប្រាតិភោគដោយអនុប្បទាន គឺជាការដាក់អនុប្បទានជាចលនវត្ថុដើម្បីធ្វើការធានាក្នុងការសងកាតព្វកិច្ចរបស់កូនបំណុលចំពោះម្ចាស់បំណុលវិញ។ តាមរយៈការស្រាវជ្រាវទៅលើគេហទំព័ររបស់គ្រឹះស្ថាន ឬភ្នាក់ងារប្រាតិភោគដោយអនុប្បទានភាគច្រើន ចលនវត្ថុដែលទទួលយកសម្រាប់ធ្វើជាកម្មវត្ថុនៃការធានារួមមានយានយន្ត (រថយន្ត ទោចក្រយានយន្ត) គ្រឿងអេឡិចត្រូនិច គ្រឿងអលង្ការជាដើម។

#### ក- រចនាសម្ព័ន្ធនៃការបង្កើត

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជនដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។ មិនខុសពីកិច្ចសន្យា[10]ដទៃ បើគូភាគីយល់ព្រមជាមួយគ្នា នោះនឹងមានការបង្កើតចំណងគតិយុត្តឡើងដោយកូនបំណុលធ្វើអនុប្បទាន (ផ្ទេរដោយផ្ទាល់ ឬមិនផ្ទាល់) ទៅម្ចាស់បំណុលនូវចលនវត្ថុដែលជាកម្មវត្ថុជាការធានាចំពោះការខ្ចីប្រាក់។

យ៉ាងណាមិញនៅប្រទេសជប៉ុន ការបង្កើតប្រាតិភោគដោយអនុប្បទាន ត្រូវបានបែងចែកជាពីរប្រភេទគឺ ការបង្កើតតាមរយៈសិទ្ធិលើកម្មសិទ្ធិ និងការបង្កើតតាមរយៈការធានា។ ជាគោលការណ៍ទូទៅ «ការបង្កើតប្រាតិភោគដោយអនុប្បទានតាមរយៈសិទ្ធិលើកម្មសិទ្ធិ» ត្រូវបានគេយល់ឃើញថានៅពេលបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន សិទ្ធិលើកម្មសិទ្ធិនឹងត្រូវបានផ្ទេរទាំងស្រុងទៅឲ្យម្ចាស់បំណុលក្នុងការធានាបំណុល។ ផ្ទុយទៅវិញ «ការបង្កើតប្រាតិភោគដោយអនុ

[8] សិទ្ធិប្រាតិភោគប្រត្យក្សរួមមាន៖ សិទ្ធិឃាត់ទុក, ឯកសិទ្ធិ, សិទ្ធិលើការបញ្ចាំ, ហ៊ីប៉ូតែក និងសិទ្ធិប្រាតិភោគដោយអនុប្បទាន (ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា៧៦៧ កថាខណ្ឌទី២)

[9] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី លេខរៀង១០១

[10] មាត្រា៣៣៦-១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ការបង្កើតកិច្ចសន្យាដោយសំណើ និងស្ទីការ «កិច្ចសន្យាមានអានុភាពដោយសារសំណើ និងស្ទីការត្រូវគ្នា»

ប្បទានតាមរយៈការធានា» គឺមិនចាំបាច់មានការផ្ទេរសិទ្ធិកម្មសិទ្ធិទេ។ ភ្ជាប់ជាមួយគ្នានេះងាកមកខាងក្រមរដ្ឋប្បវេណីកម្ពុជាវិញ មាត្រា៨៨៨ កថាខណ្ឌទី១ នៅពេលដែលបង្កើតប្រាតិភោគដោយអនុប្បទាន កូនបំណុល ឬតតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ឲ្យទៅម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ច។ ប្រសិនបើ កាតព្វកិច្ចត្រូវបានសងរួចហើយ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុត្រូវផ្ទេរទៅអ្នកបង្កើតវិញ។ នេះមានន័យថា នៅពេលបង្កើតប្រាតិភោគដោយអនុប្បទាននៅកម្ពុជាក៏មានការផ្ទេរកម្មសិទ្ធិរវាងភាគីនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទានដែរ។ ជារួមបើធៀបទៅនឹងប្រទេសជប៉ុន ប្រាតិភោគដោយអនុប្បទានតាមក្រមរដ្ឋប្បវេណីកម្ពុជា គឺ «ត្រូវបានបង្កើតឡើងតាមរយៈសិទ្ធិលើកម្មសិទ្ធិ»។

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងតាមការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬជាមួយតតិយជនដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។ ដូច្នេះ ដើម្បីឲ្យការព្រមព្រៀងមានអានុភាពតាមផ្លូវច្បាប់ ល្គឹកណាតែមានការគោរពតាមលក្ខខណ្ឌគ្រឹះនៃកិច្ចសន្យា៖

- ការព្រមព្រៀងធ្វើឡើងដោយគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ
- ភាគីនៃការបង្ហាញឆន្ទៈត្រូវតែជាប្រភេទជនដែលមានសមត្ថភាពតាមផ្លូវច្បាប់
- កម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានត្រូវតែជាចលនវត្ថុដែលមានតម្លៃស្របច្បាប់ក្នុងសកម្មភាពពាណិជ្ជកម្ម ហើយជាវត្ថុដែលអាចធ្វើអនុប្បទានបាន អាចជាចលនវត្ថុតែមួយ ឬជាចលនវត្ថុច្រើនជាងមួយ។

### ខ- អានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ជាទូទៅការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សរមែងតែងមានការដាក់ធានា ក្រោមរូបភាពណាមួយដើម្បីជាកត្តាជម្រុញឲ្យកូនបំណុលសងកាតព្វកិច្ចរបស់ខ្លួនចំពោះម្ចាស់បំណុលវិញ។ ក្នុងករណីជាក់ស្តែង យើងមិនអាចអះអាងបានទេថាកូនបំណុលជំពាក់បំណុលម្ចាស់តែមួយ ពោលគឺអាចមានម្ចាស់បំណុលច្រើនអាស្រ័យលើស្ថានភាពសេដ្ឋកិច្ចជាក់ស្តែងផ្ទាល់ខ្លួនរបស់កូនបំណុល។ ការជាប់ជំពាក់ជំពិននឹងម្ចាស់បំណុលច្រើនក្នុងអំឡុងពេលតែមួយនេះ អាចជាការបង្កើតសិទ្ធិលើបំណុលនានាក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្សទាំង៥ (ឯកសិទ្ធិ សិទ្ធិឃាត់ទុក សិទ្ធិលើការបញ្ចាំ សិទ្ធិប្រាតិភោគដោយអនុប្បទាន និងហ៊ីប៉ូតែក)។ ហេតុនេះ តើម្ចាស់បំណុលនីមួយៗ ឬនៅត្រង់ចំណុច

នេះយើងសង្កត់ធ្ងន់ទៅលើម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន អាចនឹងមានសិទ្ធិតតាំងបែបណាចំពោះម្ចាស់បំណុលដទៃ កូនបំណុល ឬតតិយជនបាន?

### ខ-១- ការផ្ទេរការកាន់កាប់

ការផ្ទេរការកាន់កាប់ ទាំងក្រមរដ្ឋប្បវេណីកម្ពុជា[11] ទាំងក្រមរដ្ឋប្បវេណីជប៉ុន[12] បានទទួលស្គាល់ប្រភេទនៃការផ្ទេរការកាន់កាប់រួមមាន៤ប្រភេទដូចជា (១) ការប្រគល់ដោយជាក់ស្តែង (២) ការប្តូរលក្ខណៈនៃការកាន់កាប់ (៣) ការប្រគល់ដោយសង្ខេប និង(៤) ការផ្ទេរការកាន់កាប់ដោយបញ្ជា។ គួរបញ្ជាក់ថាវិធីសាស្ត្រនៃការបែងចែកនេះ គឺកម្ពុជា និងជប៉ុន មានលក្ខណៈដូចគ្នាទាំងស្រុង។

- **ការប្រគល់ដោយជាក់ស្តែង**

នៅត្រង់មាត្រា២២៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជា និងមាត្រា១៨២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីជប៉ុនបានចែងបញ្ជាក់ថា «ការប្រគល់ដោយជាក់ស្តែង» គឺជាការប្រគល់ដោយផ្ទាល់ដៃពីអ្នកកាន់កាប់ទៅអ្នកទទួលការកាន់កាប់តាមការជាក់ស្តែង។

ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់បានព្រមព្រៀងលក់រថយន្តឲ្យអ្នកទិញក្នុងតម្លៃ៥ម៉ឺនដុល្លារអាមេរិក។ កិច្ចសន្យានេះ បានចងភ្ជាប់កាតព្វកិច្ចឲ្យអ្នកលក់ធ្វើការប្រគល់ដោយជាក់ស្តែងនូវរថយន្តនោះ ទើបអ្នកទិញប្រគល់លុយឲ្យ។ ការប្រគល់បែបនេះ ហៅថា «ការប្រគល់ដោយជាក់ស្តែង» ពោលគឺមានការផ្ទេរការកាន់កាប់ (ផ្ទេរកម្មសិទ្ធិ)លើរថយន្ត ពីអ្នកលក់មកឲ្យអ្នកទិញវិញ។

- **ការប្តូរលក្ខណៈនៃការកាន់កាប់**

ចំណុចនេះ មានចែងនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាមាត្រា២២៩ កថាខណ្ឌទី២ និងក្រមរដ្ឋ-ប្បវេណីជប៉ុនមាត្រា១៨៣។ «ការប្តូរលក្ខណៈនៃការកាន់កាប់»នេះ ពុំមានការប្រគល់ជាក់ស្តែងនូវវត្ថុទេ គ្រាន់តែមានការព្រមព្រៀងគ្នា ហើយហៅថាជាការប្រគល់ដោយប្រយោល គឺជាលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការផ្ទេរការកាន់កាប់។ មានន័យថា ម្ចាស់បំណុល និងកូនបំណុលគ្រាន់តែឆ្លើយព្រមព្រៀងគ្នា ទាំងមិនបានប្រគល់វត្ថុជាក់ស្តែងទៅឲ្យម្ចាស់បំណុលផងនោះ។

ឧទាហរណ៍៖ ក្នុងករណីលក់ទិញដដែល ទោះបីជាវត្ថុត្រូវបានលក់ជាស្ថាពរហើយក្តី ប្រសិនបើអ្នកលក់ និងអ្នកទិញព្រមព្រៀងគ្នា រក្សាវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនោះនឹងអ្នកលក់ (មាន

[11] មាត្រា២២៩ ការផ្ទេរការកាន់កាប់

[12] មាត្រា១៨២, មាត្រា១៨៣ និងមាត្រា១៨៤

ន័យថាអ្នកលក់បន្តការកាន់កាប់ដោយផ្ទាល់លើវត្ថុ) ក៏ហៅថាជាការផ្ទេរការកាន់កាប់ដែរ គ្រាន់តែជាការប្តូរលក្ខណៈនៃការកាន់កាប់តាមការព្រមព្រៀង ពោលគឺបានប្រគល់ឲ្យដោយប្រយោល។

➢ **ការប្រគល់ដោយសង្ខេប**

«ការប្រគល់ដោយសង្ខេប» មានចែងនៅត្រង់ក្រមរដ្ឋប្បវេណីកម្ពុជាមាត្រា២២៩ កថាខណ្ឌទី៣ និងក្រមរដ្ឋប្បវេណីជប៉ុនមាត្រា១៨២ កថាខណ្ឌទី២។ តាមរយៈការប្រគល់បែបនេះមិនមានការប្រគល់ដោយជាក់ស្តែងកើតឡើងទេ ព្រោះថាវត្ថុដែលជាកម្មវត្ថុនៃការផ្ទេរបានស្ថិតនៅក្នុងការកាន់កាប់របស់អ្នកទទួលការកាន់កាប់រួចជាស្រេចទៅហើយ គ្រាន់តែមិនទាន់មានការផ្ទេរកម្មសិទ្ធិបានត្រឹមត្រូវ។ ហេតុនេះ នៅពេលមានការបង្កើតសិទ្ធិប្រត្យក្ស ម្ចាស់បំណុលមានតែឈ្មោះថាបានផ្ទេរការកាន់កាប់ទៅឲ្យកូនបំណុល ទាំងមិនបានប្រគល់វត្ថុដោយជាក់ស្តែង។

ឧទាហរណ៍៖ បើនិយាយពីកិច្ចសន្យាលក់ ទិញ អ្នកទិញបានបន្តកាន់កាប់ដោយផ្ទាល់ទៅលើវត្ថុរួចជាស្រេចទៅហើយ គ្រាន់តែមិនទាន់មានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើវត្ថុនោះ។ លុះមានការលក់ទិញកើតឡើង អ្នកទិញផ្ទេរកម្មសិទ្ធិតែម្តងទៅលើវត្ថុនោះ ដោយមិនបានឆ្លងកាត់ការប្រគល់វត្ថុពីសំណាក់អ្នកលក់នោះទេ។ ដើម្បីឲ្យកាន់តែងាយយល់ តួយ៉ាងលោក **ក** កំពុងកាន់កាប់ផ្ទាល់លើម៉ូតូរបស់លោក **ខ** ខណៈពេលដែលម៉ូតូមិនមែនជាកម្មសិទ្ធិរបស់ខ្លួនសោះឡើយ។ ក្រោយមកលោក **ក** បានទិញម៉ូតូពីលោក **ខ** ដូចនេះលោក **ខ** បានផ្ទេរកម្មសិទ្ធិលើម៉ូតូឲ្យលោក **ក** ដោយមិនមានការប្រគល់វត្ថុកើតឡើងឡើយ ព្រោះតែម៉ូតូនេះកំពុងត្រូវបានកាន់កាប់ផ្ទាល់ដោយលោក **ក** ជាស្រេច។

គួរបញ្ជាក់ថា នៅក្នុងឧទាហរណ៍ខាងលើនេះ អាចមាន២ករណី។ ទី១ លោក **ក** បានកាន់កាប់លើម៉ូតូ ហើយអាចប្រើប្រាស់ម៉ូតូបានតាំងពីមុនពេលមានការលក់ទិញ ផ្ទេរម្ចាស់កម្មសិទ្ធិទៅទៀត។ ទី២ លោក **ក** បានកាន់កាប់ម៉ូតូមុននឹងគាត់បានទិញក៏ពិតមែន ប៉ុន្តែមិនទាន់បានប្រើប្រាស់លុះដល់មានការលក់ទិញ ផ្ទេរកម្មសិទ្ធិជាស្ថាពរ ទើបលោក **ក** ទទួលបាននូវកូនសោរម៉ូតូ ហើយអាចប្រើប្រាស់ម៉ូតូបានក្នុងនាមជាម្ចាស់កម្មសិទ្ធិ។

➢ **ការផ្ទេរការកាន់កាប់ដោយបញ្ជា**

លក្ខណៈដូចគ្នានៃប្រភេទនៃការកាន់កាប់ទី៤ រវាងបទប្បញ្ញត្តិកម្ពុជា មាត្រា២២៩ កថាខណ្ឌទី៤ និងជប៉ុន មាត្រា១៨៤ គឺ«ការផ្ទេរការកាន់កាប់ដោយបញ្ជា»។

នៅក្នុងទម្រង់នៃការប្រគល់មួយនេះ ការប្រគល់គឺមិនត្រូវបានធ្វើឡើងតាមការជាក់ស្តែងនោះទេ។ នៅក្នុងស្ថានភាពនេះ អ្នកប្រគល់បានកាន់កាប់ដោយប្រយោលតាមរយៈអ្នកកាន់កាប់

ម្នាក់ទៀត (តតិយជន) អ្នកប្រគល់អាចផ្ទេរការកាន់កាប់ដោយប្រយោល តាមរយៈការព្រមព្រៀងរវាងអ្នកប្រគល់ និងអ្នកទទួលការប្រគល់ ព្រមទាំងជូនដំណឹងអំពីការផ្ទេរនេះ ទៅតតិយជនដែលកំពុងកាន់កាប់ដោយផ្ទាល់ចំពោះវត្ថុនោះ ដើម្បីឲ្យតតិយជននោះអាចប្រគល់វត្ថុនោះបាន។

ឧទាហរណ៍៖ កិច្ចសន្យាលក់ទិញរថយន្តមួយ ដែលប្រើប្រាស់វិធីសាស្ត្រការផ្ទេរការកាន់កាប់ដោយបញ្ជា គឺស្ថិតនៅក្នុងស្ថានភាពមួយដែលអ្នកលក់ជាម្ចាស់លើរថយន្ត បានឲ្យតតិយជនណាម្នាក់ (អាចជាញាតិ ឬជាអ្នកពាក់ព័ន្ធដទៃទៀត) ជួយកាន់កាប់មើលថែរក្សារថយន្តរបស់ខ្លួនជាបណ្ដោះអាសន្ន។ ក្រោយមកគាត់ក៏សម្រេចចិត្តលក់រថយន្តនោះ ខណៈពេលដែលគាត់មិនបានកាន់កាប់រថយន្តនៅក្នុងដៃផងនោះ គាត់អាចព្រមព្រៀងជាមួយនឹងអ្នកទិញថានឹងមានការប្រគល់ដោយបញ្ជានូវរថយន្តទៅឲ្យអ្នកទិញ។ អ្នកលក់បានជូនដំណឹងទៅកាន់តតិយជនកាន់កាប់រថយន្តដោយផ្ទាល់ ឲ្យធ្វើការប្រគល់រថយន្តជាក់ស្ដែងទៅឲ្យអ្នកទិញ។ នេះហើយ ដែលហៅថាជា «ការផ្ទេរកាន់កាប់ដោយបញ្ជា»។

សូមមើលតារាងសង្ខេបអំពីវិធីសាស្ត្រនៃការផ្ទេរការកាន់កាប់

| **ប្រភេទនៃការផ្ទេរការកាន់កាប់** | **លក្ខខណ្ឌ** | **មុនការផ្ទេរ** | **ក្រោយការផ្ទេរ** |
|---|---|---|---|
| *ការប្រគល់ដោយជាក់ស្ដែង* | • ឆន្ទៈព្រមព្រៀងផ្ទេរការកាន់កាប់<br>• ការផ្ទេរការកាន់កាប់ដោយផ្ទាល់ | អនុប្បទាយី អនុប្បទានិក | អនុប្បទាយី អនុប្បទានិក |
| *ការប្តូរលក្ខណៈនៃការកាន់កាប់* | គូភាគីទាំងពីរគ្រាន់តែបង្ហាញឆន្ទៈក្នុងការផ្ទេរការកាន់កាប់ | អនុប្បទាយី អនុប្បទានិក | អនុប្បទាយី អនុប្បទានិក |
| *ការប្រគល់ដោយសង្ខេប* | អនុប្បទានិកកាន់កាប់រួចជាស្រេច | អនុប្បទាយី អនុប្បទានិក | អនុប្បទាយី អនុប្បទានិក |
| *ការផ្ទេរការកាន់កាប់ដោយបញ្ជា* | ឆន្ទៈព្រមព្រៀងផ្ទេរឲ្យតតិយជនណាម្នាក់កាន់កាប់ | អនុប្បទាយី អនុប្បទានិក<br>តតិយជនទទួលបញ្ជាឲ្យកាន់កាប់ | អនុប្បទាយី អនុប្បទានិក<br>តតិយជនទទួលបញ្ជាឲ្យកាន់កាប់ |

**សម្គាល់៖** សញ្ញា ⬭ មានន័យថាជាភាគីដែលកាន់កាប់ដោយផ្ទាល់ (ចំពោះ) ទៅលើវត្ថុ។

រួមសេចក្តីមក ទាំងបញ្ញត្តិកម្ពុជា (មាត្រា២២៩) ទាំងបញ្ញត្តិជប៉ុន(មាត្រា១៨៣ និងមាត្រា១៨៤) សុទ្ធសឹងតែបែងចែកប្រភេទនៃការផ្ទេរការកាន់កាប់ជា៤ប្រភេទ ដែលក្នុងនោះមានការផ្ទេរការកាន់កាប់ដោយផ្ទាល់ (ការប្រគល់ជាក់ស្តែង) និងការផ្ទេរការកាន់កាប់ដោយប្រយោល (ការប្តូរលក្ខណៈនៃការកាន់កាប់ ការប្រគល់ដោយសង្ខេប និងការប្រគល់ដោយបញ្ជា)។ ការវែកញែកឲ្យច្បាស់ពីប្រភេទនៃការកាន់កាប់នេះ នឹងបានជាប្រយោជន៍ ដល់ការបកស្រាយខាងមុខបន្តទៀតអំពីលក្ខខណ្ឌតតាំងចំពោះប្រាតិភោគដោយអនុប្បទាននៅប្រទេសកម្ពុជា។

**ខ-២- ការកម្រិតអានុភាពតតាំង**

នៅក្នុងបទប្បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ ក្នុងករណីដែលមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុដាក់ប្រាតិភោគ។

ឆ្លើយតបទៅនឹងវិធីនៃការផ្ទេរការកាន់កាប់ទាំង៤ ប្រសិនបើមិនមានវិធីសាស្ត្រណាមួយត្រូវបានប្រើប្រាស់នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានទេ វាពិបាកនឹងឲ្យម្ចាស់បំណុលមានលទ្ធភាពទៅតតាំងជាមួយនឹងអ្នកមានសិទ្ធិដទៃទៀតណាស់។ តួយ៉ាង ករណីមានម្ចាស់បំណុលថ្មីបានបង្កើតសិទ្ធិលើបំណុលជាមួយនឹងកូនបំណុលរបស់ខ្លួនដែលជាជនតែមួយ ខណៈពេលដែលម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន មិនបានទទួលសិទ្ធិផ្ទេរការកាន់កាប់ស្របតាមមាត្រា២២៩នៃក្រមរដ្ឋប្បវេណីកម្ពុជាទេ ម្ចាស់បំណុលមានសិទ្ធិត្រឹមទាមទារឲ្យកូនបំណុលសងត្រឡប់មកវិញនូវបំណុលរបស់ខ្លួន ហើយកូនបំណុលនឹងសងនៅពេលក្រោយពីសងម្ចាស់បំណុលដទៃសិនក៏ថាបាន ព្រោះម្ចាស់បំណុលដទៃមានមូលដ្ឋានគ្រឹះតតាំងរឹងមាំជាងក្នុងបញ្ហាតតាំងសិទ្ធិឲ្យសងបំណុលនេះ។ កិច្ចការស្រាវជ្រាវមួយនេះ នឹងបង្ហាញថាការការពារសិទ្ធិនៃម្ចាស់បំណុលប្រាតិ-ភោគដោយអនុប្បទានតាមវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រទាំង៤នេះ មានលក្ខណៈគ្រប់ជ្រុងជ្រោយហើយឬនៅ? យ៉ាងណាមិញ មានទស្សនៈលើកឡើងថា ទោះអនុវត្តតាមមាត្រា២២៩នៃក្រមរដ្ឋប្បវេណីកម្ពុជា (ការផ្ទេរការកាន់កាប់) ក៏ហានិភ័យនៅតែមានលទ្ធភាពកើតឡើងខ្ពស់ចំពោះម្ចាស់បំណុលដែរ។

ដើម្បីរំលេចឲ្យឃើញកាន់តែច្បាស់ពីបញ្ហាដូចដែលបានរៀបរាប់មកនេះ ឧទាហរណ៍ថា លោក «ក» ជាម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន មិនបានទទួលការផ្ទេរការកាន់កាប់រថយន្តរបស់កូនបំណុល «ខ» នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានទេ បើទោះបីជាកូនបំណុល

«ខ» បានអះអាងរួចមកហើយថាយករថយន្តនោះដាក់ប្រាតិភោគ ដើម្បីធានាបំណុល៣ម៉ឺនដុល្លារ។ ក្រោយមក កូនបំណុល «ខ» មិនអើពើថារថយន្តរបស់ខ្លួនបានដាក់ប្រាតិភោគដោយអនុប្បទានរួចហើយឬយ៉ាងណានោះទេ គឺយករថយន្តទៅលក់ឲ្យហាងរថយន្ត «ទំនើបថ្មី»។ ករណីដល់កាលបរិច្ឆេទកំណត់នៃការសងបំណុល តែកូនបំណុលមិនព្រមសងវិញ សំណួរចោទឡើងថាម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន ដែលបានបង្កើតសិទ្ធិលើបំណុលជាមួយរថយន្តនោះមុនអាចមានសិទ្ធិទាមទាររថយន្តនោះពីហាងរថយន្តបានដែរឬទេ? តើមានសិទ្ធិអ្វីទៅតតាំងយកអាទិភាពនៃការទទួលបានប្រាក់ពីកូនបំណុលដែរឬទេ? ចម្លើយយ៉ាងងាយនោះគឺថា មិនអាចទេ ព្រោះមានបទប្បញ្ញត្តិបញ្ជាក់យ៉ាងច្បាស់ថា ក្នុងករណីបែបនេះ ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានពុំមានសិទ្ធិណាមួយ ទៅតតាំងជាមួយតតិយជនឡើយ ក្រៅពីការទាមទារសិទ្ធិឲ្យសងបំណុលនេះចំពោះកូនបំណុលតែប៉ុណ្ណោះ។

## កថាខណ្ឌទី២ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

នៅពេលមានការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន រមែងកើតនូវលក្ខខណ្ឌគតិយុត្តនានាក្នុងពេលតំណាលគ្នានោះដែរ។ ជារួម គឺវិបាកដែលកើតចេញពីការបង្កើតសិទ្ធិនេះ នឹងកើតមានឡើង ដើម្បីចងភ្ជាប់ទំនាក់ទំនងគ្នារវាងម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានជាមួយនឹងកូនបំណុល ឬមានករណីខ្លះទៀត អាចពាក់ព័ន្ធនឹងតតិយជន (ក្នុងករណីដែលការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយផ្ទេរការកាន់កាប់តាមវិធីសាស្ត្រទី៤ គឺការផ្ទេរការកាន់កាប់ដោយបញ្ជា)។ ហេតុនេះ យើងគួរសិក្សាស្វែងយល់ថា បន្ទាប់ពីបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានហើយ តើនឹងមានវិបាកអ្វីខ្លះកើតឡើង?

### ក- វិសាលភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

ជាទូទៅ បញ្ហាវិវាទរដ្ឋប្បវេណីជាបញ្ហាដែលកើតឡើងរវាងបុគ្គលឯកជន ជាមួយនឹងបុគ្គលឯកជន ដែលត្រូវបានគេសង្កត់ធ្ងន់ទៅលើការគោរពគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ ត្រង់ចំណុចនេះ ចង់បង្ហាញឲ្យឃើញថា នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ទំហំនៃអានុភាពទៅលើចលនវត្ថុដែលជាកម្មវត្ថុ គឺអាស្រ័យទៅតាមការកំណត់ព្រមព្រៀងគ្នារវាងគូភាគីនៃកិច្ចសន្យាប្រាតិភោគ។ ប្រសិនបើមានចលនវត្ថុសម្រាប់ដាក់ធានាតែមួយ ឬមានពីរ ឬផ្គុំគ្នាច្រើនយ៉ាងណានោះ គឺមិនមែនចោទជាបញ្ហាឡើយ សំខាន់ស្ថិតនៅត្រង់ថាវាជាទ្រព្យកម្មសិទ្ធិរបស់កូន

បំណុល។ គួរបញ្ជាក់ផងដែរថា ទំហំនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចមានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុជាកម្មវត្ថុ និងជាផ្នែកមួយនៃវត្ថុដែលជាកម្មវត្ថុនោះ នៅពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ពោលគឺមានអានុភាពចំពោះផលដែលកើតឡើងពីចលនវត្ថុនោះ។

ក្នុងករណីដែល***អ្នកបង្កើត ឬតតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ*** ត្រង់ចំណុចនេះ អានុភាពនៃប្រាតិភោគដោយអនុប្បទាន មិនអាចកើតមានឡើងចំពោះផលនោះឡើយ។ បើពិចារណាឲ្យបានស៊ីជម្រៅទៅលើឫសគល់ជាដើមចមបណ្តាលឲ្យមានការបញ្ញត្តិរបៀបនេះ ស្ថិតនៅត្រង់ថាកាលណាអ្នកបង្កើត ឬតតិយជន កាន់កាប់ដោយផ្ទាល់ចំពោះចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន អ្នកប្រើប្រាស់ ឬអ្នកបង្កបង្កើនជាផលចេញពីចលនវត្ថុនោះ គឺជាកូនបំណុល ឬតតិយជននេះឯង មិនមែនជាម្ចាស់បំណុលឡើយ។ ហេតុនេះ វាគ្មានភាពចាំបាច់ណាមួយ ក្នុងការផ្តល់សិទ្ធិឲ្យម្ចាស់បំណុលមានអានុភាពគ្របដណ្តប់លើផលដែលខិតខំបង្កឡើងដោយជនដទៃទៀតនោះទេ។ ចំណុចនេះផងដែរមិនមែនសំដៅទៅលើតែផលល្អនោះទេ ជួនកាលចលនវត្ថុនោះអាចបង្កជាផលអវិជ្ជមានផងដែរ។

ឧទាហរណ៍ រថយន្តដែលបានដាក់ធានាបំណុលប្រាតិភោគដោយអនុប្បទានរួចហើយ បាន និងកំពុងកាន់កាប់ដោយកូនបំណុល ជាអកុសលរថយន្តនោះត្រូវបានគេលួចយកបាត់ទៅ។ មកដល់ត្រឹមនេះដោយមិនវែកញែកពីជនល្មើសដែលបានលួចរថយន្តទៅបាត់ ចំពោះបញ្ហាប្រឈមនេះ គួរវែកញែកឲ្យបានច្បាស់ថា រវាងម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន និងកូនបំណុលអ្នកណាមួយជាអ្នកទទួលខុសត្រូវលើចលនវត្ថុដែលបានបាត់? ជាគោលការណ៍សមភាព អ្នកដែលកាន់កាប់វត្ថុដោយផ្ទាល់គួរតែជាអ្នកដែលមានករណីយកិច្ចរក្សាវត្ថុឲ្យគង់វង្ស។ ប៉ុន្តែបើគាត់ពុំអាចរក្សាបានទេ មានតែប្រគល់ការទទួលខុសត្រូវឲ្យគាត់ ពោលគឺចលនវត្ថុក៏បាត់ ការសងបំណុលចំពោះម្ចាស់ប្រាតិភោគដោយអនុប្បទានក៏នៅរក្សាដដែល។

ជារួម ប្រសិនបើម្ចាស់បំណុលមិនបានកាន់កាប់ដោយផ្ទាល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានទេ នោះអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផលមិនអាចកើតមានឡើយ។

បន្ទាប់ពីបានធ្វើប្រាតិភោគដោយអនុប្បទានលើចលនវត្ថុណាមួយជាកំណត់ហើយ បើកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលមានសិទ្ធិក្នុងការប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ដោយផ្ទាល់ខ្លួន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរបានស្របជាមួយនឹងការជូនដំណឹងទៅកូនបំណុល។ ដោយហេតុថា ប្រាតិភោគដោយអនុប្បទានអនុញ្ញាតឲ្យកូនបំណុលមានលទ្ធភាព

កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយផ្ទាល់ ហេតុនេះក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលប្រគល់វត្ថុដែលជាកម្មវត្ថុបានដើម្បីយកមកចាត់ចែងប្តូរជាប្រាក់ ឬធ្វើអនុប្បទានជាស្ថាពរលើចលនវត្ថុនោះ។ ទន្ទឹមនឹងនេះ មិនមែនមានន័យថា ម្ចាស់បំណុលមានសិទ្ធិលើតម្លៃចលនវត្ថុទាំងស្រុងលើគ្រប់ករណីនោះទេ។ ប្រសិនបើតម្លៃនៃចលនវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង ម្ចាស់បំណុលត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះទៅឲ្យកូនបំណុលដោយចាត់ទុកថាជាប្រាក់ជម្រះ។

ភ្ជាប់ជាមួយគ្នានេះ កូនបំណុលក៏មានសិទ្ធិរបស់ខ្លួនផងដែរ។ ក្នុងករណីម្ចាស់បំណុលកាន់កាប់ដោយផ្ទាល់លើចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន បើកូនបំណុលបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាកំណត់ចំពោះម្ចាស់បំណុល នោះម្ចាស់បំណុលត្រូវមានកាតព្វកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុត្រឡប់មកកូនបំណុលជាម្ចាស់ដើមវិញ។ បន្ថែមពីនេះចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលតាមកាលកំណត់ក៏ដោយ បើម្ចាស់បំណុលមិនទាន់បានចាត់ចែងប្តូរជាប្រាក់ ឬធ្វើអនុប្បទានជាស្ថាពរលើចលនវត្ថុនោះទេ កូនបំណុលនៅតែមានសិទ្ធិអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលកន្លងហួសនោះ ហើយនៅតែមានសិទ្ធិទាមទារឲ្យម្ចាស់បំណុលប្រគល់វត្ថុមកឲ្យខ្លួនវិញបានដដែល។ នៅត្រង់លក្ខខណ្ឌនេះ កូនបំណុលត្រូវផ្តល់នូវកាតព្វកិច្ចគ្រប់ចំនួន និងបង្ហាញអំពីការផ្តល់នោះទៅម្ចាស់បំណុល នៅមុនពេលការផ្តល់ប្រាក់ជម្រះ។ ការអនុវត្តសិទ្ធិរបស់កូនបំណុលបែបនេះ អាចធ្វើទៅបានតែក្នុងករណីដែលតម្លៃវត្ថុដែលជាកម្មវត្ថុ មិនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង។

គួរបញ្ជាក់ផងដែរថា វិសាលភាពនៃសិទ្ធិលើបំណុលប្រាតិភោគដោយអនុប្បទានដែលត្រូវបានធានារួមមាន ប្រាក់ដើម ការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា សោហ៊ុយដើម្បីអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាន សោហ៊ុយដើម្បីថែរក្សាវត្ថុដែលជាកម្មវត្ថុ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុដែលជាកម្មវត្ថុ[13]។

## ខ- ការកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន

ចំពោះ ***ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានទាមទារឲ្យប្រគល់វត្ថុដែលជាកម្មវត្ថុ***វិញ ផ្ទុយពីករណីខាងលើ អានុភាពនៃប្រាតិភោគដោយអនុប្បទាន អាចកើតមានឡើងចំពោះផល ក្នុង

[13] មាត្រា៨៩៥ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

ករណីម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានកាន់កាប់ដោយផ្ទាល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។ មិនខុសពីការបកស្រាយពីមុន ជាគោលការណ៍សមធម៌ ជនណាកាន់កាប់ដោយផ្ទាល់លើវត្ថុណាក៏ដោយ ជននោះគួរតែត្រូវទទួលយកទាំងលាភសក្ការៈ ទាំងហានិភ័យដែលអាចកើតឡើងចំពោះវត្ថុនោះ។ ត្រង់ចំណុចនេះ មានពីរករណីដែលអាចនឹងត្រូវបានពិចារណា៖

**ទី១** គឺស្ថិតនៅក្នុងអំឡុងនៃកាលបរិច្ឆេទនៃការសងត្រឡប់នៃបំណុល បើម្ចាស់បំណុលកាន់កាប់ដោយផ្ទាល់ចំពោះចលនវត្ថុនោះ ម្ចាស់បំណុលគឺជាអ្នកទទួលផលពីវា។

**ទី២** លុះត្រាណាដល់កំណត់កាលបរិច្ឆេទនៃការសងហើយ កូនបំណុលមិនបានអនុវត្តកាតព្វកិច្ចសង ម្ចាស់បំណុលនឹងអនុវត្តសិទ្ធិចាត់ចែងប្តូរជាប្រាក់នូវចលនវត្ថុដែលជាកម្មវត្ថុ ឬអាចធ្វើអនុប្បទានស្ថាពរលើចលនវត្ថុនោះបាន។ ក្នុងករណីនេះផងដែរ ផលទាំងឡាយដែលកើតចេញពីចលនវត្ថុ ទោះមិនបានកំណត់តាំងពីពេលចុះកិច្ចសន្យាប្រាតិភោគដោយអនុប្បទានក៏ដោយ ក៏ម្ចាស់សិទ្ធិប្រាតិភោគអាចទទួលយកបានដែរ ព្រោះខ្លួនជាអ្នកកាន់កាប់ដោយផ្ទាល់លើចលនវត្ថុនោះ។

ទន្ទឹមនឹងការទទួលបានអានុភាពដែលកើតឡើងចំពោះផល ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន ក៏មានសិទ្ធិទទួលការសងដោយមានអាទិភាពផងដែរ ព្រោះខ្លួនគឺជាអ្នកកាន់កាប់ដោយផ្ទាល់លើចលនវត្ថុដែលជាកម្មវត្ថុនៃការធានា។

## ផ្នែកទី២ លក្ខខណ្ឌតតាំង និងការអនុវត្តប្រឈមជាបញ្ហានៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

លក្ខខណ្ឌតតាំង សំដៅលើគោលការណ៍ ឬមូលដ្ឋានគ្រឹះដែលអាចឲ្យជនណាម្នាក់យកទៅអះអាងចំពោះជនដទៃបានថាខ្លួនពិតជាមានសិទ្ធិជាងជនដទៃនោះ។ ត្រង់ចំណុចនេះ ប្រាតិភោគដោយអនុប្បទានបានបង្កើតនូវលក្ខខណ្ឌតតាំងសម្រាប់ម្ចាស់បំណុលយកទៅប្រើប្រាស់ ជាប្រយោជន៍អះអាងចំពោះកូនបំណុល ឬតតិយជនឲ្យមានការទទួលស្គាល់សិទ្ធិក្នុងការសង បំណុលត្រឡប់មកខ្លួនវិញ។

### កថាខណ្ឌទី១ គោលការណ៍ទូទៅនៃលក្ខខណ្ឌតតាំង

លក្ខខណ្ឌតតាំង ជាលក្ខខណ្ឌទាក់ទងនឹងការផ្សព្វផ្សាយជាសាធារណៈអំពីការបង្កើត ការផ្ទេរ ឬការកែប្រែនូវសិទ្ធិប្រត្យក្សដើម្បីជាប្រយោជន៍សម្រាប់សុវត្ថិភាពគតិយុត្តក្នុងការជួញដូរ [14] ។ ជាទូទៅ មូលហេតុភាគច្រើននៃការបង្កើត ការផ្ទេរ និងការកែប្រែនូវសិទ្ធិប្រត្យក្ស គឺជាកិច្ចសន្យា។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មានកិច្ចសន្យាច្រើនរាប់មិនអស់ត្រូវបានបង្កើតឡើង ដើម្បីបម្រើឲ្យការរស់នៅរបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ។ កិច្ចសន្យាទាំងនេះកើតឡើងនៅស្ទើរតែជិតជុំខ្លួនយើងទាំងអស់ ដែលតម្រូវឲ្យភាគីមានការព្រមព្រៀងគ្នាទៅវិញទៅមក ថាគួរបង្កើត គួរផ្ទេរ ឬគួរកែប្រែសិទ្ធិប្រត្យក្សរបស់ខ្លួនតាមវិធីណា ។ ទន្ទឹមនឹងនេះ ការបង្កើតសិទ្ធិប្រត្យក្សនេះ អាចនឹងឈានទៅដល់ការដាក់វត្ថុ ឬមានបុគ្គលដើម្បីធានាក្នុងការសងបំណុលត្រឡប់ទៅម្ចាស់បំណុលវិញ ទើបអាចសម្រួលឲ្យដំណើរការបង្កើតសិទ្ធិលើបំណុលនេះ បញ្ចៀសនូវហានិភ័យបាន។ ក្នុងន័យនេះ ប្រសិនបើកូនបំណុល មិនមានលទ្ធភាពសង ឬមិនសងទេ ម្ចាស់បំណុលគួរតែមានវិធីសាស្ត្រក្នុងការតតាំងជាមួយកូនបំណុល ជាកត្តាចងភ្ជាប់កាតព្វកិច្ចរបស់កូនបំណុល ឲ្យត្រូវតែបំពេញកាតព្វកិច្ចសងរបស់ខ្លួនដោយខកខានមិនបាន។ ជាការពិតណាស់ កាលពីអតីតកាល អនុលោមតាមច្បាប់ព្រៃ អនុញ្ញាតឲ្យមានការប្រើប្រាស់វិធីសាស្ត្រហិង្សាបានគ្រប់រូបភាពពីសំណាក់ភាគីខ្លាំងជាង ទៅកាន់ភាគីខ្សោយជាង។ បើក្រឡេកមើលនៅក្នុងរឿងព្រេងបុរាណជាហូរហែមកឃើញថា ម្ចាស់បំណុលបានប្រើប្រាស់កម្លាំងបាយបង្ខំឲ្យកូនបំណុលសងកាតព្វកិច្ចវិញ។ ក៏ប៉ុន្តែបច្ចុប្បន្ននេះ មិនអនុវត្តដូច្នោះបានទៀតទេ។ មិនថាជាប្រទេសកម្ពុជា ឬជាប្រទេសជប៉ុន សុទ្ធសឹងតែមានច្បាប់គ្រប់គ្រងត្រឹមត្រូវ ប្រកបដោយសន្តិវិធី ហេតុនេះលក្ខខណ្ឌតតាំងដូចដែលរៀបរាប់មុននេះគឺមិនមែនជាការបង្ខិតបង្ខំដោយប្រើហិង្សាក្រោមទម្រង់ណាមួយនោះទេ។

ជាទូទៅ ចំពោះលក្ខខណ្ឌនៃការតតាំងអាចមានច្រើនប្រភេទ អាស្រ័យទៅតាមការបញ្ញត្តិ និងការអនុវត្តច្បាប់នៃប្រទេសនីមួយៗនៅក្នុងសកលលោក។ ការដែលអាចបែងចែកជាប្រភេទលក្ខខណ្ឌតតាំងផ្សេងៗគ្នានេះ ដោយសារតែយើងកំពុងតែពិភាក្សាទៅលើប្រធានបទផ្នែករដ្ឋប្បវេណី ដែលឈរលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ហេតុនេះមិនមានការតម្រូវដាច់ណាត់ណាមួយថាត្រូវតែអនុវត្តតាមវិធីនេះ ឬត្រូវតែអនុវត្តតាមវិធីនោះទេ។ ពាក់ព័ន្ធនឹងការតតាំងក្នុងករណី

[14] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១*, ខែមេសា ឆ្នាំ២០១៣

ចលនវត្ថុ មានប្រទេសខ្លះជ្រើសរើសយកវិធី «ផ្ទេរការកាន់កាប់» ដែលអាចឲ្យមានការត-តាំងបាន ខណៈពេលដែលប្រទេសមួយចំនួនទៀត ជ្រើសរើសយក«ការចុះបញ្ជីចលនវត្ថុ» ធ្វើជាលក្ខខណ្ឌតតាំង។

### កថាខណ្ឌទី២ លក្ខខណ្ឌតតាំងក្នុងករណីប្រាតិភោគដោយអនុប្បទាន

ដូចដែលបានរៀបរាប់ពីចំណុចលក្ខខណ្ឌតតាំង យើងសង្កេតឃើញថា ការបញ្ញត្តិឲ្យអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទានទាំងនៅកម្ពុជា ទាំងនៅក្នុងប្រទេសជប៉ុនចំពោះច្បាប់កាលពីមុនឆ្នាំ២០០៤ ដើម្បីឲ្យម្ចាស់បំណុលអាចតតាំងសិទ្ធិខ្លួនចំពោះតតិយជនបាន លុះត្រាណាម្ចាស់បំណុលនិងកូនបំណុលបានធ្វើការផ្ទេរការកាន់កាប់ក្រោមទម្រង់រូបភាពណាមួយ ក្នុងចំណោមរូបភាពទាំង៤នៃការផ្ទេរការកាន់កាប់។

ប្រទេសជប៉ុន មុនឆ្នាំ២០០៤ [15] លក្ខខណ្ឌតតាំងចំពោះតតិយជន ក្នុងករណីប្រាតិភោគដោយអនុប្បទាន មានសភាពដូចបទប្បញ្ញត្តិ និងការអនុវត្តនៅកម្ពុជាបច្ចុប្បន្នទាំងស្រុង។ មានន័យថា ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាននៅប្រទេសជប៉ុនបានទទួលយក «ការផ្ទេរការកាន់-កាប់»ធ្វើជាលក្ខខណ្ឌនៃការតតាំងចំពោះតតិយជនបាន។

យ៉ាងណាមិញ ទោះបីជាប្រាតិភោគដោយអនុប្បទាន ជាប្រភេទមួយនៃសិទ្ធិប្រត្យក្សដែលតម្រូវឲ្យមានការធានាដោយចលនវត្ថុមុននឹងមានការបង្កើតសិទ្ធិលើបំណុលក៏ដោយ គេមិនអាចអះអាងឲ្យបានគ្រប់ជ្រុងជ្រោយថា សិទ្ធិនោះនឹងត្រូវទទួលបានការការពារពេញលេញទេ។ ជាការលើកឡើងពីបញ្ញត្តិជាក់ស្តែង ក្រមរដ្ឋប្បវេណីកម្ពុជាមាត្រា៨៩៣ កថាខណ្ឌទី២ បានកំណត់ក្នុងករណីចលនវត្ថុនោះ ជាចលនវត្ថុជុំគ្នា បើអ្នកបង្កើតមានគម្រោងនឹងលក់វត្ថុដែលជាកម្មវត្ថុទៅជនដទៃ សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចអនុវត្តចំពោះទឹកប្រាក់ដែលបានលក់នោះឡើយ។ ជាគោលការណ៍ ទឹកប្រាក់ដែលទទួលបានពីការលក់ចលនវត្ថុនោះ គួរតែត្រូវបានមកលើម្ចាស់បំណុល ក្នុងពេលទូទាត់បំណុល បើកូនបំណុលមិនមានលទ្ធភាពក្នុងការសង ព្រោះថាចលនវត្ថុនោះ ជាវត្ថុសម្រាប់ដាក់ធានាបំណុល។ ប្រសិនបើ មិនអាចសងបំណុលបានទេ មានតែវត្ថុសម្រាប់អះអាងធានានោះហើយ ដែលជាថ្នូរនឹងការសងបំណុល។ ពោលជារួមគឺ យោងតាមច្បាប់នៃប្រទេសទាំងពីរ ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន ពិតជាមិនបានទទួលនូវសិទ្ធិពេញលេញក្នុងការធានាឲ្យបាននូវការសងបំណុលត្រឡប់វិញឡើយ។

[15] ឆ្នាំ២០០៤ ជាឆ្នាំដែលជប៉ុនអភិវឌ្ឍច្បាប់របស់ខ្លួន តាមរយៈការនាំចូលមកអនុវត្តនូវប្រព័ន្ធនៃការចុះបញ្ជីចលនវត្ថុ

## កថាខណ្ឌទី៣ ហានិភ័យដែលអាចនឹងកើតឡើងចំពោះម្ចាស់បំណុល

កន្លងមក ពាក់ព័ន្ធនឹងលក្ខខណ្ឌតតាំងដូចដែលបានរៀបរាប់ពីខាងលើនេះ គេសង្កេតឃើញមានបញ្ហាមួយចំនួនអាចកើតឡើង នៅត្រង់ការទទួលស្គាល់ «២. ការប្តូរលក្ខណៈនៃការកាន់កាប់ និង៤. ការផ្ទេរការកាន់កាប់ដោយបញ្ជា»។ ជាកត្តាសត្យានុម័ត ការផ្ទេរការកាន់កាប់រួមមានការផ្ទេរដោយផ្ទាល់ (ការប្រគល់វត្ថុជាក់ស្តែង) និងការផ្ទេរការកាន់កាប់ដោយប្រយោល (ការប្តូរលក្ខណៈនៃការកាន់កាប់, ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា)។ បញ្ហាស្ថិតនៅត្រង់ការផ្ទេរការកាន់កាប់ដោយប្រយោល ដោយដកចេញនូវការប្រគល់ដោយសង្ខេប ព្រោះចំពោះវិធីសាស្ត្រផ្ទេរតាមរយៈការប្រគល់ដោយសង្ខេប បានបង្កប់អត្ថន័យរួចជាស្រេចហើយថា ម្ចាស់បំណុលបានកាន់កាប់ដោយផ្ទាល់ទៅលើចលនវត្ថុ ដែលជាកម្មវត្ថុតាំងពីមុនពេលបង្កើតប្រាតិភោគដោយអនុប្បទាន។ ពោលគឺ តាមរយៈការប្រគល់ជាក់ស្តែង និងការប្រគល់ដោយសង្ខេប ម្ចាស់បំណុលជាតួអង្គក្នុងការឃុំគ្រង កាន់កាប់ផ្ទាល់ទៅលើចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។ ផ្ទុយទៅវិញ ករណីការផ្ទេរតាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ និងការផ្ទេរការកាន់កាប់តាមការបញ្ជាវិញ គឺកូនបំណុលមិនបានប្រគល់ចលនវត្ថុដោយផ្ទាល់ទៅកាន់ម្ចាស់បំណុលទេ។ នេះសបញ្ជាក់ឲ្យឃើញថា កូនបំណុលនៅតែកាន់កាប់ រក្សាវត្ថុជាធម្មតា។

ដូចដែលបានបង្ហាញរួចមកហើយពីភាពងាយស្រួល ក្នុងការប្រើប្រាស់វិធីប្រាតិភោគដោយអនុប្បទាននេះ ត្រង់ថាកូនបំណុលនៅតែអាចបន្តប្រើប្រាស់ចលនវត្ថុដែលជាកម្មវត្ថុនៃការដាក់ប្រាតិភោគបាន ហេតុនេះវិធីសាស្ត្រនេះត្រូវបានគេនិយមប្រើប្រាស់ច្រើន។ តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ និងការផ្ទេរការកាន់កាប់ដោយបញ្ជា បានក្លាយទៅជាលក្ខខណ្ឌសម្រាប់ការតតាំងជាមួយនឹងតតិយជនបាន។ បញ្ហាស្ថិតនៅត្រង់ថា គេមិនអាចឲ្យគេមើលពីសភាពលក្ខណៈខាងក្រៅរបស់វត្ថុថាកំពុងជាប់ធានាបំណុលឬអត់ទេ ដែលនេះជាកត្តាជម្រុញឲ្យសុវត្ថិភាពជំនួញមានហានិភ័យខ្ពស់។

តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ និងការផ្ទេរការកាន់កាប់ដោយបញ្ជា បានបង្កលទ្ធភាពដល់កូនបំណុលឲ្យមានសិទ្ធិក្នុងការចាត់ចែងលើចលនវត្ថុដែលជាកម្មវត្ថុ ព្រោះថាវត្ថុនោះស្ថិតនៅក្នុងដៃកូនបំណុលផ្ទាល់។ តាមសុចរិតភាព កូនបំណុលពិតជាមិនមានសិទ្ធិឡើយ ក្នុងការចាត់ចែងលើចលនវត្ថុដែលបានដាក់ប្រាតិភោគរួចទៅហើយនោះ។ ក៏ប៉ុន្តែ នរណាទៅអាចអះអាងបានថាកូនបំណុលពិតជាមានភាពស្មោះត្រង់នឹងម្ចាស់បំណុលពិតប្រាកដមែន ហើយមិនហ៊ានប្រើ

ប្រាស់ចលនវត្ថុដដែលដើម្បីជាប្រយោជន៍ផ្សេងទៀត ដោយភ្លេចគិតពីការបំពានសិទ្ធិពិតប្រាកដរបស់ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាននោះ។

បញ្ញត្តិបានកំណត់រួចមកហើយថា ប្រសិនបើតតិយជននោះធ្វើលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ **តតិយជនអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះអ្នកបង្កើតបាន**។ ដូច្នេះ វានឹងប៉ះពាល់ដល់ប្រយោជន៍របស់ម្ចាស់សិទ្ធិដើមពិតប្រាកដ (ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន) ជាក់ជាមិនខាន។

គួរបញ្ជាក់ផងដែរថា ផ្អែកលើបំណកស្រាយខាងដើមមក ម្ចាស់បំណុលមានសិទ្ធិក្នុងការចាត់ចែងប្តូរជាប្រាក់ ឬអាចធ្វើអនុប្បទានជាស្ថាពរលើវត្ថុដែលជាកម្មវត្ថុបាន ប្រសិនបើកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ បន្ថែមពីនេះ ម្ចាស់បំណុលថែមទាំងអាចទាមទារឲ្យកូនបំណុលប្រគល់ចលនវត្ថុ ដែលខ្លួនមិនបានកាន់កាប់ដោយផ្ទាល់លើចលនវត្ថុនោះ ក្នុងគោលបំណងយកមកជម្រះលើបំណុលពេលកូនបំណុលមិនអនុវត្តកាតព្វកិច្ច។ បញ្ហាចោទនៅត្រង់ថា ប្រសិនបើកូនបំណុលបានប្រើប្រាស់ចលនវត្ថុតែមួយ ដែលជាកម្មវត្ថុនៃការដាក់ប្រាតិភោគដោយអនុប្បទានពីមុនយកទៅបង្កើតសិទ្ធិលើបំណុលថ្មីលើវត្ថុនោះ តើការទាមទារប្រគល់វត្ថុរបស់ម្ចាស់បំណុលខាងលើនឹងទៅជាយ៉ាងណា? តើកូនបំណុលមានចលនវត្ថុឯណាទៀតយកមកប្រគល់ឲ្យម្ចាស់បំណុលបើខ្លួនមិនបានអនុវត្តកាតព្វកិច្ចផងនោះ។ ត្រង់ចំណុចនេះ អាចបញ្ជាក់បានយ៉ាងច្បាស់ថា លទ្ធភាពដែលម្ចាស់បំណុលនឹងទទួលហានិភ័យ គឺមានកម្រិតខ្ពស់។

ដូចគ្នាផងដែរ ចំពោះតតិយជនដែលបានទទួលបញ្ញាពីអ្នកបង្កើត បានកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ករណីនេះបានផ្តល់អានុភាពចំពោះតតិយជន ដែលបានទទួលនូវលទ្ធកម្មនូវវត្ថុនោះ ឲ្យមានសិទ្ធិទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន ប្រសិនបើតតិយជនបានបំពេញគ្រប់លក្ខខណ្ឌនៃការធ្វើលទ្ធកម្មដោយសុចរិ-ត។

ដោយផ្អែកលើសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២ ដែលរៀបចំឡើងដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានពន្យ-ល់ទោះលើមាត្រា៨៩៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីកម្ពុជាយ៉ាងដូច្នេះថា កូនបំណុលអាចធ្វើការចាត់ចែងលើចលនវត្ថុផ្ទុំគ្នា ដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានបានដោយសេរីក្នុងករណីកូនបំណុលនៅតែបន្តកាន់កាប់ដោយផ្ទាល់លើចលនវត្ថុផ្ទុំគ្នា ហើយកូនបំណុលមាន

បំណងចាត់ចែងតាំងពីដំបូងលើវត្ថុនោះ។ ដើម្បីឲ្យកាន់តែងាយស្រួលយល់ សូមចាប់អារម្មណ៍ទៅលើឧទាហរណ៍មួយដូចដែលនឹងរៀបរាប់តទៅនេះ។

តួយ៉ាងលោក **ក** មានទំនិញជាច្រើននៅក្នុងហាងរបស់ខ្លួន ហើយគាត់មានបំណងនឹងលក់ទំនិញខ្លះទៅឲ្យលោក **គ**។ មិនទាន់បានលក់ទំនិញផង ស្រាប់តែលោក **ក** បានយកទំនិញក្នុងហាងទៅដាក់ធានាប្រាតិភោគដោយអនុប្បទានជាមួយនឹង លោក **ខ** ដែលជាម្ចាស់បំណុល។ ក្រោយមកលោក **ក** ក៏បានលក់ចលនវត្ថុមួយផ្នែកនៅក្នុងហាងទៅឲ្យលោក **គ** តាមការគ្រោងទុកតាំងពីដំបូង។ បើទោះបីជាលោក **គ** បានដឹងយ៉ាងជាក់ច្បាស់ទៅហើយថា ចលនវត្ថុផ្គុំគ្នាត្រូវបានប្រើប្រាស់ជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានរួចមកហើយក្តី ក៏លោក **គ** នៅតែអាចធ្វើលទ្ធកម្មដោយសុចរិតលើមួយផ្នែកនៃចលនវត្ថុផ្គុំគ្នានោះបានតាមការសន្យារបស់លោក **ក** ចំពោះរូបលោក។ លោក **គ** នៅតែជាតតិយជនសុចរិត ព្រោះទំនិញទាំងនោះ លែងស្ថិតនៅជាផ្នែកនៃចលនវត្ថុផ្គុំគ្នាទៀតហើយ។

ពិនិត្យទៅលើបញ្ញត្តិច្បាប់ដដែល គឺមិនបានកំណត់ឲ្យច្បាស់លាស់ទេថា កូនបំណុលអាចធ្វើលទ្ធកម្មទៅតតិយជននូវចលនវត្ថុផ្គុំគ្នាបានត្រឹមកម្រិតណានោះ។ ពាក្យថា «ចាត់ចែងដោយសេរី» គឺពិតជាមានវិសាលភាពធំទូលាយណាស់ ដែលអាចបកស្រាយបានថា រហូតដល់អស់ចលនវត្ថុទាំងស្រុងផងក៏ថាបាន។

យ៉ាងនេះហើយ ដែលអាចក្លាយទៅជាហានិភ័យយ៉ាងសម្បើមចំពោះម្ចាស់បំណុលប្រាតិ-ភោគដោយអនុប្បទាន។ បើបញ្ញត្តិច្បាប់ការពារតតិយជនបែបនេះហើយ តើម្ចាស់បំណុលប្រាតិ-ភោគដោយអនុប្បទានអាចនឹងមានសិទ្ធិអ្វីមកតតាំងជាមួយតតិយជនបានទៅ? ករណីនេះ មិនអាចតតាំងនឹងតតិយជនបានទេ មានតែតតាំងជាមួយកូនបំណុលខណៈពេលដែលខ្លួនមិនមានវត្ថុអ្វីមកធ្វើការធានាថា កូនបំណុលនឹងសងត្រឡប់មកវិញនូវបំណុលរបស់ខ្លួន ឬយ៉ាងណានោះទេ។ នេះសបញ្ជាក់ឲ្យឃើញពីកំសោយនៃបញ្ញត្តិច្បាប់ ក្នុងការជួយការពារសិទ្ធិម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានឲ្យបានពេញលេញ។

### ក- បញ្ហានៃករណីតតិយជនក្លាយជាអ្នកទិញ

នៅត្រង់ចំណុចស្តីពីលក្ខខណ្ឌនៃការតតាំង បានគូសបញ្ជាក់ឲ្យឃើញថា នៅប្រទេសកម្ពុជាការចុះបញ្ជីចលនវត្ថុ មិនបានក្លាយជាលក្ខខណ្ឌចម្បងក្នុងការធានាសិទ្ធិប្រាតិភោគនោះទេ។ គោល

ការណ៍នេះ ត្រូវបានអនុវត្តនៅក្នុងប្រទេសជប៉ុន មុនឆ្នាំ២០០៤ គឺមុននឹងជប៉ុននាំយកប្រព័ន្ធចុះបញ្ជីលើចលនវត្ថុមកអនុវត្ត។

ដូចដែលបានរៀបរាប់ពីខាងដើម សិទ្ធិប្រាតិភោគដោយអនុប្បទាន ទទួលស្គាល់លក្ខខណ្ឌនៃការផ្ទេរការកាន់កាប់តាមរយៈ «ការប្តូរលក្ខណៈនៃការកាន់កាប់»។ យោងតាមគោលគំនិតរបស់អ្នកច្បាប់របស់ប្រទេសជប៉ុន ការទទួលស្គាល់លក្ខខណ្ឌបែបនេះ ហាក់បីដូចជាមានកំសោយក្នុងការយកមកធ្វើជាលក្ខខណ្ឌតតាំងជាមួយនឹងម្ចាស់បំណុលដទៃណាស់ ដោយហេតុថាការផ្ទេរការកាន់កាប់តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ គឺគ្រាន់តែមានការព្រមព្រៀងរវាងគូភាគី[16]តែប៉ុណ្ណោះ ដោយគ្មានការប្រគល់ជាក់ស្តែង។ ដូចនេះ ក្នុងករណីដែលតតិយជនជឿជាក់ថា ចលនវត្ថុដែលនោះ មិនមានជាប់ធានាបំណុលប្រាតិភោគណាមួយពីមុនឡើយ ហើយក៏បានទិញចលនវត្ថុនោះពីសំណាក់កូនបំណុល[17]។ ជាធម្មតា នៅពេលមានកិច្ចសន្យាលក់ទិញកើតឡើង រមែងតែងភ្ជាប់នូវសិទ្ធិ និងកាតព្វកិច្ចទៅនឹងអ្នកលក់ ក៏ដូចជាអ្នកទិញ។ អ្នកលក់ មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថា«អ្នកទិញ» ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់[18]។ ពោលគឺ តតិយជនដែលជាអ្នកទិញ មានសិទ្ធិក្នុងការទទួលបានចលនវត្ថុមកធ្វើការកាន់កាប់ដោយផ្ទាល់។

សូមមើលគំនូសបំព្រួញដោយសង្ខេបអំពីករណីនេះដូចតទៅៈ




[16] គូភាគីនៅទីនេះ សំដៅលើម្ចាស់បំណុល(ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន) និង កូនបំណុល ឬតតិយជនដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន

[17] 内田貴『民法Ⅲ 債権総論・担保物権（第３版）』、（東京大学出版会、２００５年９月） ទំព័រ៥៣១

[18] ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា៥១៥

ពាក់ព័ន្ធនឹងគោលការណ៍នៅប្រទេសកម្ពុជា យោងតាមមាត្រា៨៩៤ កថាខណ្ឌទី១ បាន បញ្ញត្តិថា «បើអ្នកបង្កើតដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ដោយអនុប្បទាន នៅក្រោយពេលបង្កើតកិច្ចសន្យានោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុ នោះទៅតតិយជន ឬបានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិ-យជននោះបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា១៩៣ (លទ្ធកម្មដោយសុចរិតនូវ កម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះម្ចាស់សិទ្ធិ ប្រាតិភោគដោយអនុប្បទានបាន»។ ស្តីពីលទ្ធកម្មដោយសុចរិត ចំពោះអ្នកដែលបានផ្ទេរការកាន់ កាប់ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និងគ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយី [19] គ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ ដោយ។

ក្នុងករណីនេះ តតិយជនដែលជាអ្នកទិញ បានទិញយកចលនវត្ថុពីអ្នកលក់ដោយសុចរិត ដោយមិនបានដឹងជាមុនសោះថា ចលនវត្ថុដែលគាត់បានទិញនោះ ត្រូវបានជាប់ដាក់ធានាបំណុល ព្រោះថាការមើលសភាពពីខាងក្រៅ មិនអាចឆ្លុះបញ្ចាំងឲ្យអ្នកទិញអាចវិនិច្ឆ័យបានទេថាវត្ថុនោះ មានបន្ទុកបំណុល ឬយ៉ាងណានោះ។ ហេតុនេះ វាចាំបាច់ណាស់ ក្នុងការការពារតតិយជនដែល សុចរិត ដូចជាអ្នកទិញចលនវត្ថុដែលជាកម្មវត្ថុនៃការធានាប្រាតិភោគដោយអនុប្បទានពីកូនបំណុ-ល។ នេះសបញ្ជាក់ឲ្យឃើញថា សូម្បីតែបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីកម្ពុជាក៏បានចងភ្ជាប់រួចជា ស្រេច ក្នុងការផ្តល់សិទ្ធិអាទិភាព និងការការពារចំពោះតតិយជនសុចរិត ជាជាងការពារទៅលើ ម្ចាស់ប្រាតិភោគដោយអនុប្បទាន ឬក៏ហៅថាម្ចាស់បំណុល។

តើការធ្វើដូចនេះ មិនរំលោភបំពានសិទ្ធិរបស់ម្ចាស់បំណុលពេកទេឬយ៉ាងណា? តើមានវិធី សាស្ត្រយ៉ាងណាដើម្បីជួយសង្គ្រោះម្ចាស់បំណុល ដើម្បីតតាំង ធានាឲ្យបាននូវការសងបំណុល របស់ខ្លួនត្រឡប់មកវិញ?

ត្រង់ចំណុចនេះ នៅប្រទេសជប៉ុនមានវិវាទមួយបានកើតឡើងរវាងលទ្ធកម្មដោយសុចរិត និងការប្តូរលក្ខណៈនៃការកាន់កាប់ថារវាងលក្ខខណ្ឌទាំងពីរនេះ មួយណាមានអានុភាពជាង? យោងតាមសាលដីកាជាយុត្តិសាស្ត្ររបស់តុលាការកំពូលនៃប្រទេសជប៉ុន លទ្ធកម្មដោយសុចរិត មានអានុភាពជាងការប្រគល់ដោយសង្ខេប ដោយយោងលើហេតុផលថាការពិនិត្យមើលសភាពពី

[19] អនុប្បទាយី សំដៅលើជនដែលមានសិទ្ធិ ឬទ្រព្យសម្បត្តិ ហើយធ្វើការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិនោះទៅឲ្យបុគ្គលម្នាក់ទៀត។ ត្រង់ចំណុចនេះ អនុប្បទាយី គឺកូនបំណុលប្រាតិភោគដោយអនុប្បទាន ព្រមទាំងជាអ្នកលក់ចលនវត្ថុទៅឲ្យតតិយជន។

ខាងក្រៅមិនអាចឲ្យគេវែកញែកបានថាចលនវត្ថុនោះ បានទទួលដាក់ប្រាតិភោគហើយឬយ៉ាងណានោះទេ។ ហេតុនេះ អ្នកទិញសុចរិត គ្មានកំហុស នឹងមានអាទិភាពលើចលនវត្ថុនោះច្រើនជាង[20]។

ជាការពិតណាស់ឆ្លងតាមលទ្ធកម្មដោយសុចរិត ការលក់ទិញ គួរតែត្រូវបានធានាថាគ្មានការរំខានដោយតតិយជន ឬម្ចាស់បំណុលដទៃទៀតឡើយ។ ហេតុនេះ ដើម្បីធានាផលប្រយោជន៍របស់អ្នកទិញ កូនបំណុលមានកាតព្វកិច្ចធានាការរំខាន ក៏ដូចជាការធានាចំពោះវិការៈអាថ៌កំបាំងនានាដែលអាចនឹងកើតមានឡើង។

## ខ- បញ្ហានៃករណីតតិយជនក្លាយជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានលំដាប់ទី២

បំណកស្រាយកន្លងមកបានបញ្ជាក់យ៉ាងច្បាស់ថា តាមរយៈការដាក់ចលនវត្ថុដើម្បីធានាប្រាតិភោគដោយអនុប្បទាន កូនបំណុលដោយមានការព្រមព្រៀងជាមួយនឹងម្ចាស់បំណុលអាចមានសិទ្ធិបន្តកាន់កាប់ដោយផ្ទាល់លើវត្ថុដែលជាកម្មវត្ថុបាន ដើម្បីជាប្រយោជន៍ក្នុងការប្រើប្រាស់វត្ថុនោះជាប្រក្រតី បើទោះបីស្ថិតក្នុងកាលៈទេសៈជាប់ដាក់ធានាបំណុលរួមមកហើយក៏ដោយ។ ក្នុងករណីមាន**ការបង្កើតប្រាតិភោគដោយអនុប្បទានពីរលើក** មានន័យថាកូនបំណុលយកចលនវត្ថុដែលកំពុងជាប់ធានាប្រាតិភោគដោយអនុប្បទានហើយ ទៅដាក់ធានាប្រាតិភោគដោយអនុប្បទានជាថ្មីម្តងទៀត ជាមួយនឹងម្ចាស់បំណុលផ្សេង តើគេត្រូវការពារម្ចាស់បំណុលទី២ដោយយោងលើហេតុផលថាគាត់មានភាពសុចរិតចំពោះការទទួលយកវត្ថុដាក់ធានាបំណុលឬទេ? តើអាចអនុវត្តបញ្ញត្តិស្តីពីលទ្ធកម្មដោយសុចរិត (មាត្រា១៩៣នៃក្រមរដ្ឋប្បវេណី) ចំពោះប្រាតិភោគដោយអនុប្បទានលំដាប់ទី២នេះបានដែរឬទេ? តើនៅក្នុងដំណាក់កាលទី២នេះទៀតសោត អាចអនុវត្ត «ការប្តូរលក្ខណៈនៃការកាន់កាប់ ឬការប្រគល់ដោយសង្ខេប» ដែលម្ចាស់បំណុលទី២ និងកូនបំណុលដដែល ព្រមព្រៀងគ្នាឲ្យកូនបំណុលជាអ្នកកាន់កាប់ដោយផ្ទាល់លើចលនវត្ថុបានដែរឬទេ? ដោយក្នុងបញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាន (មាត្រា៨៨៨ ដល់៨៩៩នៃក្រមរដ្ឋប្បវេណីកម្ពុជា) មិនបានបញ្ញត្តិពីលំដាប់នៃសិទ្ធិដូចការបញ្ចាំចលនវត្ថុ[21]ទេ ហេតុនេះ តើការសងបំណុលត្រឡប់ទៅវិញម្ចាស់បំណុលទី១អាចទាមទារសិទ្ធិអាទិភាពតាមពេល ចំពោះម្ចាស់បំណុលទី២ ក៏ដូចជាកូនបំណុលបានដែរឬទេ?

[20] កម្រងសាលដីកាលេខ១៤-២, ទំព័រ១៦៨

[21] មាត្រា៨៣៣ លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ៖ ក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតនោះ

មុននឹងឈានទៅដល់ការវិភាគចម្លល់ទាំងប៉ុន្មានដូចដែលបានរៀបរាប់ពីខាងលើនេះ ជាបឋម សូមចាប់ផ្តើមពិចារណាពីមាត្រា១៩៣ នៃក្រមរដ្ឋប្បវេណីកម្ពុជាជាមុនសិន។ មាត្រា១៩៣ បានបញ្ញត្តិថា «អ្នកដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និងគ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ»។ យោងតាមសេចក្តីពន្យល់ក្រមក៏បានគូសបញ្ជាក់ផងដែរថា មាត្រា១៩៣ស្តីពីលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុនេះ គឺជាបញ្ញត្តិសម្រាប់រក្សាសុវត្ថិភាពក្នុងកិច្ចការជំនួញចលនវត្ថុ តាមរយៈការការពារអ្នកដែលបានបង្កើតកិច្ចសន្យាអនុប្បទានកម្មសិទ្ធិជាមួយអ្នកគ្មានសិទ្ធិ ដោយមានការជឿច្រឡំថា អ្នកកាន់កាប់ចលនវត្ថុជាកម្មសិទ្ធករលើចលនវត្ថុនោះ។ គួរបញ្ជាក់បន្ថែមផងដែរថា ដើម្បីធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុដោយសុចរិត ចាំបាច់ត្រូវមានការផ្ទេរការកាន់កាប់។ ការផ្ទេរការកាន់កាប់ក្នុងករណីនេះ វិធីសាស្ត្រនៃការផ្ទេរការកាន់កាប់៣ប្រភេទរួមមាន ការប្រគល់ដោយជាក់ស្តែង ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា។ ចំណុចគួរឲ្យកត់សម្គាល់ គឺក្រមមិនបានរាប់បញ្ចូល ការផ្ទេរតាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ទេ ដោយហេតុថាការប្តូរលក្ខណៈនៃការកាន់កាប់ គឺជាការប្រគល់តាមតែទស្សនៈប៉ុណ្ណោះ ហើយមើលទៅពីក្រៅស្ថានភាពនៃការកាន់កាប់ ពុំមានការផ្លាស់ប្តូរទាល់តែសោះ។ ក្នុងករណីដែលបានលើកឡើងបែបនេះ ចុះហេតុដូចម្តេចទើបមិនដកចេញនូវវិធីសាស្ត្រនៃការផ្ទេរតាមរយៈ ការប្រគល់ដោយសង្ខេបផង? បើពិនិត្យឲ្យហ្មត់ចត់ទៅ ទាំងការប្តូរលក្ខណៈនៃការកាន់កាប់ ទាំងការប្រគល់ដោយសង្ខេប សុទ្ធតែជាវិធីសាស្ត្រនៃការផ្ទេរការកាន់កាប់ដោយប្រយោល ដែលវាផ្ទុយស្រឡះពីការប្រគល់ដោយជាក់ស្តែងជាវិធីសាស្ត្រផ្ទេរការកាន់កាប់ដោយផ្ទាល់។

តាមរយៈការចង្អុលបង្ហាញមាត្រា១៩៣ ស្របជាមួយនឹងសេចក្តីពន្យល់បកស្រាយបែបនេះ សំណួរដែលបានចោទឡើងខាងលើ អាចនឹងត្រូវបានឆ្លើយក្នុងគោលការណ៍ជាទូទៅនៃច្បាប់ថា ប្រសិនបើកូនបំណុលមិនស្មោះត្រង់ ហើយយកចលនវត្ថុដែលកំពុងជាប់ប្រាតិភោគដោយអនុប្បទានទៅដាក់ធានាប្រាតិភោគដោយអនុប្បទានជាថ្មីម្តងទៀត ជាមួយនឹងម្ចាស់បំណុលផ្សេង ច្បាប់ត្រូវការពារម្ចាស់បំណុលទី២ដោយយោងលើហេតុផលថាគាត់មានភាពសុចរិត និងគ្មានកំហុសចំពោះការទទួលយកចលនវត្ថុដែលជាកម្មវត្ថុដាក់ធានាបំណុល។ ពោលគឺគេអាចអនុវត្តបញ្ញត្តិស្តីពីលទ្ធកម្មដោយសុចរិត (មាត្រា១៩៣នៃក្រមរដ្ឋប្បវេណី) ចំពោះប្រាតិភោគដោយអនុប្បទានលំដាប់ទី២នេះបាន។ នៅក្នុងដំណាក់កាលទី២នេះ មិនមានបញ្ញត្តិណាមួយរារាំងការអនុវត្ត «ការប្តូរលក្ខ-

ណៈនៃការកាន់កាប់ ឬការប្រគល់ដោយសង្ខេប» ដែលម្ចាស់បំណុលទី២ និងកូនបំណុលដដែល ព្រមព្រៀងគ្នាឲ្យកូនបំណុលជាអ្នកកាន់កាប់ដោយផ្ទាល់លើចលនវត្ថុនោះទេ។

យ៉ាងណាមិញ ចំពោះសំណួរថា បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាន (មាត្រា៨៨៨ ដល់ ៨៩៩នៃក្រមរដ្ឋប្បវេណីកម្ពុជា) មិនបានបញ្ញត្តិពីលំដាប់នៃសិទ្ធិដូចការបញ្ចាំចលនវត្ថុ[22]ទេ ហេតុនេះ តើការសងបំណុលត្រឡប់ទៅវិញ ម្ចាស់បំណុលទី១អាចទាមទារសិទ្ធិអាទិភាពតាមពេល ចំពោះ ម្ចាស់បំណុលទី២ ក៏ដូចជាកូនបំណុលបានដែរឬទេ? បញ្ហានេះ មិនទាន់អាចនឹងត្រូវបានដោះ-ស្រាយទេ ព្រោះថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានលំដាប់ក្រោយ មិនមែនធ្វើលទ្ធកម្មដោយ សុចរិតតែម្តងលើចលនវត្ថុនោះឡើយ គឺគ្រាន់តែយកចលនវត្ថុនោះមកធ្វើជាកម្មវត្ថុនៃការធានាលើ ការសងត្រឡប់នៃបំណុលតែប៉ុណ្ណោះ។ បទប្បញ្ញត្តិស្រដៀងនឹងប្រាតិភោគដោយអនុប្បទាន គឺការ បញ្ចាំចលនវត្ថុ ដែលបញ្ញត្តិស្តីពីការបញ្ចាំចលនវត្ថុនេះ មានយ៉ាងជាក់លាក់ពីលំដាប់នៃសិទ្ធិលើការ បញ្ចាំចលនវត្ថុ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា៨៣៣ ដែលកំណត់ថា បើបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិ លើការបញ្ចាំទាំងនោះ ត្រូវអនុលោមទៅតាមពេលវេលាដែលបានបង្កើតនោះ។ ដោយការបញ្ញត្តិ បែបនេះហើយ មានមតិមួយចំនួនយល់ឃើញថា បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះ លំដាប់នៃសិទ្ធិលើប្រាតិភោគដោយអនុប្បទាន។ មិនមែនមានន័យថា ការយល់ឃើញបែបនេះខុស ទាំងស្រុងនោះទេ ប៉ុន្តែមិនមានគោលការណ៍ណាមួយ ចង្អុលបង្ហាញថាត្រូវអនុលោមតាមវិធីនេះ ឡើយ។

សូមមើលគំនូសបំព្រួញដោយសង្ខេបអំពីករណីនេះដូចតទៅ៖




[22] មាត្រា៨៣៣ លំដាប់នៃសិទ្ធិលើការបញ្ចាំចលនវត្ថុ៖ ក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំលើចលនវត្ថុតែមួយ ដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃសិទ្ធិលើការបញ្ចាំទាំងនោះត្រូវអនុលោមតាមពេលវេលាដែលបានបង្កើតនោះ

## គ- បញ្ហានៃករណីចលនវត្ថុផ្គុំគ្នាដែលត្រូវបានលក់មួយផ្នែក

អនុលោមតាមមាត្រា៨៩៤ កថាខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ក្នុងករណីប្រាតិភោគដោយអនុប្បទានលើចលនវត្ថុផ្គុំគ្នា ប្រសិនបើអ្នកបង្កើតមានគម្រោងលក់ចលនវត្ថុនោះទៅជនដទៃ ព្រោះតែអ្នកបង្កើត(កូនបំណុល) នៅតែបន្តការកាន់កាប់ដោយចំពោះទៅលើចលនវត្ថុ ទោះបីជាការលក់នោះ ធ្វើក្រោយពេលបង្កើតប្រាតិភោគដោយអនុប្បទានរួចក៏ដោយ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬម្ចាស់បំណុល មិនអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងនឹងអ្នកទិញចលនវត្ថុផ្គុំគ្នានោះបានទេ។ នៅត្រង់ចំណុចនេះ «ចលនវត្ថុផ្គុំគ្នា» មិនបានកំណត់ថា មានទំហំត្រឹមកម្រិតណា ហើយប្រសិនបើលក់ អាចលក់ត្រឹមកម្រិតណាឡើយ។ ហេតុដូច្នេះហើយ ថ្វីត្បិតតែជាប់ធានាបំណុលប្រាតិភោគដោយអនុប្បទានមែន ចុះបើកូនបំណុលមិនមានភាពស្មោះត្រង់ជាមួយនឹងម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន ហើយលក់មិនត្រឹមតែមួយផ្នែកទេ គឺលក់ចលនវត្ថុផ្គុំគ្នានោះទាំងស្រុងទៅឲ្យជនណាម្នាក់ទៅតាមការសន្យារបស់ខ្លួនតាំងពីដំបូង ម្ចាស់បំណុលនឹងទទួលរងនូវហានិភ័យខ្ពស់ ព្រោះលែងមានវត្ថុសម្រាប់ធានាឲ្យកូនបំណុលសងកាតព្វកិច្ចរបស់ខ្លួនទៀតហើយ។

តួយ៉ាង ម្ចាស់រោងចក្រសម្លៀកបំពាក់កាត់ដេរធុនតូចមួយ បានជួបវិបត្តិខ្វះថវិកាសម្រាប់ទិញក្រណាត់ដេរផលិតផលបន្ថែមទៀត។ គាត់សម្រេចចិត្តបង្កើតប្រាតិភោគ ដោយមានការដាក់ម៉ាស៊ីនដេរដែលមានទាំងអស់ចំនួន២០គ្រឿង ជាការធានាលើបំណុលរបស់គាត់ជាមួយនឹងម្ចាស់បំណុល។ មុននឹងមានការបង្កើតប្រាតិភោគដោយអនុប្បទាន ម្ចាស់រោងចក្រពិតជាបានជួបវិបត្តិហិរញ្ញវត្ថុផង បានសន្យាលក់ម៉ាស៊ីនដេរ១៥គ្រឿងទៅឲ្យម្ចាស់រោងចក្រកាត់ដេរមួយទៀតដែលជាមិត្តនឹងគ្នា។ យើងសង្កេតឃើញថា មានការសន្យាថាលក់កើតឡើងតាំងពីដំបូងរវាងម្ចាស់រោងចក្រ និងម្ចាស់រោងចក្រ។ ម្ចាស់រោងចក្រជាអ្នកទិញម៉ាស៊ីនដេរទាំង១៥គ្រឿង មានសិទ្ធិពេញលេញក្នុងការតតាំងជាមួយនឹងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន តាមរយៈការធ្វើលទ្ធកម្មដោយសុចរិតរបស់ខ្លួន។ ក្នុងករណីនេះ បើអស់ម៉ាស៊ីនដេរទាំង១៥គ្រឿងទៅ មានន័យថាតម្លៃនៃការធានាបំណុលចំពោះប្រាតិភោគដោយអនុប្បទាននោះគឺមិនគ្រប់គ្រាន់ឡើយ។

សូមមើលគំនូសបំព្រួញសង្ខេបអំពីករណីនេះដូចតទៅៈ




**កថាខណ្ឌទី៤ ការអនុវត្តប្រាតិភោគដោយអនុប្បទាន**

មិនថានៅប្រទេសកម្ពុជា ឬនៅជប៉ុនទេ ប្រាតិភោគដោយអនុប្បទានត្រូវបានអនុវត្តតាមលំនាំដូចគ្នា។ ប្រសិនបើកាតព្វកិច្ចត្រូវបានអនុវត្ត មានន័យថា កូនបំណុលសងបំណុលត្រឡប់ទៅម្ចាស់បំណុលវិញតាមការសន្យា ឬតាមការព្រមព្រៀងក្រោយទៀតរវាងគ្នានឹងគ្នា សន្មតថាប្រាតិ-ភោគដោយអនុប្បទានត្រូវបានអនុវត្តបញ្ចប់ជាស្ថាពរ។ ផ្ទុយទៅវិញ បើកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្តូរវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគជាប្រាក់ដោយផ្ទាល់ខ្លួន ឬធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនោះជាស្ថាពរបាន ដោយមានការជូនដំណឹងទៅកាន់អ្នកបង្កើត(កូនបំណុល ឬតតិយជន)។ ដោយហេតុថា តាមរយៈប្រាតិភោគដោយអនុប្បទាន កូនបំណុល ឬតតិយជនដែលបានទទួលបញ្ញា មានសិទ្ធិកាន់កាប់ដោយផ្ទាល់លើចលនវត្ថុដែលជាកម្មវត្ថុបាន ដូច្នេះនៅត្រង់ករណីដែលកាតព្វកិច្ចមិនត្រូវបានអនុវត្តនេះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន មានសិទ្ធិទាមទារឲ្យកូនបំណុល ឬតតិយជននោះ ប្រគល់វត្ថុមកឲ្យខ្លួនធ្វើការចាត់ចែងបាន។ ទន្ទឹមនឹងការចាត់ចែងទៅលើចលនវត្ថុដាក់ធានាប្រាតិភោគដោយអនុប្បទាន ប្រសិនបើការចាត់ចែងនោះ បានទទួលនូវតម្លៃរបស់ចលនវត្ថុលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសងម្ចាស់បំណុលមានករណីយកិច្ចបង់ចំនួនទឹកប្រាក់ដែលលើសនោះទៅឲ្យកូនបំណុលវិញ។

ជាគោលការណ៍ ប្រសិនបើកូនបំណុលបានអនុវត្តកាតព្វកិច្ចសងរបស់ខ្លួនរួចហើយ ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនោះទៅកូនបំណុលវិញ (ករណីម្ចាស់បំណុលកាន់កាប់ដោយផ្ទាល់លើចលនវត្ថុជាកម្មវត្ថុនៃប្រាតិភោគ)។

ទោះបីជាកាលកំណត់សងកាតព្វកិច្ចបានកន្លងផុតហើយក៏ដោយ បើកូនបំណុលបានផ្តល់នូវកាតព្វកិច្ចគ្រប់ចំនួន និងបានបង្ហាញអំពីការផ្តល់នោះទៅម្ចាស់បំណុល មុនមានការជម្រះពីម្ចាស់បំណុល កូនបំណុលដែលជាអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន អាចទទួលយកមកវិញនូវវត្ថុដាក់ធានាប្រាតិភោគនោះបាន។ ប៉ុន្តែ បើម្ចាស់បំណុលបានជូនដំណឹងពីការចង់ជម្រះប្រាក់ដែលកូនបំណុលមិនសងនោះរួច កូនបំណុលមិនអាចទាមទារយកមកវិញនូវវត្ថុបានទេ លើកលែងតម្លៃបន្ទាប់ពីជម្រះហើយលើសពីប្រាក់ដែលកូនបំណុលបានខ្ចី។

ចាប់តាំងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេសកម្ពុជា សម្រេចផ្តល់អាជ្ញាប័ណ្ណដល់ម្ចាស់ប្រាតិភោគដោយអនុប្បទានឲ្យមានប្រតិបត្តិការក្នុងឆ្នាំ២០០៩មក ចំនួននៃការអនុវត្តប្រាតិ-ភោគដោយអនុប្បទាន មានការកើនឡើងគួរឲ្យកត់សម្គាល់។ ជាឧទាហរណ៍ជាក់ស្តែង ចំពោះករណីនៃការអនុវត្តនៅក្នុងប្រទេសកម្ពុជាផ្ទាល់ ហាងប្រាតិភោគដោយអនុប្បទាន ឃែស យូ អាប់ (Cash U Up) បានទទួលអាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការកាលពីឆ្នាំ២០១០ និងបន្តពង្រីកសាខាទៅដល់ខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។ យោងទៅតាមព័ត៌មានដែលបានចេញផ្សាយ នៅលើគេហទំព័ររបស់ភ្នំពេញប៉ុស្តិ៍[23] លោក ស៊ា រិទ្ធី (Sear Rithy) ជាប្រធានរបស់ឃែស យូ អាប់ បានឲ្យដឹងថា កាលពីបង្កើតហាងប្រាតិភោគដោយអនុប្បទានដំបូងក្នុងឆ្នាំ២០១០ គ្រឹះស្ថានផ្តល់ប្រាក់កម្ចីនេះមានដើមទុន២,៥លានដុល្លារអាមេរិច។ វត្ថុដែលជាកម្មវត្ថុអាចយកមកដាក់ធានាបានមានដូចជាគ្រឿងអលង្ការ រថយន្ត ម៉ូតូ ដែលអាចធានាបំណុលបានដល់កម្រិតអតិបរមាត្រឹម៥០០០ដុល្លារអាមេរិច។

យោងតាមសារព័ត៌មានដដែលបានឲ្យដឹងថា ការអនុវត្តប្រាតិភោគដោយអនុប្បទាននៅកម្ពុជានៅមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយ។ ទទ្បីករណ៍អាចបញ្ជាក់បានស្រាប់ គឺថាតាំងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសផ្តល់អាជ្ញាប័ណ្ណដល់ម្ចាស់ហាងប្រាតិភោគដោយអនុប្បទានមក ចាប់តាំងពីឆ្នាំ២០០៩ ដល់២០១៤ មានតែ៦ហាងប្រាតិភោគប៉ុណ្ណោះដែលបានសុំអាជ្ញាប័ណ្ណ។ បញ្ហាប្រឈមមួយទៀត ដែលបណ្តាលឲ្យការអនុវត្តប្រាតិភោគដោយអនុប្បទាន នៅកម្ពុជាមាន

[23]គេហទំព័រព័ត៌មានភ្នំពេញប៉ុស្តិ៍ http://www.phnompenhpost.com/business/pawn-shop-rise-proves-quick-fix (ចូលមើលថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦)

លក្ខណៈមិនទាន់សូវទូលំទូលាយ បើយោងតាមលោក ស៊ា រិទ្ធី ប្រជាពលរដ្ឋកម្ពុជានៅមានភាពខ្មាសអៀនក្នុងការមកកម្ចីប្រាក់នៅហាងប្រាតិភោគដោយអនុប្បទាន ឬហាងបញ្ចាំផ្សេងទៀតជាជាងការទៅខ្ចីប្រាក់ពីធនាគារ។ ហេតុនេះ ចំនួនអ្នកប្រើប្រាស់វិធីប្រាតិភោគដោយអនុប្បទាននេះនៅមានកម្រិតនៅឡើយ។

បញ្ហាប្រឈមនៃការអនុវត្ត ចំពោះករណីគ្រឿងអលង្ការ លោក ស៊ា រិទ្ធី បានបញ្ជាក់ថាមិនមានឯកសារបញ្ជាក់កម្មសិទ្ធិនៃចលនវត្ថុនៃត្រឹមត្រូវបាននោះទេ។ អ្វីដែលហាងប្រាតិភោគរបស់លោកធ្វើបាននោះ គឺមានតែការពិនិត្យមើលលើអត្តសញ្ញាប័ណ្ណរបស់កូនបំណុល ព្រមជាមួយនឹងការបញ្ជាក់ពីអាសយដ្ឋាន ការងារពិតប្រាកដរបស់កូនបំណុលតែប៉ុណ្ណោះ ដែលខុសពីអចលនវត្ថុមានលិខិតស្នាម ប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ។ ដូច្នេះ លទ្ធភាពហានិភ័យអាចកើតមានកម្រិតខ្ពស់ចំពោះទាំងម្ចាស់បំណុល ទាំងកូនបំណុល។

ក្រោយពីបានសិក្សា លើលក្ខណៈដូចគ្នារវាងប្រាតិភោគដោយអនុប្បទានកម្ពុជា-ជប៉ុនមក យើងអាចសន្និដ្ឋានបានថា ប្រព័ន្ធប្រាតិភោគដោយអនុប្បទានរបស់ប្រទេសកម្ពុជាបច្ចុប្បន្នមានលក្ខណៈដូចគ្នាច្រើន ទៅនឹងប្រាតិភោគដោយអនុប្បទាននៅជប៉ុន ជាពិសេសមុនឆ្នាំ២០០៤ ដែលជប៉ុនបានបង្កើតច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទាន។ ចំណុចដូចនោះ រួមបញ្ចូលទាំងលក្ខខណ្ឌនៃការបង្កើត អានុភាពនៃការតតាំង និងការអនុវត្តផង។

ជាបន្ត យើងនឹងសិក្សាអំពីលក្ខណៈខុសគ្នារវាងប្រាតិភោគដោយអនុប្បទានកម្ពុជា-ជប៉ុននៅជំពូកទី២។

# ជំពូកទី២

# លក្ខណៈខុសគ្នានៃបទប្បញ្ញត្តិ ស្តីពីប្រាតិភោគដោយ អនុប្បទានកម្ពុជា-ជប៉ុន

# ជំពូកទី២
# លក្ខណៈខុសគ្នានៃបទប្បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទានកម្ពុជា-ជប៉ុន

នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន មិនមានចែងពីប្រាតិភោគដោយអនុប្បទាននោះទេ។ យ៉ាងណាមិញ ជប៉ុនមានមាន«**ច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទាន**» ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៤។ ថ្វីត្បិតតែនីតិខាងឯកជនរបស់ព្រះរាជាណាចក្រជប៉ុន បានគ្របដណ្តប់យ៉ាងស៊ីជម្រៅទៅលើនីតិឯកជន (ក្រមរដ្ឋប្បវេណី) នៃព្រះរាជាណាចក្រកម្ពុជាមែន អាស្រ័យទៅលើស្ថានភាពភូមិសាស្ត្រ កត្តាប្រជាសាស្ត្រ ក៏ដូចជាគោលគំនិតរបស់អ្នកតាក់តែងច្បាប់កម្ពុជា យើងសង្កេតឃើញពីភាពដោយឡែកពីគ្នាមួយចំនួន រវាងគោលការណ៍ប្រាតិភោគដោយអនុប្បទានកម្ពុជា និងជប៉ុន គួរឲ្យកត់សម្គាល់។ ផ្តោតទៅលើបទប្បញ្ញត្តិនេះនៅកម្ពុជា ហាក់បីដូចជាមិនទាន់មានលក្ខ-ណៈសម្បូរបែបដូចជាបទប្បញ្ញត្តិនៅក្នុងប្រទេសជប៉ុននៅឡើយ ទាំងលក្ខខណ្ឌនៃការបង្កើត ទាំងលក្ខខណ្ឌនៃការតតាំងសិទ្ធិរបស់ភាគីពាក់ព័ន្ធជាដើម។ ដើម្បីឲ្យកាន់តែជ្រាបច្បាស់ជាងនេះទៅទៀត ជាបន្តទៅនេះនឹងមានការស្រាយបំភ្លឺ ព្រមទាំងវែកញែកបង្ហាញឲ្យឃើញយ៉ាងប្រត្យក្សពីករណីខុសគ្នានៃបញ្ញត្តិរបស់ប្រទេសទាំងពីរ។

## ផ្នែកទី១ លក្ខខណ្ឌនៃការទទួលស្គាល់ប្រាតិភោគដោយអនុប្បទានតាមរយៈការផ្ទេរការកាន់កាប់នៅកម្ពុជា

ប្រាតិភោគដោយអនុប្បទាននៅកម្ពុជា បានទទួលយកលក្ខខណ្ឌផ្ទេរការកាន់កាប់ធ្វើជាគោលការណ៍គ្រឹះនៅពេលបង្កើតប្រាតិភោគដោយអនុប្បទាន។ ការផ្ទេរការកាន់កាប់ដូចបំណកស្រាយខាងលើ រួមមានការប្រគល់ដោយជាក់ស្តែង ការប្តូរលក្ខណៈនៃការកាន់កាប់ ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា[24]។ ក្នុងចំណោមវិធីសាស្ត្រនៃការផ្ទេរការកាន់កាប់ទាំង៤ប្រភេទនេះ ភាគីម្ចាស់បំណុល និងកូនបំណុលអាចសម្រេចជ្រើសរើសយកវិធីណាមួយក៏បានទៅតាមឆន្ទៈព្រមព្រៀងគ្នា។ យ៉ាងណាមិញ មានតែ«ការប្តូរលក្ខណៈនៃការកាន់កាប់»ទេ ដែលអនុញ្ញាតឲ្យកូនបំណុល អាចមានសិទ្ធិក្នុងការកាន់កាប់ដោយផ្ទាល់ទៅលើចលនវត្ថុជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។ ចំណែក«ការប្រគល់ជាក់ស្តែង» និង«ការប្រគល់ដោយសង្ខេប» គឺម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានអាចមានសិទ្ធិក្នុងការកាន់កាប់ដោយផ្ទាល់ទៅលើវត្ថុ។

[24] មាត្រា២២៩ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

រីឯ «ការផ្ទេរការកាន់កាប់ដោយបញ្ញា»វិញ គឺម្ចាស់បំណុល ឬកូនបំណុលអាចបញ្ញាឲ្យតតិយជនណាម្នាក់កាន់កាប់ទៅលើចលនវត្ថុដែលជាកម្មវត្ថុនៃការដាក់ធានាបាន។

ពោលជារួមគឺ ឲ្យតែមានការផ្ទេរការកាន់កាប់តាមវិធីសាស្ត្រមួយក្នុងវិធីសាស្ត្រទាំង៤ខាងលើនេះ គឺបញ្ញត្តិកម្ពុជាទទួលស្គាល់ពីភាពស្របច្បាប់នៃប្រាតិភោគដោយអនុប្បទានដែលត្រូវបានបង្កើតឡើងនោះហើយ វៀរលែងតែមានករណីពិសេសដទៃទៀត ដែលច្បាប់មិនទទួលស្គាល់ តួយ៉ាងដូចជា ការយកចលនវត្ថុទុច្ចរិតដើម្បីដាក់ធានាលើអនុប្បទានរបស់ខ្លួន ឬការបោកបន្លំដោយចេតនាពីភាគីណាមួយជាដើម។

## កថាខណ្ឌទី១ ការការពារម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន

ជាកត្តាសត្យានុម័តម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន គឺជាជនដែលបានចំណាយថវិកាដើម្បីឲ្យកូនបំណុលប្រើប្រាស់ក្នុងរយៈពេលជាកំណត់ណាមួយ។ ហេតុនេះកូនបំណុល ត្រូវមានកាតព្វកិច្ចសងបំណុលត្រឡប់ទៅម្ចាស់បំណុលវិញ ដោយភ្ជាប់ជាមួយនូវប្រយោជន៍តិចក្តីច្រើនក្តី (ជាក់ស្តែង រួមមានការប្រាក់ជាអាទ៍)។ យ៉ាងណាមិញ ការធានាឲ្យបានថាកូនបំណុលនឹងមិនបំពានកាតព្វកិច្ចរបស់ខ្លួន គឺជារឿងមិនងាយនឹងធ្វើឲ្យប្រាកដបាន ដោយហេតុថា មនុស្សនិងលុយ គោនិងស្មៅ ជឿជាក់ថាប្រសិនបើមនុស្សមានលុយគ្រប់គ្រាន់ហើយ មនុស្សប្រាកដជាមានលទ្ធភាពសុចរិតខ្ពស់ក្នុងការអនុវត្តកាតព្វកិច្ច បើពុំនោះទេសោតគេនៅតែត្រូវការលុយជាចាំបាច់ ឬមានមហិច្ឆតាខ្ពស់ជាដើម ដែលជាហេតុបណ្តាលឲ្យការសងកាតព្វកិច្ចមិនត្រូវបានអនុវត្ត។

អនុលោមតាមគោលការណ៍ទទួលស្គាល់ការកាន់កាប់ដោយប្រយោល (មិនផ្ទាល់) របស់ម្ចាស់បំណុលទៅលើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ហានិភ័យអាចកើតមានឡើងខ្ពស់ចំពោះម្ចាស់បំណុល ព្រោះថាកូនបំណុលអាចចាត់ចែងលើវត្ថុដោយមិនឲ្យម្ចាស់បំណុលដឹង។ បុព្វហេតុនេះហើយ ញ៉ាំងឲ្យមានការបង្កើតវិធីសាស្ត្រនៃ«**ការបិទផ្លាកសម្គាល់**»លើចលនវត្ថុជាប់ធានាប្រាតិភោគដោយអនុប្បទាន ដែលអាចធ្វើឲ្យជនក្រៅពីម្ចាស់បំណុល និងកូនបំណុល ក៏ដឹងអំពីស្ថានភាពគតិយុត្តរបស់ចលនវត្ថុផងដែរ។ ការធ្វើបែបនេះ គឺជាវិធីជួយម្ចាស់បំណុល ក្នុងការការពារការរំខានពីសំណាក់តតិយជនមកលើវត្ថុជាកម្មវត្ថុនៃបំណុលរបស់ខ្លួន។ មានន័យថា នៅពេលកូនបំណុលមិនមានភាពស្មោះត្រង់ ហើយលួចលាក់យកចលនវត្ថុដដែលដែលកំពុងជាប់ធានាបំណុល ទៅធ្វើលទ្ធកម្ម ឬបង្កើតសិទ្ធិលើបំណុលថ្មី តតិយជនដែលបម្រុងនឹងទទួលយកវត្ថុពីអ្នកធ្វើលទ្ធកម្ម (កូនបំណុល)នឹងដឹងពីគំនិតទុច្ចរិត ហើយមិនហ៊ានទទួលយកចលនវត្ថុនោះឡើយ

ព្រោះខ្លាចមិនអាចតតាំងជាមួយ ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានរបស់កូនបំណុលបាន។ កត្តានេះហើយ ដែលធ្វើឲ្យគេជឿជាក់ថា ហានិភ័យដែលអាចនឹងកើតឡើងចំពោះម្ចាស់បំណុលនឹងត្រូវបានបញ្ចៀស ព្រោះបានដាក់លក្ខខណ្ឌការពារម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានបានយ៉ាងត្រឹមត្រូវ។

មួយវិញទៀត ការធ្វើបែបនេះ (ការបិទផ្លាកសម្គាល់លើចលនវត្ថុ) អាចឲ្យម្ចាស់បំណុលមានទំនុកចិត្តក្នុងការរំពឹងចំពោះការអនុវត្តកាតព្វកិច្ចរបស់កូនបំណុលចំពោះខ្លួនវិញ (សងប្រាក់ត្រឡប់មកវិញ រួចម្ចាស់បំណុលនឹងប្រគល់ភាពជាម្ចាស់កម្មសិទ្ធិលើវត្ថុដល់កូនបំណុលវិញដូចគ្នាដែរ)។ កូនបំណុលដែលសុចរិត ពិតជាមានភាពភ័យខ្លាច និងប្រតិបត្តិកាតព្វកិច្ចរបស់ខ្លួនជាមិនខាន។

### កថាខណ្ឌទី២ ការការពារតតិយជនសុចរិត

ពីបញ្ញត្តិមួយទៅបញ្ញត្តិមួយនៃច្បាប់ រមែងតែងតែមានគោលដៅការពារទាំងសិទ្ធិ ទាំងផលប្រយោជន៍របស់គ្រប់ជនដែលពាក់ព័ន្ធ។ ទោះបីជាការការពារនោះមិនបានគ្រប់ជ្រុងជ្រោយនៅកាលៈទេសៈខ្លះក៏ដោយ យើងសង្កេតឃើញថា អ្នកតាក់តែងច្បាប់ បានខិតខំសម្រិតសម្រាំងយ៉ាងអស់ពីកម្លាំងកាយចិត្ត ធ្វើយ៉ាងណាឲ្យទទួលបានច្បាប់ដ៏មានប្រសិទ្ធភាពខ្ពស់ អាចទទួលយកបាន។ អាស្រ័យហេតុនេះហើយ នៅក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រង់បញ្ញត្តិស្ដីពីប្រាតិភោគដោយអនុប្បទានចាប់ពីមាត្រា៨៨៨ ដល់មាត្រា៨៩៩ ក៏មិនភ្លេចរួមបញ្ចូលនូវការការពារជនពាក់ព័ន្ធទាំងឡាយរួមមានកូនបំណុល ម្ចាស់បំណុល ព្រមទាំងតតិយជនដែលមានជាប់ជំពាក់ជំពិនទៅនឹងសិទ្ធិ ក៏ដូចជាផលប្រយោជន៍ជាមួយកូនបំណុល ឬម្ចាស់បំណុលនៃប្រាតិភោគដោយអនុប្បទាន។ ម្ចាស់បំណុល ត្រូវបានការពារឲ្យមានលក្ខខណ្ឌធានាបាននូវការសងកាតព្វកិច្ចពីកូនបំណុលត្រឡប់មកខ្លួនវិញ កូនបំណុលទទួលបានសិទ្ធិ និងផលប្រយោជន៍ក្នុងការកាន់កាប់ដោយផ្ទាល់ ដែលអនុញ្ញាតឲ្យកូនបំណុលអាចប្រើប្រាស់វត្ថុជាកម្មវត្ថុនៃការដាក់ធានាបាន ចំណែកឯតតិយជន ក៏ត្រូវបានទទួលសិទ្ធិ និងផលប្រយោជន៍ក្នុងការតតាំងចំពោះកូនបំណុល ព្រមទាំងម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានផងដែរ។

ប្រសិនបើមានការពាក់ព័ន្ធទៅនឹងតតិយជន តើតតិយជនមានសិទ្ធិកម្រិតណាក្នុងការយកតតាំងនឹងម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានបាន? តើតតិយជនត្រូវបំពេញលក្ខខណ្ឌបែបណា ទើបត្រូវទទួលបានការការពារពីសំណាក់ច្បាប់?

ឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើ មាត្រា៨៩០ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងការពារសិទ្ធិ និងផលប្រយោជន៍របស់តតិយជនដូចតទៅ៖

«ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមមាត្រា២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះទេ»។

អ្នកបង្កើតនៅទីនេះ សំដៅលើកូនបំណុល ដែលបានសេចក្តីថា ម្ចាស់បំណុលអាចតតាំងបានត្រឹមតែជាមួយកូនបំណុលឲ្យអនុវត្តកាតព្វកិច្ច ប៉ុន្តែមិនអាចប្រើសិទ្ធិជាម្ចាស់បំណុលទៅតតាំងជាមួយនឹងតតិយជនណាផ្សេងបានឡើយ។

មួយវិញទៀត ទោះក្នុងករណីចលនវត្ថុផ្ទុំគ្នា មាត្រា៨៩៤ កថាខណ្ឌទី២ បានកំណត់ថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចយកសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ទៅតតាំងចំពោះតតិយជនបានឡើយ ទោះបីជាតតិយជននោះបានបំពេញ ឬមិនបំពេញគ្រប់លក្ខខណ្ឌ ដែលបានកំណត់នៅក្នុងមាត្រា១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ)។ ករណីនេះ អាចអនុវត្តទៅបាន ប្រសិនបើកូនបំណុលនៅតែបន្តការកាន់កាប់ដោយផ្ទាល់លើចលនវត្ថុផ្ទុំគ្នានោះ។ យើងបានដឹងរួចមកហើយថា តាមរយៈប្រាតិភោគដោយអនុប្បទានបានអំណោយផលដល់កូនបំណុលក្នុងការបន្តសិទ្ធិប្រើប្រាស់ អាស្រ័យផលលើចលនវត្ថុទៀតបាន។ ហេតុនេះ ទោះបីជានៅពេលបង្កើតប្រាតិភោគដោយអនុប្បទាន មានការទទួលស្គាល់ទាំងការផ្ទេរការកាន់កាប់ដោយផ្ទាល់ក្តី ដោយប្រយោលក្តី កូនបំណុលនៅតែទាមទារឲ្យមានការផ្ទេរការកាន់កាប់ដោយប្រយោល ដែលយើងអាចមើលឃើញថាមានលទ្ធភាពនឹងកើតឡើងច្រើន។ ដូចនេះ ការធ្វើលទ្ធកម្មឲ្យតតិយជននោះ គឺមិនបានក្លាយជាបញ្ហារាំងស្ទះសម្រាប់កូនបំណុលនោះទេ។

នេះសបញ្ជាក់ឲ្យឃើញថា បញ្ញត្តិនេះបានចែងយ៉ាងហ្មត់ចត់សម្រាប់ការពារប្រយោជន៍របស់តតិយជន ឲ្យមានអាទិភាពជាងម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន។

### កថាខណ្ឌទី៣ តុល្យភាពនៃការការពារទាំងសិទ្ធិរបស់ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន និងតតិយជន

ដូចដែលបានបង្ហាញមកពីខាងដើមស្រាប់ តតិយជនដែលបានបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានលើចលនវត្ថុដដែល ត្រូវទទួលបានការការពារសិទ្ធិក្នុងរូបភាពនៃការធ្វើលទ្ធកម្មដោយ

សុចរិត[25]។ ទោះបីជាយ៉ាងណាក៏ដោយ ការការពារតតិយជនរបៀបនេះ ត្រូវបានគេគិតថាជាការការពារច្រើនហួស ដែលអាចធ្វើឲ្យប៉ះពាល់ដល់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលបង្កើតសិទ្ធិលើចលនវត្ថុនេះតាំងពីដំបូងមកម្ល៉េះ។ ហេតុដូចនេះ ក្នុងករណីប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលដល់កូនបំណុល ឬតតិយជនឲ្យមានសិទ្ធិក្នុងការកាន់កាប់លើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយផ្ទាល់ក៏ដោយ ក៏មិនទុកម្ចាស់បំណុលមួយឡែក ឬធ្វើឲ្យម្ចាស់បំណុលមានការខាតបង់ផលប្រយោជន៍ដោយប្រការណាមួយឡើយ។ ជាដំណោះស្រាយម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលត្រូវបានបង្កើតឡើងតាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់[26] ក៏ត្រូវទទួលបានការការពារពីច្បាប់ដូចជាម្ចាស់លទ្ធកម្មកម្មសិទ្ធិដោយសុចរិតដែរ។

តើគួរមានវិធីសាស្ត្របែបណាក្នុងការដោះស្រាយបញ្ហានៃការការពារសិទ្ធិ ទទួលបាននូវការសងបំណុលរបស់ជនទាំង២[27]ខាងលើនេះ?

ជានីតិវិធីនៃការស្រាយបញ្ហាជំពាក់ជំពិនគ្នាខាងលើនេះ នៅប្រទេសកម្ពុជា ប្រសិនបើមានចលនវត្ថុណាមួយត្រូវបានយកមកដាក់ធានាបំណុល ក្នុងរឿងប្រាតិភោគដោយអនុប្បទាន ម្ចាស់បំណុលនឹង **«ធ្វើការបិទផ្លាកសម្គាល់»** មួយលើវត្ថុជាសញ្ញាបញ្ជាក់ថាវត្ថុនោះមានជាប់ធានាបំណុល ព្រមទាំងជាបច្ច័យបញ្ជាក់ឲ្យឃើញថា ម្ចាស់បំណុល ឬអ្នកទិញ ឬជនដែលមានបំណងចង់ប្រើប្រាស់ចលនវត្ថុនោះតាមប្រភេទនៃបញ្ញត្តិច្បាប់ណាមួយក៏ដោយ ត្រូវមានការប្រុងប្រយ័ត្នចំពោះការបង្កើតសិទ្ធិធានាលើបំណុលដោយយកវត្ថុដដែលជាន់គ្នាមកប្រើប្រាស់[28]។ តាមរយៈការបិទផ្លាកបែបនេះ គេជឿជាក់ថាអាចធ្វើឲ្យតតិយជនដែលមានបំណងទិញចលនវត្ថុនោះក្លាយជាជនទុច្ចរិត និងមានកំហុស ព្រោះគាត់ពិតជាបានដឹងរួចទៅហើយ ថាចលនវត្ថុមានស្ថានភាពគតិយុត្តបែបណា។ កាលណាតតិយជនជាជនទុច្ចរិត និងមានកំហុស ដែលដឹងថាមានជាប់ប្រាតិភោគដោយអនុប្បទានលើចលនវត្ថុនោះហើយ នៅតែបន្តធ្វើលទ្ធកម្មទៀត នោះតតិយជនមិនអាចតតាំងសិទ្ធិលើ

[25] មាត្រា១៩៣ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា

[26] មានន័យថាកូនបំណុលគឺជាអ្នកកាន់កាប់ដោយផ្ទាល់លើចលនវត្ថុដែលបានដាក់ប្រាតិភោគដោយមិនប្រគល់ឲ្យម្ចាស់បំណុលដោយផ្ទាល់ក្នុងការធានាបំណុលទេ

[27] ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន និងម្ចាស់លទ្ធកម្មកម្មសិទ្ធិដោយសុចរិត

[28] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២*, ខែមេសា ឆ្នាំ២០១៣

បំណុលជាមួយនឹងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបានទេ[29]។ លើកលែងតែ ករណីចលនវត្ថុផ្ទុំគ្នា ហើយកូនបំណុលបានសន្យាតាំងពីមុនពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាមួយនឹងតតិយជន (ជនផ្សេងពីម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន)ណាម្នាក់ ថាព្រមលក់ចលនវត្ថុផ្ទុំគ្នា[30]នោះទៅឲ្យ ទើបតតិយជនទាំងសុចរិត ទាំងទុច្ចរិត(បានដឹងថាមានប្រាតិភោគដោយអនុប្បទានហើយនៅតែទិញ) អាចមានសិទ្ធិតតាំងនឹងម្ចាស់ប្រាតិភោគដោយអនុប្បទានបាន។

យ៉ាងណាមិញ បច្ចុប្បន្ន នីតិវិធីដោះស្រាយបែបនេះ ត្រូវបានគេយល់ឃើញថាមិនមានប្រសិទ្ធភាពនោះទេ ព្រោះថាបើទោះបីជាមានការបិទផ្លាកសម្គាល់ជាប់ធានាបំណុលក៏ពិតមែន ក៏ប៉ុន្តែដោយយោងលើហេតុផលថា កូនបំណុលជាអ្នកកាន់កាប់ដោយផ្ទាល់លើវត្ថុដែលជាកម្មវត្ថុ ដូចនេះគេមិនអាចធានាបានទេថា កូនបំណុលមានភាពស្មោះត្រង់ពិតប្រាកដជាមួយម្ចាស់បំណុល ហើយមិនលួចលាក់ដកផ្លាកនោះចេញវិញ។ ជាការពិតណាស់ មិនចំពោះកូនបំណុលណាម្នាក់នោះទេ ប្រសិនបើគាត់មានភាពទ័លច្រក ហើយត្រូវការប្រាក់ជាចាំបាច់ ទោះគាត់កំពុងជាប់ជំពាក់បំណុលរួចទៅហើយ ក៏លទ្ធភាពនៃការខ្ជីបន្ថែមទៀតមានកម្រិតខ្ពស់ ដែលពិបាកនឹងប៉ាន់ស្មាន ទុកចិត្តណាស់។ ដោយមូលហេតុនៃភាពក្រីក្រ នឹងអាចជម្រុញឲ្យកូនបំណុលលក់ចលនវត្ថុជាប់ធានាប្រាតិភោគដោយអនុប្បទាននោះ ទៅតតិយជនណាម្នាក់ដែលតាមរយៈការលក់ (ធ្វើលទ្ធកម្មដោយសុចរិត) តតិយជនមានសិទ្ធិក្នុងការទទួលបាននូវវត្ថុដោយផ្ទេរជាប្រាក់មកឲ្យអ្នកលក់[31] ឬឲ្យម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានទៅតាមការព្រមព្រៀងរបស់អ្នកលក់ និងអ្នកទិញ ព្រមទាំងម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន ប្រសិនបើម្ចាស់បំណុលបានដឹង និងពាក់ព័ន្ធក្នុងរឿងលក់ទិញនោះដែរ។ ផ្ទុយទៅវិញ ប្រសិនបើកូនបំណុលលួចលាក់លក់ចលនវត្ថុដោយកំបាំងមុខពីម្ចាស់បំណុល ហើយយកប្រាក់ដែលលក់បានទៅប្រើប្រាស់ជាប្រយោជន៍ផ្សេងៗក្រៅពីការសងកាតព្វកិច្ចចំពោះម្ចាស់បំណុល នោះក៏មានលទ្ធភាពនឹងអាចទៅរួចដែរ។

[29] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៩៣ កថាខណ្ឌទី១ លទ្ធកម្មដោយសុចរិត «អ្នកដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និងគ្មានកំហុស ត្រូវធ្វើលទ្ធកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ»

[30] ត្រង់ចំណុចនៃការលក់ចលនវត្ថុផ្ទុំគ្នានេះ អាចជាការលក់ផ្នែកនៃចលនវត្ថុ ឬអាចថាលក់ចលនវត្ថុទាំងស្រុងផងក៏ថាបានព្រោះច្បាប់មិនបានកំណត់ពីទំហំនៃការអាចយកចលនវត្ថុផ្ទុំគ្នានេះទៅលក់ក្នុងកម្រិត ចំនួនជាក់លាក់ប៉ុណ្ណាទេ

[31] កូនបំណុលប្រាតិភោគដោយអនុប្បទាន

យោងទៅតាមបរិបទនេះ ការធ្វើប្រាតិភោគដោយអនុប្បទាន គឺអាចបណ្តាលឲ្យម្ចាស់បំណុលមានការខាតបង់ប្រយោជន៍ ក្នុងករណីកូនបំណុលមិនមានភាពស្មោះត្រង់ ហើយលក់ចលនវត្ថុដែលបានដាក់ធានាបំណុលនោះទៅបាត់។

យោងតាមរបាយការណ៍របស់ធនាគារពិភពលោក គិតត្រឹមឆ្នាំ២០១២ បានបង្ហាញថាមានប្រជាជនកម្ពុជាប្រមាណ១៧.៧%ដែលកំពុងស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រ។ ស្ថិតនៅក្នុងស្ថានភាពជាប្រទេសកំពុងអភិវឌ្ឍន៍សេដ្ឋកិច្ច[32] ប្រជាជនជាច្រើន ដែលមានចំណូលទាប ចំណាយខ្ពស់មិនឆ្លើយតបទៅនឹងតម្រូវការ ដែលជាកត្តាញ៉ាំងឲ្យគាត់ទៅខ្ចីប្រាក់អ្នកដទៃ ក្នុងការបង្កើតជំនួញ ឬបង្គ្រប់ថវិកាសម្រាប់ឲ្យដំណើរការជំនួញរបស់គេបន្តប្រព្រឹត្តទៅមុខទៀតបាន។

តាមរយ:ការសិក្សាស្រាវជ្រាវកន្លងមក នៅប្រទេសជប៉ុនមានលំហូរនៃការប្រើប្រាស់ប្រាតិភោគដោយអនុប្បទាននេះ តាំងពីមុនមានការអនុវត្តនៅប្រទេសកម្ពុជា។ បើទោះបីជាជប៉ុនមិនមានចែងបញ្ញត្តិស្តីពី ប្រាតិភោគដោយអនុប្បទាននៅក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនក៏ដោយ ដោយសារយល់ពីគុណប្រយោជន៍នៃការប្រើប្រាស់វិធីសាស្ត្រ ប្រាតិភោគដោយអនុប្បទាននេះ ធ្វើឲ្យជប៉ុនមានការពិចារណាបង្កើតជាបញ្ញត្តិនានា ជាច្បាប់ដោយឡែកជាអាទិ៍ ដើម្បីធ្វើការគ្រប់គ្រង សម្របសម្រួលទៅលើការអនុវត្តប្រាតិភោគដោយអនុប្បទាន ញ៉ាំងឲ្យជីវភាព សុខុមាលភាពរបស់ប្រជាជនជប៉ុន ក៏ដូចជាសេដ្ឋកិច្ចនៃប្រទេសជប៉ុន មានភាពប្រសើរឡើងមួយកម្រិតថែមទៀត។ គួរបញ្ជាក់ថា បញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាននៅប្រទេសជប៉ុនមានការប្រែប្រួលជាបន្តបន្ទាប់ ដោយជប៉ុនខិតខំធ្វើសមាហរណកម្មយកប្រព័ន្ធថ្មីៗមកបញ្ចូលក្នុងការអនុវត្តប្រាតិភោគដោយអនុប្បទានឲ្យកាន់តែមានភាពរលូន។

នៅប្រទេសកម្ពុជា ដោយយកតាមលំនាំការអនុវត្តកាលពីអតីតកាលរបស់ប្រទេសជប៉ុន គឺមានការបិទផ្លាកសញ្ញាលើចលនវត្ថុថា មានជាប់ធានាប្រាតិភោគដោយអនុប្បទានហើយ។ វិធីសាស្ត្របែបនេះ មិនមានប្រសិទ្ធភាពខ្ពស់នោះទេ ដោយមើលឃើញបទពិសោធន៍ពីការអនុវត្តវិធីសាស្ត្របិទផ្លាកសម្គាល់នេះ នៅក្នុងប្រទេសជប៉ុនតាំងពីមុនឆ្នាំ២០០៤ (ឆ្នាំកែទម្រង់បញ្ញត្តិប្រាតិភោគដោយអនុប្បទានដោយនាំយកប្រព័ន្ធអនុវត្តថ្មី ដើម្បីទប់ទល់នឹងបញ្ហា) ដើម្បីការពារម្ចាស់បំណុល។ ជាលទ្ធផល ជប៉ុនជួបនូវវិវាទប្រឆាំងសិទ្ធិគ្នា រវាងម្ចាស់បំណុល ជាមួយនឹងតតិយជន ហើយមានការប្ដឹងផ្តល់ដល់តុលាការជាច្រើនអំពីវិវាទនេះ។

---

[32] GDP $16.78 billion ក្នុងឆ្នាំ២០១៤ និងGDP Per Capita 1094,6 ចន្លោះឆ្នាំ២០១១-២០១៥ ដកស្រង់ចេញពីគេហទំព័ររបស់ធនាគារពិភពលោក http://www.worldbank.org/en/country/cambodia (ចូលមើលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦)

ពាក់ព័ន្ធនឹងបញ្ហាមានការបង្កើតប្រាតិភោគដោយអនុប្បទានជាលើកទី២ ថ្វីត្បិតតែក្រមរដ្ឋប្បវេណីកម្ពុជាមិនបានកំណត់ច្បាស់ថា ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានមុន ឬក្រោយបានទទួលអាទិភាពនៃសងកាតព្វកិច្ចដូចមានកំណត់ច្បាស់នៅក្នុងបទប្បញ្ញត្តិច្បាស់នៃ ការបញ្ចាំចលនវត្ថុ ក៏ដោយ យោងតាម «ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា» សិទ្ធិប្រាតិភោគច្រើនលើទ្រព្យធានាតែមួយ ត្រូវមានអាទិភាពអនុលោមតាមពេលនៃការតម្កល់លិខិតជូនដំណឹងអំពីទ្រព្យធានា [33]។

ទោះជាយ៉ាងណាក៏ដោយ យោងតាមមាត្រា១៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាដដែល បើអ្នកទិញក្នុងអាជីវកម្មធម្មតា (មិនមែនបង្កើតសិទ្ធិលើបំណុលតាមរយៈប្រាតិភោគ) នោះអ្នកទិញត្រូវទទួលកម្មសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញឡើយ។ ហេតុនេះគេឃើញថាអត្ថិភាពនៃអ្នកទិញ មានលំដាប់ខ្ពស់ជាងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន។

នៅប្រទេសជប៉ុន នាសម័យស្យូវ៉ៈ(Shouwa Era, 昭和時代) វិវាទឡើងដល់តុលាការស្តីពីប្រាតិភោគដោយអនុប្បទាន បានកើតឡើងអំពីអាទិភាពរវាងលទ្ធកម្មដោយសុចរិត និងប្រាតិភោគដោយអនុប្បទានតាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់។ សាលក្រមលេខ១៤នេះបានប្រកាសទទួលស្គាល់លទ្ធកម្មដោយសុចរិត មានអាទិភាពជាជាងការផ្ទេរតាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់។ ហេតុផលនៃសេចក្តីសម្រេចនេះ គឺដោយសារជនដែលធ្វើលទ្ធកម្មទៅលើចលនវត្ថុមានសុចរិតភាព ដែលមិនបានដឹងអំពីភាពជាប់ធានាបំណុលនៃវត្ថុ ហើយដោយសភាពជាប់ធានាបំណុលនេះ មិនអាចត្រូវបានមើលឃើញពីលក្ខណៈខាងក្រៅបានទេ។ ដូច្នេះ ចាំបាច់ត្រូវតែការពារតតិយជនសុចរិតដែលធ្វើលទ្ធកម្មដោយសុចរិតលើវត្ថុនោះ។

ក្នុងប្រទេសកម្ពុជា នៅពេលមានការបង្កើតប្រាតិភោគដោយអនុប្បទាន គឺមិនតម្រូវឲ្យចុះបញ្ជីនោះទេ ដោយហេតុថាទាក់ទងនឹងចលនវត្ថុ វាគ្មានប្រព័ន្ធចុះបញ្ជីដូចអចលនវត្ថុ ដើម្បីជូនដំណឹងអំពីស្ថានភាពគតិយុត្តជាសាធារណៈនោះទេ[34]។

ជាទស្សនៈក្នុងការកែប្រែស្ថានការណ៍នេះ ចំពោះការអនុវត្តប្រាតិភោគដោយអនុប្បទាននៅកម្ពុជា គួរមានការបង្កើតបទប្បញ្ញត្តិស្តីពីការចុះបញ្ជីចលនវត្ថុនាពេលអនាគត ដើម្បីជាការធានានូវការទទួលបានសិទ្ធិពេញលេញរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬហៅថាម្ចាស់បំណុល

[33] ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឆ្នាំ២០០៧, មាត្រា១២

[34] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២*, ខែមេសា ឆ្នាំ២០១៣

នេះឯង។ ការធ្វើបែបនេះ អាចជាកត្តាជម្រុញឲ្យមានការកាត់បន្ថយវិវាទក្នុងរឿងបំណុល ហើយក៏ជាផ្នែកមួយជួយឲ្យសេដ្ឋកិច្ចកម្ពុជាមានការអភិវឌ្ឍន៍ទៅមុខយ៉ាងរលូនផងដែរ។

### កថាខណ្ឌទី៤ ស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងផ្នែកប្រាតិភោគដោយអនុប្បទាន

យោងតាមប្រកាសលេខ ១៣៣០ សហវ ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្ម និងហិរញ្ញវត្ថុ **នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន** ត្រូវបានបង្កើតឡើង ដើម្បីបំពេញមុខងារនានាទៅតាមបញ្ញត្តិដែលបានកំណត់ [35] ។ ស្ថាប័នមួយនេះ មានសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការនានា ដែលពាក់ព័ន្ធតែនឹងប្រាតិភោគដោយអនុប្បទាន នាយកដ្ឋាននេះត្រូវបំពេញមុខងារដូចជា៖

- រៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព គោលនយោបាយចាំបាច់នានា សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- គ្រប់គ្រង ត្រួតពិនិត្យ ផ្តល់អាជ្ញាបណ្ណ បន្តសុពលភាពអាជ្ញាបណ្ណ ដកហូតអាជ្ញាបណ្ណ និងកំណត់ទណ្ឌកម្មវិន័យ ក៏ដូចជាវិធានការរដ្ឋបាលចំពោះអាជីវកម្មរដ្ឋបាលចំពោះអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- ប្រមូលចំណូលអាជ្ញាបណ្ណអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខុសច្បាប់ ដែលគ្មានការអនុញ្ញាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផ្សះផ្សា និងដោះស្រាយរាល់វិវាទដែលទាក់ទងនឹងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានខុសច្បាប់ ដែលគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំឲ្យមានវេទិកាដេញថ្លៃទ្រព្យប្រាតិភោគដោយអនុប្បទាន
- ធ្វើរបាយការណ៍ប្រចាំខែជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម ហិរញ្ញវត្ថុ។

[35] គេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ http://gdfi.mef.gov.kh/?page=detail&ctype=article&id=675 (ចូលមើលថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦)

នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន មានការិយាល័យក្រោមឱវាទចំនួន៤ដូចជា៖

- ការិយាល័យសេវាកម្ម វាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ
- ការិយាល័យគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍លំនៅឋាន
- ការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ
- ការិយាល័យស្រាវជ្រាវ និងបង្ក្រាបបទល្មើសអាជីវកម្ម។

យ៉ាងណាមិញ ករណីមានវិវាទកើតឡើង ថ្វីត្បិតតែនាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន មានភារកិច្ចផ្សះផ្សា ព្រមទាំងដោះស្រាយវិវាទពាក់ព័ន្ធនឹងផ្នែកប្រាតិភោគដោយអនុប្បទានក៏ពិតមែន វាគឺជាវិធីសាស្ត្រនៃការដោះស្រាយក្រៅប្រព័ន្ធតុលាការនៅឡើយ។ ពោលគឺ គូភាគីវិវាទនៅតែមានជម្រើសក្នុងការប្តឹងទៅតុលាការឲ្យជួយកាត់សេចក្តីបាន។ ហេតុនេះ តុលាការក៏ជាស្ថាប័នមានសមត្ថកិច្ចលើវិវាទប្រាតិភោគដោយអនុប្បទានផងដែរ។

## ផ្នែកទី២ លក្ខខណ្ឌនៃការទទួលស្គាល់ប្រាតិភោគដោយអនុប្បទានតាមរយៈការចុះបញ្ជីនៅជប៉ុន

### កថាខណ្ឌទី១ លក្ខខណ្ឌគ្រឹះ និងផលប្រយោជន៍នៃការចុះបញ្ជីចលនវត្ថុ

ប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ នៅប្រទេសជប៉ុន អ្នកតាក់តែងច្បាប់ បានយកចិត្តទុកដាក់ខ្លាំងទៅលើបញ្ហាប្រាតិភោគដោយមានការធានា។ នៅប្រទេសជប៉ុន ក៏ទទួលស្គាល់«ការប្រគល់ចលនវត្ថុ» ជាលក្ខខណ្ឌសម្រាប់តតាំងក្នុងករណីធានាបំណុលដែរ។ ប៉ុន្តែនេះគ្រាន់តែជាបញ្ញត្តិដែលមិនទាន់ត្រូវបានកែប្រែ មានន័យថា ជាបញ្ញត្តិដែលជប៉ុនប្រើប្រាស់កាលពីមុន។

បច្ចុប្បន្ននេះ តើជប៉ុនបានធ្វើវឌ្ឍនកម្មយ៉ាងដូចម្តេចខ្លះ ទៅលើបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌតតាំងករណីអនុវត្តចំពោះចលនវត្ថុ?

បន្ទាប់ពីលក្ខខណ្ឌនៃការផ្ទេរការកាន់កាប់ដែលជាលក្ខខណ្ឌគ្រឹះ «ការចុះបញ្ជីលើចលនវត្ថុ» បានក្លាយជាលក្ខខណ្ឌតតាំងដ៏មានសុវត្ថិភាពមួយ ដែលត្រូវបានបង្កើតឲ្យអនុវត្តនៅក្នុងប្រទេសជប៉ុនចាប់ពីខែ មីនា ឆ្នាំ២០០៥មក។ ដោយផ្តោតទៅលើតម្រូវការរបស់សហគ្រាសធុនតូច និងមធ្យម អ្នកច្បាប់ជប៉ុន បានបង្កើតជាបញ្ញត្តិបន្ថែមនេះដើម្បីសម្រួលសុវត្ថិភាពជំនួញ ក៏ដូចជាសុវត្ថិភាពប្រាតិភោគដោយអនុប្បទានឲ្យកាន់តែមានភាពប្រសើរឡើង។ ការចុះបញ្ជីត្រូវធ្វើឡើងចំពោះទាំង

ចលនវត្ថុធម្មតា (មួយៗ ដាច់ដោយឡែក) ទាំងចលនវត្ថុផ្តុំគ្នា។ ព័ត៌មាននានាទាក់ទងនឹងការបង្កើតប្រាតិភោគដោយអនុប្បទាន អាចនឹងត្រូវបានបើកទូលាយជាចំហឲ្យសាធារណជនដឹងឮ ពោលគឺជនណាក៏ដោយអាចមើលពីសភាពខាងក្រៅ របស់ចលនវត្ថុក៏អាចបញ្ជាក់បានថាចលនវត្ថុជាប់ឬមិនជាប់ធានាបំណុលប្រាតិភោគដោយអនុប្បទាន។ ប្រសិនបើ គេចង់បានព័ត៌មានពីចលនវត្ថុ គេអាចធ្វើការស្នើសុំទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីដើម្បីត្រួតពិនិត្យបាន។ ទោះបីជាពុំទាន់ដឹងជាមុនថា វត្ថុនោះពិតជាកំពុងជាប់ចុះបញ្ជីហើយ ឬយ៉ាងណាក៏ដោយ សាធារណជនក៏អាចស្នើសុំឲ្យស្ថាប័នមានសមត្ថកិច្ចជួយស្រាវជ្រាវពីចលនវត្ថុនោះឲ្យខ្លួនបាន ដោយគ្រាន់តែប្រាប់ពីអត្តសញ្ញាណរបស់វត្ថុ ព្រោះប្រព័ន្ធនៃការចុះបញ្ជីនេះ មានលក្ខណៈឯកភាពគ្នាទូទាំងប្រទេសជប៉ុន ដោយទិន្នន័យទាំងអស់ត្រូវបានបង្រួមចូលគ្នាក្នុងប្រព័ន្ធតែមួយ។

យ៉ាងណាមិញ តាមរយៈប្រាតិភោគដោយអនុប្បទាន «ការប្រគល់ដោយសង្ខេប» ដែលចាត់ទុកជាលក្ខខណ្ឌតតាំងជាមួយតតិយជន គឺអាចចោទជាបញ្ហាឡើង ដោយសារថា តាមការប្រគល់ដោយសង្ខេបនេះ គឺមិនអាចឲ្យមើលពីលក្ខណៈខាងក្រៅបានថា ចលនវត្ថុនោះ ជាកម្មវត្ថុនៃការដាក់ប្រាតិភោគឬទេ? បញ្ហានេះ ត្រូវបានអ្នកជំនាញការផ្នែកច្បាប់នៅប្រទេសជប៉ុន ក៏ដូចជាអ្នកវិភាគទាំងឡាយជឿជាក់ថា វាអាចនឹងបង្កផលប៉ះពាល់ដល់ប្រយោជន៍របស់តតិយជន ឬអាចជារបស់ម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានលំដាប់ទី២។

ឆ្លើយតបទៅនឹងបញ្ហាខាងលើនេះ ប្រទេសជប៉ុនក៏បានបង្កើតនូវប្រព័ន្ធបង្ហាញជាសាធារណៈនូវឋានៈរបស់ចលនវត្ថុ កាលពីឆ្នាំ២០០៤កន្លងទៅនេះ ពោលគឺមានការបង្កើត«**ច្បាប់ពិសេសស្តីពីសិទ្ធិប្រាតិភោគដោយអនុប្បទានលើចលនវត្ថុ**»។ ខ្លឹមសារគួរឲ្យកត់សម្គាល់នៅក្នុងច្បាប់នោះ គឺការនាំយកនូវប្រព័ន្ធនៃការចុះបញ្ជីលើចលនវត្ថុមកអនុវត្ត។ នៅពេលដាក់ប្រាតិភោគចលនវត្ថុ ដើម្បីបង្កើតប្រាតិភោគដោយអនុប្បទាន តម្រូវឲ្យមានការយកចលនវត្ថុនោះទៅធ្វើការចុះបញ្ជីជាមុនសិន។ តាមរយៈវិធីសាស្ត្រនៃការចុះបញ្ជីនេះ អាចក្លាយទៅជាលក្ខខណ្ឌនៃការតតាំងជាមួយនឹងម្ចាស់បំណុល ឬតតិយជនដទៃទៀតបាន។ យោងតាមបទប្បញ្ញត្តិនៅក្នុង ច្បាប់ពិសេសស្តីពីសិទ្ធិប្រាតិភោគដោយអនុប្បទានលើចលនវត្ថុ ការចុះបញ្ជីនេះ គឺចាត់ទុកដូចទៅនឹងលក្ខខណ្ឌនៃការប្រគល់វត្ថុដោយផ្ទាល់ដែរ។ ***យ៉ាងណាក៏ដោយ ការចុះបញ្ជីនេះ កម្រិតតែទៅលើនីតិបុគ្គលដែលត្រូវធ្វើការចុះបញ្ជីរាល់ពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានតែប៉ុណ្ណោះ***។

ហេតុផលនៃការបង្កើតឲ្យមានប្រព័ន្ធចុះបញ្ជីឡើង គឺដោយសារតែវិធីសាស្ត្រនៃការបង្ហាញជាសាធារណៈថាចលនវត្ថុណាមួយជាប់ដាក់ប្រាតិភោគហើយ ឬយ៉ាងណានោះ ពិបាកនឹងទទួល

យកបាន ព្រោះតាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់ និងការផ្ទេរការកាន់កាប់ដោយបញ្ញា គឺជាការមើលលក្ខណៈពីខាងក្រៅសុទ្ធសាធ ដែលមិនអាចធ្វើឲ្យគេមើលឃើញពីសភាពបំណុលរបស់វត្ថុណាមួយនោះទេ។ បន្ទាប់ពីបង្កើតប្រព័ន្ធនេះឡើង គេសង្កេតឃើញថាចំនួនវិវាទអំពីប្រាតិភោគដោយអនុប្បទានមានការថយចុះ ដែលជាសញ្ញានៃការដោះស្រាយបញ្ហាដ៏មានប្រសិទ្ធភាព។ នេះសបញ្ជាក់ឲ្យឃើញថា ការអនុវត្តវិធីនេះអាចបង្ការហានិភ័យដែលនឹងកើតមានឡើងទាំងចំពោះតតិយជន ទាំងចំពោះម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន។ ក្នុងករណីដែលម្ចាស់បំណុលថ្មី ចង់បង្កើតការធានាដោយប្រើប្រាស់ចលនវត្ថុដដែល នោះម្ចាស់បំណុលថ្មីនឹងមានលទ្ធភាពក្នុងការដឹងពីស្ថានភាពរបស់ចលនវត្ថុ ហើយបើម្ចាស់បំណុលថ្មីនៅតែយល់ព្រមបង្កើតសិទ្ធិលើបំណុលជាមួយកូនបំណុល នោះនឹងបង្កលក្ខណៈងាយស្រួលដល់ការបែងចែក វែកញែកថាបំណុលក្រោយនេះមានឬគ្មានកំហុស។ បន្ថែមពីនេះ ការចុះបញ្ជីនេះ បានផ្តល់ជាប្រយោជន៍ច្រើន ដោយហេតុថា អ្នកគ្រប់គ្រងព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងការដាក់ប្រាតិភោគចលនវត្ថុគឺជាស្ថាប័នមានសមត្ថកិច្ចរួមតែមួយ ដែលមិនមែនជាកូនបំណុលខ្លួនឯង ដូចនេះលទ្ធភាពនៃការភ័ន្តច្រឡំ ឬហានិភ័យនានា នឹងមិនងាយកើតមានឡើង។

ជារួមការអនុវត្តបែបនេះ នឹងជួយធានាឲ្យបានថាផលប្រយោជន៍របស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននឹងមិនត្រូវបានរំលោភបំពាន។

នៅក្នុងប្រទេសជប៉ុនដដែល ចំពោះការចុះបញ្ជីមិនត្រឹមតែធ្វើទៅលើចលនវត្ថុនីមួយៗប៉ុណ្ណោះទេ ថែមទាំងអនុវត្តទៅលើចលនវត្ថុផ្គុំគ្នា[36]ទៀតផង។ មុននឹងមានការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ជនដែលនឹងក្លាយជាម្ចាស់បំណុល អាចមានសិទ្ធិក្នុងការស្នើសុំត្រួតពិនិត្យលើស្ថានភាពរបស់ចលនវត្ថុជាមុនសិន ដើម្បីបញ្ជាក់ពីភាពទំនេរពីបំណុលរបស់វត្ថុនោះ។

យ៉ាងណាមិញ ទោះបីជាការចុះបញ្ជីចលនវត្ថុនេះ ជាមូលដ្ឋានគ្រឹះក្នុងការធានាបាននូវការមិនរំលោភបំពានបំណុល ប៉ុន្តែជាគោលការណ៍បានកំណត់យ៉ាងជាក់លាក់ថា អាចធានាបានត្រឹមតែអាជ្ញាយុកាល១០ឆ្នាំ។ បើហួសរយៈពេលនេះ ការចុះបញ្ជីមិនមានប្រសិទ្ធភាពក្លាយជាលក្ខខណ្ឌតតាំងទៀតទេ។ នៅពេលមានការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ពោលគឺមានការចុះបញ្ជីលើចលនវត្ថុ សិទ្ធិកម្មសិទ្ធិលើចលនវត្ថុត្រូវបានដកចេញពីកូនបំណុល។ ក្នុងករណីកូនបំណុលសងត្រឡប់ទៅវិញនូវបំណុលគ្រប់ចំនួន សិទ្ធិកម្មសិទ្ធិនេះនឹងត្រូវបានប្រគល់ត្រឡប់ទៅម្ចាស់បំណុល

[36] ចលនវត្ថុផ្គុំគ្នា គឺជាចលនវត្ថុច្រើនដែលត្រូវបានកំណត់ តាមទំហំ មាត្រដ្ឋាន ដូចជាប្រភេទ ឬកន្លែងស្ថិតនៅរបស់ចលនវត្ថុ ទោះបីអាចនឹងមានការប្រែប្រួលក្តី ឬគ្មានក្តី។

វិញ ខណៈពេលដែលសិទ្ធិកម្មសិទ្ធិនេះ នឹងត្រូវបានដកហូតទាំងស្រុងពីកូនបំណុលតែម្តងទៅឲ្យម្ចាស់បំណុលប្រសិនបើកូនបំណុលមិនសងត្រឡប់នូវបំណុលរបស់ខ្លួននោះទេ។ ក្នុងករណីនេះចលនវត្ថុនោះផងដែរនឹងត្រូវបានចាត់ចែងផ្ទេរមកឲ្យម្ចាស់បំណុលទៅតាមស្ថានភាពជាក់ស្តែង។

### កថាខណ្ឌទី២ ការចុះបញ្ជីចលនវត្ថុ

#### ក- ប្រភេទនៃការចុះបញ្ជី

ជាគោលការណ៍ ការចុះបញ្ជីមាន៣សណ្ឋានគឺ[37]៖

- ការចុះបញ្ជីអនុប្បទានចលនវត្ថុ (ចុះពេលបង្កើតសិទ្ធិលើបំណុល)
- ការចុះបញ្ជីបន្តចិរវេលានៃការចុះបញ្ជី (ធ្លាប់ចុះរួចហើយ គ្រាន់តែបន្ថែមរយៈពេល)
- ការចុះបញ្ជីប្រកាសលុបចោលការចុះបញ្ជីពីមុន

ការបែងចែកជាប្រភេទបែបនេះ គឺជួយសម្រួលនូវរបៀបរៀបរយនៃការចុះបញ្ជី ដែលអាចជាប្រយោជន៍សម្រាប់ទាំងស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រង ក្នុងការបែងចែកទៅតាមប្រភេទនីមួយៗ សម្រួលសម្រាប់ទាំងសាធារណជនឲ្យមានភាពងាយស្រួលយល់ និងឆាប់រហ័សស្វែងរកព័ត៌មានពាក់ព័ន្ធឃើញ។

#### ខ- នីតិវិធីនៃការចុះបញ្ជី

អ្នកសិក្សាទាំងឡាយ បានជ្រាបច្បាស់ហើយថា ពាក់ព័ន្ធនឹងរឿងរ៉ាវឯកជន មិនចាំបាច់មានតតិយជន ឬអន្តរការីណាមកជ្រៀតជ្រែកក្នុងរឿងផ្ទាល់ខ្លួនរបស់គេនោះទេ ដោយឈរលើគោលការណ៍គោរពស្វ័យភាពនៃឆន្ទៈរបស់បុគ្គល(គូភាគី ឬជនមានសិទ្ធិដែលពាក់ព័ន្ធតែប៉ុណ្ណោះ)។ ដើម្បីបង្កើតប្រាតិភោគដោយអនុប្បទាន ក៏មិនខុសពីសិទ្ធិឯកជនដទៃទេ គឺគូភាគី (ម្ចាស់បំណុល និងកូនបំណុល) មានសិទ្ធិស្វ័យសម្រេចព្រមព្រៀងជាមួយគ្នា នឹងទៅចុះបញ្ជីលើចលនវត្ថុដែលជាកម្មវត្ថុនៃការធានា។

បន្ទាប់ពីមានការព្រមព្រៀងគ្នាហើយ ភាគីអាចរៀបចំសំណុំបែបបទ ឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមការណែនាំ រួចនាំយកទៅចុះបញ្ជីដោយផ្ទាល់ នៅក្រសួងមហាផ្ទៃនៃទីក្រុងតូក្យូ ឬសេនាធិការរបស់ក្រសួងមានសមត្ថកិច្ចចុះបញ្ជីដែលនៅជិតទីតាំងរបស់គូភាគី។ វិធីសាស្ត្រមួយទៀត គឺអាចផ្ញើតាមសារអេឡិចត្រូនិចដើម្បីស្នើសុំចុះបញ្ជី។

---

[37] គេហទំព័រក្រសួងយុត្តិធម៌ជប៉ុន http://www.moj.go.jp/MINJI/DOUSANTOUKI/TOUKI_SHINSEI/tetsuzuki01.html (ចូលមើលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦)

បើពិចារណាពីនីតិវិធីនៃការចុះបញ្ជីប្រាតិភោគដោយអនុប្បទាននៅប្រទេសជប៉ុន គឺពិតជាមានការបង្កើនទំនុកចិត្តដល់ម្ចាស់បំណុលចំពោះកូនបំណុលហើយ ថែមទាំងបង្កភាពងាយស្រួលរាប់តាំងពីនីតិវិធីនៃការចុះបញ្ជីឡើង។

គួរបញ្ជាក់ផងដែរថា លក្ខខណ្ឌដែលតម្រូវឲ្យមាននៅពេលចុះបញ្ជី បែងចែកទៅតាមប្រភេទនៃការចុះបញ្ជី។

*ការចុះបញ្ជីអនុប្បទានចលនវត្ថុ*

ដើម្បីចុះបញ្ជីតម្រូវឲ្យ ៖

- ប្រសិនបើអ្នកស្នើសុំ គឺជានីតិបុគ្គល ត្រូវមានអ្នកតំណាងផ្លូវច្បាប់ (មានលិខិតបញ្ជាក់ពីភាពជាតំណាងផង)
- បញ្ជាក់ពីអាសយដ្ឋានរបស់អ្នកស្នើសុំឲ្យបានច្បាស់លាស់
- មានទម្រង់លិខិតបញ្ជាក់ពីសុពលភាពនៃការចុះបញ្ជីសម្រាប់រយៈពេល១០ឆ្នាំ។

*ការចុះបញ្ជីពន្យារពេលនៃការចុះបញ្ជី*

- ប្រសិនបើអ្នកស្នើសុំ គឺជានីតិបុគ្គល ត្រូវមានអ្នកតំណាងផ្លូវច្បាប់
- អ្នកតំណាងតាមផ្លូវច្បាប់ត្រូវមានលិខិតបញ្ជាក់ពីភាពតំណាង ដែលលិខិតនេះធ្វើក្នុងអំឡុង៣ខែចុងក្រោយ
- ទម្រង់លិខិតបញ្ជាក់ហត្ថលេខារបស់ម្ចាស់បំណុល និងកូនបំណុលថាព្រមព្រៀងនឹងបន្តពន្យារពេលចុះបញ្ជីទៀត
- លិខិតបង្ហាញហេតុផលនៃការចង់បន្តសុពលភាព។

*ការចុះបញ្ជីប្រកាសលុបចោលការចុះបញ្ជីពីមុន*

- ប្រសិនបើអ្នកស្នើសុំ គឺជានីតិបុគ្គល ត្រូវមានអ្នកតំណាងផ្លូវច្បាប់
- អ្នកតំណាងតាមផ្លូវច្បាប់ត្រូវមានលិខិតបញ្ជាក់ពីភាពតំណាង ដែលលិខិតនេះធ្វើក្នុងអំឡុង៣ខែចុងក្រោយ
- ទម្រង់លិខិតបញ្ជាក់ហត្ថលេខារបស់ម្ចាស់បំណុល និងកូនបំណុលថាព្រមព្រៀងនឹងបន្តពន្យារពេលចុះបញ្ជីទៀត។

យើងអាចកត់សម្គាល់បានថា ការកំណត់លក្ខខណ្ឌច្បាស់លាស់មុន និងកំពុងធ្វើការចុះបញ្ជីនេះ បង្កភាពជាក់លាក់ និងមិនមានលក្ខណៈស្មុគស្មាញណាស់ណានោះទេ។

### គ- ទីកន្លែងចុះបញ្ជី និងស្ថាប័នមានសមត្ថកិច្ច

ជាគោលការណ៍ កន្លែងចុះបញ្ជីចលនវត្ថុមាន២គឺៈ

- កន្លែងចុះបញ្ជីផ្ទាល់
- កន្លែងចុះបញ្ជីមិនផ្ទាល់

កន្លែងចុះបញ្ជីផ្ទាល់ សំដៅលើ នាយកដ្ឋានទទួលបន្ទុកផ្នែករដ្ឋប្បវេណីនៃក្រសួងមហាផ្ទៃ ដែលស្ថិតនៅទីក្រុងតូក្យូ(民事行政部動産登録課、東京法務局) ឬក៏អាចជាទីកន្លែងដែលមានសមត្ថកិច្ចនៅជិតទីតាំងបង្កើតប្រាតិភោគដោយអនុប្បទាន[38]។

ការចុះបញ្ជីតាមប្រព័ន្ធអ៊ីនធើណេត (Online Registration, オンライン登記) (ឬហៅថាតាមរយៈសារអេឡិចត្រូនិច) គឺត្រូវបញ្ចូលកម្មវិធីនៃការចុះបញ្ជី (Install Registration Program) ទៅក្នុងកុំព្យូទ័រ រួចនឹងមានការពន្យល់នីតិវិធីតាមលំដាប់លំដោយដើម្បីចុះបញ្ជី។ គួរបញ្ជាក់ឲ្យកាន់តែច្បាស់ផងដែរថា ការចុះបញ្ជីនេះ គឺត្រូវការមានអ្នកតំណាងតាមច្បាប់ ឬអ្នកតំណាងដោយអាណត្តិមកធ្វើការសម្របសម្រួលលើនីតិវិធី ក៏ដូចជាចាត់ទុកថាជាសាក្សីក្នុងការចុះបញ្ជីអចលនវត្ថុនោះ។

ករណីចលនវត្ថុធម្មតា ការចុះបញ្ជីគឺមានរៀបចំឈ្មោះចលនវត្ថុនោះទៅក្នុងប្រភេទដូចគ្នាភ្ជាប់ជាមួយនឹងលេខកូដសម្គាល់របស់ចលនវត្ថុ (Serial Number) ដែលអាចឲ្យបែងចែក និងកំណត់បានពីអត្តសញ្ញារបស់ចលនវត្ថុ។ ចំណែកករណីចលនវត្ថុផ្គុំគ្នា គេចុះបញ្ជីដោយមានព័ត៌មានបន្ថែមមួយចំនួនរួមមានឈ្មោះ ប្រភេទ ថែមទាំងទីតាំងជាក់លាក់ដែលចលនវត្ថុផ្គុំគ្នាជាកម្មវត្ថុនៃការធានាតាំងនៅផង។

### កថាខណ្ឌទី៣ អាទិភាពតតាំងសិទ្ធិចំពោះកូនបំណុល តតិយជន ឬម្ចាស់បំណុល

ឆ្លើយតបទៅនឹងបញ្ហាចោទពីខាងដើម ក្នុងករណីតតិយជនអាចក្លាយជាអ្នកទិញ ជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានលំដាប់ទី២ ឬជាម្ចាស់បំណុលលើមួយផ្នែកនៃចលនវត្ថុផ្គុំគ្នា ប្រសិនបើម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន បានអនុវត្តត្រឹមត្រូវទៅតាមនីតិវិធីនៃការចុះបញ្ជី

[38] ឧទាហរណ៍ថា ម្ចាស់រោងចក្រកាត់ដេរមួយបានយកម៉ាស៊ីនដេរចំនួន៥០គ្រឿងទៅដាក់ប្រាតិភោគដោយអនុប្បទានជាមួយម្ចាស់បំណុលរបស់ខ្លួនដែលមានលំនៅក្បែររោងចក្រនោះ។ សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតនៅលំនៅដ្ឋានម្ចាស់បំណុល ដូចនេះគេអាចទៅរកអាជ្ញាមានសមត្ថកិច្ចចុះបញ្ជីនៅក្នុងតំបន់រស់នៅដើម្បីចុះបញ្ជីលើម៉ាស៊ីនដេរទាំង៥០គ្រឿងបាន។

នៅពេលមានការបង្កើត នោះម្ចាស់បំណុលប្រាតិភោគដោយអនុប្បទានមានអាទិភាពខ្ពស់ក្នុងការប្រើប្រាស់សិទ្ធិជាម្ចាស់បំណុលរបស់ខ្លួន ទៅតតាំងចំពោះតតិយជន ព្រមទាំងកូនបំណុលផងដែរ។

ថ្វីត្បិតតែការចុះបញ្ជី ពិតជាមានប្រសិទ្ធភាពខ្ពស់ក្នុងការធានាបាននូវលក្ខខណ្ឌតតាំងចំពោះតតិយជនក៏ពិតមែន តែការចុះបញ្ជីនេះក៏ឆ្លៀតទុកឱកាសឲ្យតតិយជនវិញខ្លះដែរ។ តាមរយៈការចុះបញ្ជី អាចមានអានុភាពតតាំង១០ឆ្នាំ ហើយបើផុតអាជ្ញាយុកាលនេះ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងនឹងតតិយជន ឬកូនបំណុលបានទេ[39]។ ប៉ុន្តែប្រសិនបើដល់កំណត់១០ឆ្នាំហើយ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានចុះបញ្ជីបន្តទៀតលើចលនវត្ថុដដែល ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាននៅតែមានមូលដ្ឋានគ្រឹះរឹងមាំទៅតតាំងជាមួយតតិយជនបានដដែល។

[39] ច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទាន មាត្រា៧ កថាខណ្ឌទី៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជារួមមក ក្រោយពីបានសិក្សាយ៉ាងស៊ីជម្រៅទៅលើប្រាតិភោគដោយអនុប្បទានមក យើងអាចមើលឃើញពីចំណុចខ្លាំង និងចំណុចខ្សោយនៃប្រាតិភោគដោយអនុប្បទានរបស់ប្រទេសកម្ពុជា និងប្រទេសជប៉ុនបាន។ នៅប្រទេសកម្ពុជា ដោយហេតុថា បញ្ញត្តិពាក់ព័ន្ធនឹងប្រាតិភោគដោយអនុប្បទាននៅមិនទាន់មានលក្ខណៈសម្បូរបែបនៅឡើយ ហេតុនេះ គេសង្កេតឃើញថា ការការពារតតិយជន ក៏ដូចជាម្ចាស់បំណុលហាក់បីដូចជាមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ បទប្បញ្ញត្តិនៃប្រាតិភោគដោយអនុប្បទាន នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជានៅមានចំណុចខ្វះខាត ពុំទាន់គ្រប់ជ្រុងជ្រោយនៅឡើយ។ ចំណុចបញ្ហាដែលកើតឡើងនោះ គឺការធ្វើឲ្យមានតុល្យភាពនូវការការពារសិទ្ធិ និងផលប្រយោជន៍រវាងម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ជាមួយនឹងតតិយជន (អាចជាអ្នកទិញសុចរិត ឬម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានថ្មីដោយសុចរិត)។ ដើម្បីឲ្យច្បាស់ជាងនេះទៅទៀត ការវិភាគទៅលើបញ្ហាដែលអាចកើតឡើងទាំង២ករណីដូចដែលបានរៀបរាប់ពីខាងដើម ចង់សំដៅថា ប្រសិនបើតតិយជនជាជនសុចរិត នោះច្បាប់នឹងការពារសិទ្ធិរបស់តតិយជន។ ហេតុនេះ ម្ចាស់បំណុលនឹងបាត់បង់សិទ្ធិតតាំងរបស់ខ្លួនជាមួយតតិយជន។ ទន្ទឹមនឹងការមើលឃើញពីការខាតបង់ប្រយោជន៍របស់ម្ចាស់បំណុលបែបនេះ មានចំណោទសួរមួយបានចោទឡើងថា តើម្ចាស់បំណុលនឹងមិនត្រូវទទួលរងនូវកង្វះការការពារសិទ្ធិទេឬយ៉ាងណា? ចំពោះម្ចាស់បំណុល យ៉ាងហោចណាស់ក្នុងនាមជាអ្នកឲ្យលុយទៅកូនបំណុលខ្ចី លទ្ធភាពដែលអាចនឹងកើតមាននាំឲ្យខាតបង់ប្រយោជន៍របស់ខ្លួនបែបនេះ មិនគួរបណ្តោយឲ្យកើតមានទាល់តែសោះ។

គួរបញ្ជាក់ពីដើមចមដែលបណ្តាលឲ្យមានបញ្ហាបាត់បង់ទំនុកចិត្តក្នុងរឿងធានាបំណុលនេះ គឺបណ្តាលមកពីការទទួលស្គាល់«ការផ្ទេរតាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់» ជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រផ្ទេរការកាន់កាប់ផ្សេងទៀត ដើម្បីធ្វើជាលក្ខខណ្ឌក្នុងការតតាំងជាមួយនឹងតតិយជន។ តាមរយៈការប្តូរលក្ខណៈនៃការកាន់កាប់នេះ មិនអាចធានាថា គេអាចមើលឃើញជាក់ស្តែងពីខាងក្រៅ អំពីភាពជាប់ធានាបំណុលរបស់វត្ថុនោះទេ។

ចំណែកឯនៅប្រទេសជប៉ុន គេសង្កេតឃើញថា ប្រាតិភោគដោយអនុប្បទានមានការកើតឡើងតាំងពីមុនការបង្កើតច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទានម្ល៉េះ។ គេសង្កេតឃើញពីកម្សោយនៃការអនុវត្តប្រាតិភោគដោយអនុប្បទាននាពេលនោះ តែក្រោយពីឆ្នាំ២០០៤ ជាឆ្នាំបង្កើតច្បាប់ពិសេសនេះមក ជប៉ុនស្ទើរតែលែងកើតមានវិវាទប្រាតិភោគអនុប្បទានកើតឡើងទៀត។ ភាពខ្លាំង គឺច្បាប់នេះមានប្រព័ន្ធនៃការចុះបញ្ជីត្រឹមត្រូវ ហើយមានសមត្ថកិច្ចអនុវត្តច្បាស់លាស់ ដែល

ជាហេតុធ្វើឲ្យប្រតិបត្តិការប្រាតិភោគដោយអនុប្បទានកាន់តែមានសុក្រឹត្យភាពថែមទៀត។ ដោយធ្លាប់ឆ្លងកាត់បទពិសោធន៍ជួបប្រទះកន្លងមក អ្នកច្បាប់នៃព្រះរាជាណាចក្រជប៉ុនបានសម្រេចបង្កើតប្រព័ន្ធថ្មី ដើម្បីជួយសម្រួលដល់ការអនុវត្តប្រាតិភោគដោយអនុប្បទាន បញ្ចៀសនូវវិវាទកុំឲ្យកើតមានឡើង។ ប្រព័ន្ធថ្មីនោះគឺ «ប្រព័ន្ធនៃការចុះបញ្ជីចលនវត្ថុ ដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន»។ តាមរយៈការចុះបញ្ជីនេះ ជាកត្តាជម្រុញឲ្យមានការបង្ហាញជាសាធារណៈមានលក្ខណៈជាក់ច្បាស់ថាចលនវត្ថុណាមួយនោះ មានជាប់ធានាបំណុលហើយឬនៅ ដោយហេតុថាសាធារណជន អាចមានសិទ្ធិក្នុងការស្នើសុំត្រួតពិនិត្យបញ្ជីចលនវត្ថុដែលបានចុះបញ្ជីរួចហើយនោះបាន។

ឆ្លើយតបទៅនឹងគោលបំណងនៃសារណានេះទៀតសោត អាចឲ្យវែកញែកដាច់ ពីគ្នាបានថា«ការបញ្ចាំ» សំដៅតែលើករណី ដែលម្ចាស់បំណុលជាអ្នកកាន់កាប់ដោយផ្ទាល់លើចលនវត្ថុនៅក្នុងអំឡុងពេលដែលកូនបំណុលមិនទាន់បានអនុវត្តកាតព្វកិច្ចសងចប់សព្វគ្រប់។ ចំណែកឯ«ប្រាតិភោគដោយអនុប្បទាន» មានន័យថាម្ចាស់បំណុលមិនបាច់កាន់កាប់ដោយផ្ទាល់លើចលនវត្ថុដែលជាកម្មវត្ថុនៃការធានាលើបំណុល ហើយអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់ចលនវត្ថុនោះបានក្នុងអំឡុងពេលអនុវត្តកាតព្វកិច្ចសង។

ស្របតាមចំណុចដែលបានរៀបរាប់ខាងលើ ចំណុចដូចគ្នារវាងប្រាតិភោគដោយអនុប្បទានកម្ពុជា និងជប៉ុន គឺត្រង់ថា ជាបញ្ញត្តិដែលអនុវត្តទៅលើចលនវត្ថុ ដូចជារថយន្ត ទោចក្រយានយន្ត គ្រឿងអេឡិចត្រូនិច គ្រឿងអលង្ការជាដើម។ ការបង្កើតប្រាតិភោគដោយអនុប្បទាន គឺដើម្បីជួយសម្រួលដល់កូនបំណុល ជាប្រយោជន៍ឲ្យកូនបំណុលបន្តកាន់កាប់ ដើម្បីមានលទ្ធភាពក្នុងការប្រើប្រាស់លើចលនវត្ថុ ដែលត្រូវបានយកមកដាក់ប្រាតិភោគរួច។ បច្ចុប្បន្ននេះ នៅពេលរោងចក្រ ឬក្រុមហ៊ុននានា មានបំណងខ្ចីប្រាក់ទៅបំពេញកង្វះខាតក្នុងមុខជំនួញរបស់ខ្លួន គេចូលចិត្តខ្ចីតាមរយៈប្រាតិភោគដោយអនុប្បទានជាជាងតាមរយៈការបញ្ចាំចលនវត្ថុ ដើម្បីជាការទុកចលនវត្ថុប្រើប្រាស់បន្តក្នុងអំឡុងពេលកំណត់សងបំណុលនោះវិញ។ មិនត្រឹមតែក្នុងពេលបច្ចុប្បន្ននេះទេ បើពិចារណាទៅលើភាពងាយស្រួលនៃការប្រើប្រាស់វិធីប្រាតិភោគដោយអនុប្បទាននេះទៅ នៅប្រទេសកម្ពុជានាពេលអនាគត និន្នាការនៃការជ្រើសប្រើវិធីនេះ អាចនឹងនៅតែបន្តកើនឡើងថែមទៀត។ ជាការយោងផ្សំបន្ថែមទៅលើគំនិតនេះ ក្រឡេកមើលទៅការវិវត្តន៍នៅក្នុងប្រទេសជប៉ុន ពីមុនក៏ជប៉ុនមិនសូវប្រើប្រាស់វិធីប្រាតិភោគដោយអនុប្បទាននេះដែរ។ ប៉ុន្តែដោយមើលឃើញពី

គុណប្រយោជន៍ជាច្រើនរបស់ប្រាតិភោគដោយអនុប្បទាន ជម្រុញឲ្យការអនុវត្តប្រាតិភោគដោយអនុប្បទាន មានការកើនឡើងគួរឲ្យកត់សម្គាល់។

យ៉ាងណាមិញ គេសង្កេតឃើញអំពីចំណុចខុសគ្នាគួរឲ្យកត់សម្គាល់ ត្រង់ថានៅជប៉ុនមាន «ប្រព័ន្ធចុះបញ្ជី»ពេលមានការបង្កើតប្រាតិភោគដោយអនុប្បទានឡើង ហើយមានសមត្ថកិច្ចព្រមទាំង បទដ្ឋានគតិយុត្តនានា ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ជាប្រយោជន៍ដល់ការអនុវត្តបញ្ញត្តិប្រាតិភោគដោយអនុប្បទានកាន់តែមានភាពល្អប្រសើរមួយកម្រិតទៀត។ «ការចុះបញ្ជី»នេះ បានក្លាយជាលក្ខខណ្ឌគ្រឹះដ៏សំខាន់ ជួយសម្រួលឲ្យសុវត្ថិភាពជំនួញកាន់តែមានភាពល្អប្រសើរឡើង។ បើពិចារណាឲ្យងាយស្រួលទៅលើចំណុចនេះ អ្នកសិក្សាអ្នកស្រាវជ្រាវហ្មត់ចត់ ល្អិតល្អន់ទៅលើក្រមរដ្ឋប្បវេណីទាំងឡាយបានដឹងរួចហើយថា ការចុះបញ្ជី បានក្លាយទៅជាលក្ខខណ្ឌដ៏ចម្បងដើម្បីបង្កើតសិទ្ធិប្រត្យក្ស (ការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យក្ស)ទៅលើអចលនវត្ថុ ដែលអចលនវត្ថុនេះ ត្រូវបានចាត់ទុកថាជាកម្មវត្ថុដ៏សំខាន់នៅក្នុងបញ្ហាបំណុល អចលវត្ថុនេះទៀតសោត ពាក់ព័ន្ធសំខាន់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដែលច្បាប់បានផ្តល់សារៈសំខាន់ខ្លាំងចំពោះវត្ថុនេះ ញ៉ាំងឲ្យមានការបង្កើតលក្ខខណ្ឌនៃការចុះបញ្ជីឡើង។ នៅប្រទេសជប៉ុន មិនត្រឹមតែមើលឃើញពីតម្លៃជាសារវន្តរបស់អចលនវត្ថុតែប៉ុណ្ណោះទេ សូម្បីតែចលនវត្ថុក៏បង្កើតឲ្យមានប្រព័ន្ធនៃការចុះបញ្ជីដែរ សម្រាប់ធ្វើជាលក្ខខណ្ឌតតាំង ក្នុងគោលបំណងធ្វើឲ្យម្ចាស់បំណុល ក៏ដូចជាជនដែលពាក់ព័ន្ធទាំងឡាយមានសុវត្ថិភាពក្នុងបញ្ហាជំនួញរបស់ខ្លួន។

ចំពោះកម្ពុជាវិញ បញ្ញត្តិប្រាតិភោគដោយអនុប្បទាននៅមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយ ពិសេសពាក់ព័ន្ធនឹងការចុះបញ្ជី ដែលជាហេតុបណ្តាលឲ្យហានិភ័យអាចនឹងកើតមានឡើងខ្ពស់ពិសេសចំពោះម្ចាស់បំណុល និងតតិយជន។ ជាលក្ខណៈដោយឡែកពីប្រទេសជប៉ុនមួយទៀត គឺនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាមានចែងរួចជាស្រេចពីបញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាននេះ ចាប់ពីមាត្រា៨៨៨ ដល់មាត្រា៨៩៩។

ជាសេចក្តីសន្និដ្ឋានរួម កិច្ចការស្រាវជ្រាវមួយនេះ បានចង្អុលបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាការអនុវត្តប្រាតិភោគដោយអនុប្បទាន បានបង្កលក្ខណៈងាយស្រួលដល់កូនបំណុលក្នុងការធានាលើបំណុលរបស់ខ្លួន ព្រោះលទ្ធភាពនៃការប្រើប្រាស់ចលនវត្ថុដែលជាកម្មវត្ថុនៃបំណុលនៅតែអាចកើតមានឡើង។ បើទោះបីលក្ខណៈបែបនេះ ត្រូវបានអនុវត្តជាទូទៅដូចគ្នាទាំងនៅកម្ពុជា និងនៅជប៉ុន ក៏ប៉ុន្តែគេសង្កេតឃើញពីលក្ខខណ្ឌដ៏រឹងមាំនៅប្រទេសជប៉ុនដែលតម្រូវឲ្យមានការចុះបញ្ជីលើ

ចលនវត្ថុនៅពេលបង្កើតប្រាតិភោគដោយអនុប្បទាននេះ។ ផ្ទុយទៅវិញ នៅប្រទេសកម្ពុជា មិនមានដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធចុះបញ្ជីបែបនេះទេ។

ដោយយោងតាមបទពិសោធន៍នៅប្រទេសជប៉ុន ដែលធ្លាប់មានវិវាទកើតឡើងហើយត្រូវបានគេរកដំណោះស្រាយរួច កម្ពុជាគួរចេះច្បិចយកបទពិសោធន៍ល្អៗពីការអនុវត្តផ្នែកច្បាប់នៃប្រទេសមួយនេះ ដើម្បីធ្វើជាទុនពង្រឹងវិស័យច្បាប់ទាំងលើគោលការណ៍ ទាំងលើការអនុវត្ត ឲ្យកាន់តែមានភាពប្រសើរឡើង។ នោះគឺ ការទាញយកប្រព័ន្ធនៃការចុះបញ្ជីចលនវត្ថុលើការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ដើម្បីឲ្យម្ចាស់បំណុលមានទំនុកចិត្តចំពោះការសងបំណុលត្រឡប់មកវិញគ្រប់ចំនួន និងជាកត្តារាំងស្ទះកុំឲ្យកូនបំណុលមានការប្រព្រឹត្តទង្វើមិនប្រក្រតីណាមួយដែលអាចជះឥទ្ធិពលដល់ការខាតសិទ្ធិ និងប្រយោជន៍របស់ម្ចាស់បំណុល។ តាមរយៈវិធីសាស្ត្រនេះ អាចជួយឲ្យម្ចាស់បំណុល និងតតិយជន រក្សាបាននូវតុល្យភាពនៃសិទ្ធិលើបំណុល មានន័យថា អាចកំណត់ពីលំដាប់សិទ្ធិថា គួរផ្តល់ចំពោះអ្នកណា បានត្រឹមកម្រិតណា។

បន្ថែមពីនេះ ក្រៅពីការផ្តល់គុណសម្បត្តិដល់គូភាគីពាក់ព័ន្ធនឹងបំណុល តាមរយៈការចុះបញ្ជីនៅស្ថាប័នមានសមត្ថកិច្ច រដ្ឋក៏អាចរកផលចំណេញបានដោយយកពន្ធលើការចុះបញ្ជីបាន បើទោះបីជាថវិកានេះ អាចនឹងជាចំណូលមួយផ្នែកតូចសម្រាប់ចម្រើនសេដ្ឋកិច្ចកម្ពុជាក៏ដោយ។ ការបញ្ញត្តិឲ្យកាន់តែមានភាពទូលំទូលាយ នឹងជម្រុញឲ្យមានការប្រើប្រាស់ប្រព័ន្ធប្រាតិភោគដោយអនុប្បទានកាន់តែច្រើន ដែលនេះជាកត្តាញ៉ាំងឲ្យខឿនសេដ្ឋកិច្ចជាតិនឹងមានការកើនឡើងថែមទៀត។

# អនុសាសន៍

# អនុសាសន៍

ដោយហេតុថា នៅប្រទេសកម្ពុជា ច្បាប់បានការពារតតិយជនសុចរិតជាពិសេស ឲ្យមានសិទ្ធិអាទិភាពជាងម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន ហេតុនេះអាចនឹងមានសំណួរមួយចោទឡើងថា តើម្ចាស់បំណុលមិនមែនជាជនសុចរិតនោះទេឬយ៉ាងណា? តើម្ចាស់បំណុលមានកំហុសដែរឬទេ? ជាការពិតណាស់ ម្ចាស់បំណុលពិតជាជនដែលសុចរិត ស្មោះត្រង់ពិតប្រាកដ។ នៅត្រង់ចំណុចដែលបានរៀបរាប់កន្លងមកនេះ បញ្ហាចោទឡើងត្រង់កូនបំណុលខ្លួនឯងដែលមិនគោរពកាតព្វកិច្ចជាកូនបំណុល ហើយលបលួចយកចលនវត្ថុដែលខ្លួនកាន់កាប់ដោយផ្ទាល់ស្រាប់ទៅប្រើប្រាស់បង្កើតសិទ្ធិលើបំណុលជាបន្ត ឬលក់ទៅតតិយជនដោយចេតនា។

ប្រទេសកម្ពុជា ជាប្រទេសដែលទទួលយកជំនួយខាងផ្នែកក្រមរដ្ឋប្បវេណីពីប្រទេសជប៉ុន រហូតដល់មានការចងក្រងក្រមរដ្ឋប្បវេណីកម្ពុជាថ្មីឡើង ស្របជាមួយនឹងការជួយឧបត្ថម្ភផ្នែកបច្ចេកទេសយ៉ាងស៊ីជម្រៅពីក្រុមការងារអ្នកច្បាប់ជនជាតិជប៉ុនទៀតផង។ ប្រទេសជ-ប៉ុនកាលពីអតីតកាល ក៏ធ្លាប់ជួបប្រទះបញ្ហាប្រាតិភោគដោយអនុប្បទានដូចដែលបានចោទឡើងនៅក្នុងកម្ពុជាដែរ គឺតាំងពីមុនមានការចុះបញ្ជីលើចលនវត្ថុ។ តែក្រោយមក បន្ទាប់ពីមានប្រព័ន្ធនៃការចុះបញ្ជីត្រូវបានបង្កើតឡើង បញ្ហាក៏ស្ទើរតែលែងចោទឡើងទៀត។

ហេតុដូចដែលបានពោលខាងលើនេះហើយ ប្រទេសកម្ពុជាគួរយកគំរូបង្កើតប្រព័ន្ធនៃការចុះបញ្ជីចលនវត្ថុសម្រាប់ករណីប្រាតិភោគដោយអនុប្បទានដែរ ដែលប្រការនេះ គឺជាការចេះដកស្រង់យកចំណុចល្អៗពីច្បាប់បរទេស យកមកពិចារណាឲ្យត្រូវសមនឹងស្ថានការណ៍ កាលៈទេសៈនៃប្រទេសយើង ជាស្ពានជួយដោះស្រាយ និងបញ្ចៀសបញ្ហាកុំឲ្យកើតមានឡើងទាំងក្នុងពេលបច្ចុប្បន្ន ទាំងទៅពេលអនាគត។

អ្នកសិក្សា ស្រាវជ្រាវ និស្សិត និងអ្នកបំពេញវិជ្ជាជីវៈខាងផ្នែកច្បាប់ទាំងឡាយ គួរគប្បីយកចិត្តទុកដាក់ទៅលើបញ្ហាប្រាតិភោគនេះ ចៀសវាងការកើតមានបញ្ហាទាំងពេលបច្ចុប្បន្ន និងកាន់តែកើនបញ្ហាឡើងនាពេលអនាគត ដូចដែលបានមើលឃើញស្រាប់ពីមេរៀនមកពីប្រទេសជប៉ុនមក អំពីការធ្លាប់ជួបប្រទះវិវាទគោរពសិទ្ធិគូភាគីក្នុងបញ្ហាបំណុល។ កម្ពុជាគួរតែមានប្រព័ន្ធចុះបញ្ជីចលនវត្ថុសម្រាប់ធ្វើឲ្យមានភាពរលូនចំពោះម្ចាស់បំណុលប្រាតិភោគដោយអនុប្បទាន ដោយយកមកអនុវត្តកែច្នៃឲ្យសក្តិសមជាមួយនឹងស្ថានភាព ក៏ដូចជាចេះបត់បែនឲ្យត្រូវនឹងរបត់នៃសង្គមជាតិយើង។

សរុបសេចក្តីមក ជាអនុសាសន៍រួម កម្ពុជាគួរតែៈ

ទី១ៈ នាំយកប្រព័ន្ធនៃការចុះបញ្ជីចលនវត្ថុតាមគំរូច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទានរបស់ប្រទេសជប៉ុន មកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ដើម្បីធានាសុវត្ថិភាពជំនួញដល់គ្រប់ភាគីពាក់ព័ន្ធ ជាពិសេសចំពោះម្ចាស់បំណុល។

ទី២ៈ ផ្សព្វផ្សាយអំពីប្រព័ន្ធថ្មីនេះឲ្យបានទូលំទូលាយ ភ្ជាប់ជាមួយនឹងការដាក់សមត្ថកិច្ចឲ្យបានគ្រប់គ្រាន់ ដើម្បីធានាការអនុវត្តនីតិវិធីនៃការចុះបញ្ជីឲ្យមានប្រសិទ្ធភាពទៅតាមលទ្ធភាពដែលអាចធ្វើបាន។

ទី៣ៈ ម្ចាស់បំណុល និងកូនបំណុល គួរសហការគ្នា អនុវត្តតាមប្រព័ន្ធចុះបញ្ជីនេះ ឲ្យបានត្រឹមត្រូវ ដើម្បីកុំឲ្យមានការខាតបង់ប្រយោជន៍រៀងៗខ្លួន ស្របពេលដែលស្ថាប័នមានសមត្ថកិច្ចគួរយកចិត្តទុកដាក់អនុវត្តបទប្បញ្ញត្តិស្តីពីការចុះបញ្ជីនេះឲ្យបានហ្មត់ចត់ ធ្វើឲ្យមានសង្គមសុខដុមនីយកម្មកើតឡើង ថែមទាំងជាប្រយោជន៍ជួយឲ្យដំណើរការសេដ្ឋកិច្ចជាតិ មានសន្ទុះរីកចម្រើនជាងមុនទៀត។

ប្រសិនបើមានការអនុវត្តបានខ្ជាប់ខ្ជួន តាមគោលការណ៍ច្បាប់ នោះលទ្ធភាពដែលបង្កជាបញ្ហានឹងថមថយ សុវត្ថិភាពជំនួញក៏នឹងរឹតតែប្រសើរឡើង ព្រមទាំងជាផ្នែកញ៉ាំងឲ្យកម្ពុជាក្លាយជានីតិរដ្ឋ ព្រោះមានច្បាប់គ្រប់គ្រាន់ ទន្ទឹមនឹងការជម្រុញប្រជាពលរដ្ឋឲ្យអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ៕

# ឯកសារយោង

# ឯកសារយោង

- **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ**

  ១. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

  ២. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រជប៉ុន ឆ្នាំ១៨៩៦

  ៣. «ច្បាប់ពិសេសស្តីពីប្រាតិភោគដោយអនុប្បទាន» ឆ្នាំ២០០៤ (ជប៉ុន)

  ៤. ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឆ្នាំ២០០៧ (កម្ពុជា)

- **សៀវភៅជាតិ និងអន្តរជាតិ**

  ១. សមាជិកក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ,*សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១* , ខែមេសា ឆ្នាំ២០១៣

  ២. សមាជិកក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២*, ខែមេសា ឆ្នាំ២០១៣

  ៣. សមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទថៅក្រម, *ក្រមរដ្ឋប្បវេណីភាគ៥*, បោះពុម្ពខែមីនា ឆ្នាំ២០១២

  ៤. លោកអ៊ឹឈិដា តាកាស៊ី, *ក្រមរដ្ឋប្បវេណី ភាគ៣ សិទ្ធិលើបំណុល និងសិទ្ធិប្រត្យក្ស*, បោះពុម្ពលើកទី៣ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយតូក្យូ ខែកញ្ញា ឆ្នាំ២០០៥

  内田貴『民法Ⅲ　債権総論・担保物権（第３版）』、（東京大学出版会、２００５年９月）

- **សាលដីកា**

  ១. កម្រងសាលដីកាលេខ១៤-២ (ជប៉ុន)

- **គេហទំព័រ**

  ១. ធនាគារពិភពលោក http://www.worldbank.org/en/country/cambodia/overview
  (ចូលមើលថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦)

  ២. ព័ត៌មានភ្នំពេញប៉ុស្ត៍ http://www.phnompenhpost.com/business/pawn-shop-rise-proves-quick-fix
  (ចូលមើលថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦)

  ៣. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ http://gdfi.mef.gov.kh/?page=detail&ctype=article&id=675
  (ចូលមើលថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦)

  ៤. ក្រសួងយុត្តិធម៌ជប៉ុន http://www.moj.go.jp/MINJI/DOUSANTOUKI/TOUKI_SHINSEI/tetsuzuki01.html
  (ចូលមើលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦)